# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣២ លេខ ១០ ខែតុលា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

- ព្រះពុទ្ធនិងលទ្ធិព្រះពុទ្ធសាសនា លោក ប្រៀម-ទឹម រៀបរៀង . . ១០៨១
- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ជាំង-ទាត់ រៀបរៀង . . . ១០៨៨
- ព្រះអភិធម្មបិដក គម្ពីរកថាវត្ថុ (តមក) លោក ប៊ូ-ប៉ូ រៀបរៀង . ១០៩៩
- មធុរសវាហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ . . . . ១១១៣
- មហោសថជាតក (តមក) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ . . . . . . ១១១៩

*ផ្នែកអក្សរសាស្ត្រ*

- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ១១២៩
- រឿងព្រេងនិងរឿងបុរាណជប៉ុនក្នុងមជ្ឈិមសម័យ (តមក) លោកវ៉ាយ-ម៉ុក រៀបរៀង ១១៥៩
- អធិប្បាយសុភាសិត លោក ស្តើង ធូរ រៀបរៀង លោកឧត្តមប្រឹជា ចាប-ពិន ពិនិត្យ ១១៦៦
- រឿងព្រេងប្រទេសហ្វីលីពីន ភិក្ខុ ម៉ែន-រៀម ប្រែចាកភាសាអង់គ្លេស . . . ១១៨២
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . ១១៨៣

*ផ្នែកកំណត់និងប្រវត្តិការណ៍*

- ពត៌មានផ្សេង ៗ របស់ក្រសួងធម្មការ . . . . . . ១១៩៤
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ទាត់ រៀបរៀង . ១១៩៨

មួយឆ្នាំ មាន ១២ សៀវភៅ ថ្លៃជាវ ២៣០រ០០

# KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## sommaire

### Partie religieuse :

— Le Bouddha et sa religion par M. NHEM-KHEM . . . . 1081

— La Vie du Buddha (suite) par Prâh maha PANG-KHAT . 1088

— Prah Abhidhammapitaka ( Kathavathu) (suite) par M. BOU-PO 1099

— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par le Vén. NHEAN-CHHOEUN . . . 1113

— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON revu par le Vén-KEM-TO 1119

### Partie littéraire :

— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 1129

— Contes et Légendes du Japon au Moyen-Age (suite) traduits par M. RAY-BUC . . . . . . . . 1159

— Commentaire du proverbe par M. SDOEUNG-CHHO revu par M. CHAP-PIN . . . . . . . . . . . 1166

— Contes et légendes Philippins traduits par Bhikkhu MEN-REAM 1182

— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1187

### Notes et Chroniques :

— Nouvelles diverses du Ministère des Cultes . . . . . . . . 1194

— Dictionnaire Sanscrit-khmer (suite) par le Vén. PANG-KHAT 1198

---

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

# ផ្នែកសាសនា

## ព្រះពុទ្ធ និងលទ្ធិព្រះពុទ្ធសាសនា

យើងអាចរាប់នាមមេបង្កើតសាសនាទាំងឡាយក្នុងលោកបានច្រើនណាស់ តែក្នុងទីនេះ សូមលើកយកតែនាមមេបង្កើតសាសនា ៤ រូបធំៗ មកអធិប្បាយ ព្រោះសាសនាបួននេះមានបរិស័ទគោរពរាប់អានច្រើនជាងសាសនាដទៃទៀតក្នុងសាកលលោក ។ ឯនាមអ្នកបង្កើតសាសនាបួនពួកនោះគឺ ព្រះពុទ្ធ, ព្រះយេស៊ូ, ព្រះមោហាម្មេត, ព្រះក្រិស្ណៈដែលជាអវតារព្រះនារាយណ៍ ។

បើយើងប្រៀបធៀបអំពីបុគ្គលិកលក្ខណៈ អំពីការប្រព្រឹត្តអំពីរបៀបផ្សាយសាសនានៃមេបង្កើតសាសនាទាំងបួននេះ យើងសង្កេតឃើញប្រាកដថា មានការប្លែកគ្នារវាងព្រះពុទ្ធនឹងមេបង្កើតសាសនាបីពួកទៀត ។

ដំបូងបង្អស់ព្រះពុទ្ធមានការប្លែកពីអច្ឆរិយបុគ្គលឯទៀត ត្រង់ព្រះអង្គមានព្រះទ័យប្រកបដោយ «ការលះបង់» មានការលះបង់ទ្រព្យសម្បត្តិនិងការលះបង់ព្រះសរីរកាយជាដើម ។

ព្រះយេស៊ូបានប្រកាសសាសនាថា លោកជាបុត្រព្រះអាទិទេព

ហើយនណាមួយក៏ពុំអាចទៅកើតឯស្ថានទេវតាបានឡើយ បើមិនទទួលស្គាល់លោកថាជាបុត្រនៃព្រះអាទិទេព ។

ព្រះមោហាម្មេត ថាខ្លួនលោកមិនត្រឹមតែជាអ្នកនាំសារព្រះអាទិទេព មកកាន់ស្ថានក្រោមនេះប៉ុណ្ណោះទេ គឺខ្លួនលោកនេះជាអ្នកនាំសារចុងក្រោយបំផុតរបស់ព្រះអាទិទេពទៀតផង ។ ព្រះមោហាម្មេតមិនខុសគ្នាពីព្រះយេស៊ូទេ លក្ខណ្ឌចាំបាច់របស់លោក គឺការទទួលស្គាល់គុណសម្បត្តិផ្ទាល់របស់លោក ដើម្បីទៅកាន់ទីសុខក្សេមក្សាន្តមិនមានទីបំផុត ។

ព្រះគ្រិស្ណៈវិញមានទិន្នាការឆ្ងាយជាងនេះទៅទៀត គឺលោកមិនពេញចិត្តនឹងទទួលនាមជាបុត្រព្រះអាទិទេព ឬ ជាអ្នកនាំសារចុងក្រោយបង្អស់នៃព្រះអាទិទេព ឬ ពុំនោះជាព្រះអាទិទេពតែមួយប៉ុណ្ណោះទេ ព្រោះលោកបានបញ្ជាក់ទុកថា លោកជាព្រះនៃព្រះអាទិទេពទាំងអស់ទៅទៀត។

ផ្ទុយទៅវិញ ព្រះពុទ្ធពុំដែលប្រកាសសញ្ជាតិព្រះអង្គថា ជាព្រះអាទិទេពទេ ព្រះអង្គជាបុត្រមនុស្សលោកពិតៗ ហើយនៅគ្រប់ទិសទីដែលព្រះអង្គបាទៈយាងទៅទេសនាប្រៀនប្រដៅពុទ្ធបរិស័ទ ព្រះអង្គពុំដែលមានពុទ្ធដីកា អួតអំពីអាគតដ្ឋាន ឬ អំពីរិទ្ធិអំណាចអ្វីឲ្យហួសពីវិស័យធម្មជាតិទេ បើមានខ្លះព្រះអង្គគ្រាន់តែសំដែងបាដិហារ្យ ឲ្យឃើញជាក់ស្តែងនឹង

ក្តែកអ្នកស្តាប់តាមៗ ប៉ុណ្ណោះ ។

ការប្លែកទីពីរ គឺព្រះពុទ្ធជាមគ្គទេសក៍, ជាអ្នកបង្ហាញ ជាអ្នកចង្អុលប្រាប់ផ្លូវឲ្យគេដើរ ។ ឯព្រះយេស៊ូ, ព្រះមោហាម្មត, ព្រះក្រិស្ណៈតាមតាយេកពាក្យថា « អ្នកដោះលែង » មកជាក់ខ្លួន ។

ព្រះពុទ្ធជាមគ្គទេសក៍បានសេចក្តីថា ព្រះពុទ្ធទ្រង់ស្គាល់យ៉ាងច្បាស់នូវផ្លូវប្រតិបត្តិនាំឲ្យកើតបុណ្យនឹងបាបនោះ ហើយព្រះអង្គអាចប្រាប់ដល់បរិស័ទព្រះអង្គបានថា អំពើនេះល្អគឺបុណ្យ, អំពើនេះអាក្រក់គឺបាប រួចព្រះអង្គបានទូន្មានថា គួរគប្បីបរិស័ទទាំងឡាយ ប្រព្រឹត្តតែអំពើល្អ ៗ ប៉ុន្តែបើជនណាមិនជឿព្រះអង្គ ។ ក៏ឥតមានទោសដែរ ព្រោះអំពើបាបនឹងបុណ្យជាលទ្ធផល នៃការប្រព្រឹត្តរបស់ជនម្នាក់ ៗ គឺជនណាបានសាបព្រោះនូវអំពើអ្វី ជននោះប្រាកដកាត់យកផលអំពីអំពើនោះ ។ ឧទាហរណ៍ដូចជាទ្រង់ហាមមិនឲ្យសេពសុរា ព្រោះព្រះអង្គទ្រង់ស្គាល់ច្បាស់នូវទោសនៃសុរា នូវហេតុជាគ្រឿងវិនាសបណ្តាលមកពីសុរា ។ ការណ៍នេះអស់លោកបានសង្កេតឃើញស្រាប់ហើយក្នុងបច្ចុប្បន្នកាលនេះមនុស្សប្រមឹកសុរាជាមនុស្សដែលសង្គមមនុស្សគោរពច្រើន ចាត់ទុកជាមនុស្សកោកតាប, មនុស្សវង្វេងស្មារតី, មនុស្សអេប្បយស ។ល។ ទាំងច្បាប់ប្រដៅក្នុងចៅយើងពីបុរាណក៏មានថែងថា „លោកជាធ្គតប៊ ធ្គតមួយ

នឹងស្រី ក្តួតមួយនឹងស្រា ក្តួតមួយនឹងល្បែង អំពើពាលា... ។ នេះហើយជាផលនៃអំពើអាក្រក់, ជាផលនៃអំពើបាបដែលបណ្តាលមកពីការមិនជឿតាមពាក្យទូន្មាននៃព្រះមគ្គុទ្ទេសក៍ដ៏វិសេសរបស់យើងគឺព្រះពុទ្ធ ។ អំពើបាបនេះមិនមានតែនៅក្នុងបច្ចុប្បន្នកាលនេះប៉ុណ្ណោះទេ, ព្រះពុទ្ធទ្រង់បានសំដែងថានៅមានទៅជាតិមុខទៀត សូមលោកអ្នកដែលចង់ជ្រាបពិនិត្យមើលគម្ពីរនានាខាងព្រះពុទ្ធសាសនាដែលចែងពីរឿងនេះចុះ ។

ដោយយល់ នូវខ្លឹមសារនៃពុទ្ធឱវាទនេះផង ដោយយល់ឋានៈប្រទេសកម្ពុជាដែលជាប្រទេសកាន់ព្រះពុទ្ធសាសនាផង បានជាព្រះរាជរដ្ឋាភិបាលយើង បានហាមប្រាមមិនឲ្យឈ្មួញទូទៅលក់សុរា ឬ ពិឃាតសត្វ មានគោក្របីជាដើម នៅថ្ងៃឧបោសថសីលឡើយ ។

តទៅនេះ នៅមានការប្លែកម្យ៉ាងទៀត គឺព្រះយេស៊ូ ព្រះមោហាម្មេតបានពោលអះអាងថា លោកជាប្រេសិត និងជាអ្នកនាំពាក្យនៃព្រះអាទិទេព លទ្ធិដែលលោកប្រៀនប្រដៅជាគោលច្បាប់សាសនាពិតប្រាកដមិនមានខកាន់ប្រឡំ ត្រូវបរិស័ទទទួលគោរពតាមមិនបាច់មានការពិភាក្សាអ្វីឡើយ ចំណែកព្រះក្រិស្ណៈវិញ ដែលជាព្រះលើព្រះអាទិទេពទៅទៀត សំដីរបស់លោកក៏ត្រូវចាត់ទុក ជាការពិតឥតកាន់ប្រឡំដែរ ។ ឯព្រះសម្មាសម្ពុទ្ធវិញ ព្រះអង្គពុំដែលមានពុទ្ធដីកាអះអាងដូច្នេះទេ ទុពា-

ហរណ៍ដូចជានៅក្នុងមហាបរិនិព្វានសូត្រ ព្រះអង្គទ្រង់បានប្រកាសប្រាប់ព្រះអានន្ទថា សាសនាព្រះអង្គមានមូលដ្ឋានទៅលើការពិសោធន៍និងការរិះរកខុសត្រូវ ។

ត្រង់នេះបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធជាអ្នកហេតុផលនិយមព្រះពុទ្ធមិនមែនជាអ្នកសុទិដ្ឋិនិយម (ដែលយល់ឃើញសុទ្ធតែល្អ ឬ ត្រូវ) និងមិនមែនជាអ្នកទុទិដ្ឋិនិយម (ដែលយល់ឃើញសុទ្ធតែអាក្រក់ ឬ ខុស ) នោះឡើយ ។

មួយចំណែកទៀត ព្រះពុទ្ធទ្រង់បានទាមថា ជាអ្នកធម្មាធិបតេយ្យ គឺព្រះអង្គយកធម៌និងច្បាប់ជាធំ ។ ហេតុនេះហើយបានជានៅក្នុងសាសនាព្រះអង្គ យើងសង្កេតឃើញមានការមិនប្រកាន់វណ្ណៈ បក្សពួក ពណ៌សម្បុរជាដើម ដូចជាព្រះអង្គទ្រង់បានបញ្ញត្តសិក្ខាបទជាប់រហូតមកទល់សព្វថ្ងៃនេះថា ភិក្ខុណាដែលទើបនឹងចូលមកបួសក្នុងសាសនាព្រះអង្គត្រូវតែគោរពសំពះ និងដើរក្រោយភិក្ខុដែលបានបួស ដែលមានវស្សាច្រើនជាង ទោះភិក្ខុបួសថ្មីនោះមកពីត្រកូលកស្ត្រសាមញ្ញក្តី មកពីត្រកូលក្សត្រក្តី ។

មុននឹងបញ្ចប់ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ព្រះពុទ្ធសាសនា ជាសាសនាដកល់ផ្លូវចិត្ត និងបញ្ញាត្រិះរិះរកខុសត្រូវជាធំ, ហើយជាសាសនា

ផ្អែកលើការពិសោធន៍ និងការពិចារណារករការពិតនិងមិនពិត ។ ដូច្នេះព្រះពុទ្ធអាចចាត់ថា ជាអ្នកទស្សនវិជ្ជាផង ជាអ្នកវិទ្យាសាស្ត្រផង តែវិទ្យាសាស្ត្រព្រះពុទ្ធមានការឈមទៅរកតែផ្លូវល្អ រកផ្លូវចំរើន រកសុខឲ្យជនទូទៅមិនមានរើសមុខ ជាវិទ្យាសាស្ត្រចំហ ។ ជនណាក៏ដោយ បើចង់ចេះចង់ដឹងអាចរកមើលទ្រឹស្តី ឬរូបមន្តនៃវិទ្យាសាស្ត្រព្រះអង្គ នៅក្នុងគម្ពីរនានាឃើញទាំងអស់ ព្រះពុទ្ធមិនបេះលាក់វិជ្ជារបស់ព្រះអង្គឡើយ ។ ចំណែកឯវិទ្យាសាស្ត្រនៃអ្នកប្រាជ្ញសម័យបច្ចុប្បន្នវិញ ច្រើនប្រកបទៅដោយគុណសម្បត្តិផង គុណវិបត្តិផង ។ ឧបមាដូចជាការស្រាវជ្រាវរកឃើញនូវជាតិបរមាណូ ។ ជាតិបរមាណូនេះបើគេយកមកប្រើដើម្បីសុខភាពមនុស្សនោះ ឃើញថាមានប្រយោជន៍សំខាន់ណាស់ ប៉ុន្តែបើគេយកទៅប្រើដើម្បីជាគ្រឿងអាវុធបំផ្លាញទី ១ ក៏ឃើញថាមានការអន្តរាយសម្បើមណាស់ដែរ ។

នៅទីបំផុត ខ្ញុំមានបំណងសុំឲ្យលទ្ធិព្រះពុទ្ធសាសនាបានជ្រួតជ្រាបទៅក្នុងសតិសម្បជញ្ញៈ នៃអ្នកប្រាជ្ញខាងវិទ្យាសាស្ត្រសម័យបច្ចុប្បន្នទាំងអស់កុំបីខានឡើយ ដើម្បីសូមឲ្យអស់លោកទាំងនោះយកវិទ្យាសាស្ត្ររបស់ខ្លួនមកប្រើសម្រាប់តែផ្លូវសុភមង្គលបាន ហើយ ។ ខ្ញុំហ៊ានធានាថា

ដែលបណ្តាលឲ្យពុទ្ធសាសនាបានចូលទៅជិតជាប់ក្នុងសតិសម្បជញ្ញៈ នៃអ្នកវិទ្យាសាស្ត្របច្ចុប្បន្ននឹងអ្នកដឹកនាំរដ្ឋទាំងឡាយក្នុងលោក, ដែលនោះធម៌លោភៈ ទោសៈ មោហៈ ក៏វិនាសបាត់បង់ពីសន្តានចិត្តអស់លោកដោយពិត ហើយធម៌អហិង្សានឹងចូលមកជំនួសវិញ ។ ពេលនោះសង្គ្រាមនឹងត្រូវបរាជ័យ, សន្តិភាពពិភពលោកប្រាកដជាមានរូបរាងជាក់ស្តែងឡើង ហើយមនុស្សជាតិទាំងអស់ប្រាកដជានឹងបានសេចក្តីសុខគ្រប់ ៗ គ្នាពុំខាន ។

ជយោ ព្រះពុទ្ធសាសនា !

ញ៉ែម-ចឹម

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

# អវិទូរេនិទាន ទុក្ករកិរិយាកថាទី ៦

១- ឆន្នអាមាត្យត្រឡប់ទៅកបិលពស្តុ ២- ទ្រង់ចូលទៅកាន់ក្រុងរាជគ្រឹះ ៣- ទ្រង់សន្ទនានឹងព្រះបាទពិម្ពិសារ ៤- ទ្រង់ចូលទៅកាន់សំណាក់អាឡារតាបស ៥-ទ្រង់ចូលទៅកាន់សំណាក់ឧទ្ទកតាបស ៦- ទ្រង់ចូលទៅកាន់ឧរុវេលាប្រទេសសេនានិគម ៧- ទ្រង់ប្រព្រឹត្តអត្តកិលមថានុយោគ ៨-សេចក្ដីឧបមា ៣ យ៉ាង ៩ ទ្រង់ធ្វើទុក្ករកិរិយា ១០-ទេពតាចូលទៅថ្វាយដំណឹងព្រះវរបិតា ១១- ទ្រង់ត្រឡប់បរិភោគអាហារវិញ ១២- បញ្ចវគ្គិយតាបសលះបង់ពោធិសត្វ ។

## ១- ឆន្នអាមាត្យត្រឡប់ទៅកបិលពស្តុ

ព្រះពោធិសត្វទ្រង់បព្វជ្ជាហើយ ឆន្នអាមាត្យក៏នាំយកគ្រឿងអាភរណៈទាំងឡាយទៅកាន់ព្រះនគរវិញ ។ ឯកណ្ឋកៈអាជានេយ្យបានឮព្រះតម្រាស់ព្រះពោធិសត្វចំពោះឆន្នអាមាត្យដូច្នេះ ទើបអាណិតខ្លួនដោយគិតឃើញថា ខ្លួនក៏ត្រូវព្រាត់ប្រាសអំពីម្ចាស់ដែរ ទំអត់សង្កត់សេចក្ដីសោកស្រណោះអាឡោះអាល័យមិនបាន ក៏បែកហឫទ័យស្លាប់មួយរំពេចនោះ ទៅកើតស្ថានត្រៃត្រឹង្ស ឈ្មោះកណ្ឋកទេវបុត្រ ។ ឆន្នអាមាត្យនៅតែម្នាក់ឯង យំសោកបណ្ដើរដើរបណ្ដើរ ត្រឡប់ទៅព្រះរាជនគរ

ទៅដល់ហើយ យកសេចក្ដីទៅក្រាបទូលព្រះបាទសុទ្ធោទនៈ តាមបណ្ដាំព្រះពោធិសត្វសព្វគ្រប់ប្រការ ។ គ្រានោះ កោណ្ឌញ្ញព្រាហ្មណ៍បានឮដំណឹងថា ព្រះពោធិសត្វចេញទៅសាងព្រះផ្នួសហើយ ទៅបបួលកូនព្រាហ្មណ៍តាំង ៧ នាក់ដែលបានមត់គ្នារួចហើយ តែបានត្រឹម ៤ នាក់ជាគំរប់ ៥ ទាំងខ្លួន ក៏នាំគ្នាចេញទៅបួសតាមព្រះពោធិសត្វ ។

## ២- ទ្រង់ចូលកាន់ក្រុងរាជគ្រឹះ

លុះទ្រង់បព្វជ្ជារួចហើយ ស្ដេចទៅប្រថាប់សម្រាកព្រះអង្គនៅក្នុងអនុបិយម្ពវនអស់វេលា ៧ ថ្ងៃ សោយបីតិជាអាហារ, ថ្ងៃទី ៨ ទើបស្ដេចប្រដាប់បាត្រចីវរ ទ្រង់ព្រះពជដំណើរដោយព្រះបាទ ចម្ងាយផ្លូវ ៣០ យោជន៍ តែ ១ ថ្ងៃដល់ក្រុងរាជគ្រឹះ ទ្រង់បទចរបិណ្ឌបាតតាមលំដាប់ផ្ទះ ។ កាលណោះ ឮដំណឹងខ្ទរខ្ទារខេទូទៅថាមានមនុស្សម្នាក់ចំឡែកធ្វើដំណើរមកដល់ទីក្រុង កំពុងដើរបិណ្ឌបាត ទីងថាជាទេវតាឬមនុស្សក៏មិនដឹង ទីងថាជានាគឬគ្រុឌក៏មិនដឹង ពួកអ្នកនគរបបួលគ្នាឈូឆរមើលព្រះពោធិសត្វ ។ ពួករាជបុរសយកសេចក្ដីក្រាបបង្គំទូលព្រះបាទពិម្ពិសារតាមដំណើរ ។ ព្រះបាទពិម្ពិសារទ្រង់ព្រះសណ្ដាប់ហើយ មានព្រះបន្ទូលឲ្យរាជបុរសលបឃ្លាំចាំមើល បើជាអមនុស្ស ដល់ចេញពីនគរទើងអន្តរាយបាត់ទៅ បើជាទេវតាទីងហោះទៅកាន់អាកាស បើជានាគទីង

មុជជ្រែកចូលកាន់ប្របពី ថាបើជាមនុស្សទៃ បានអាហារហើយនឹងឈប់បរិភោគមិនខាន ។ ឯព្រះមហាបុរសបានអាហារល្មមញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅបានហើយ ស្តេចចេញអំពីនគរឆ្ពោះព្រះភ័ក្ត្រទៅកាន់ញកភ្នំបណ្ឌវៈ ប្រាថ្នាធ្វើភត្តកិច្ចក្នុងទីនោះ ទតឃើញអាហារគួរបដិកូល ដែលទ្រង់មិនធ្លាប់ឃើញបែបនោះសោះ ក្នុងអត្តភាពរបស់ព្រះអង្គ ទើបទូន្មានព្រះអង្គឯងថា «ម្នាលសិទ្ធត្ថ ! អ្នកកើតក្នុងត្រកូលក្សត្រសុខុមាលជាតិ បរិបូណ៌ដោយភត្តាហារ ធ្លាប់បរិភោគតែភោជនមានក្លិនក្រអូបមានរសឆ្ងាញ់ផ្សេង ៗ អ្នកមិនដឹងខ្លួនថាជាភេទបព្វជិតបែបនេះទេឬ ? ដើរបិណ្ឌបាតដូចម្តេចទើបបានអាហារល្អ», ទ្រង់ឲ្យឱវាទខ្លួនពិចារណាបដិកូលសញ្ញាហើយទ្រង់សោយភត្តាហារនោះ ។

## ៣- ទ្រង់សន្ទនានឹងព្រះបាទពិម្ពិសារ

រាជបុរសដែលលបឃ្លាំចាំមើលឃើញដូច្នោះ ក៏ត្រឡប់យកសេចក្តីមកក្រាបទូលព្រះបាទពិម្ពិសារសព្វគ្រប់ប្រការវិញ, លុះព្រឹកឡើង ព្រះបាទពិម្ពិសារ ស្តេចឡើងរាជរថចេញទៅជាមួយសេវកាមាត្យ ទៅរកព្រះពោធិសត្វ នាបណ្ឌវបព៌ត ទតឃើញព្រះពោធិសត្វហើយ កើតសេចក្តីជ្រះថ្លា ទើបត្រាស់សួរថា «បពិត្រសមណៈ ! ព្រះនាមទ្រង់ដូចម្តេច ? ស្តេចមកពីនគរណា ? មាតាបិតានាមដូចម្តេច ?

ព្រះពោធិសត្វថ្វាយព្រះពរតបវិញថា "បពិត្រមហាពជ ! អាត្មាភាពឈ្មោះសិទ្ធត្ថ មកពីនគរកបិលពស្តុ ព្រះវរបិតា នាមព្រះបាទសុទ្ធោទនៈ ព្រះវរមាតា នាមព្រះនាងមហាមាយាទេវី នៅក្នុងជនបទដ៏ឥតគ្ហាមពាន្ធ សម្បូណ៌ដោយព្យាយាមជាគ្រឿងរកទ្រព្យ ជាក្រុងឡើងដែនកោសល ឈ្មោះគោតម(១)ដោយគោត្រ ឈ្មោះសក្យដោយត្រកូល អាត្មាភាពចេញបួសអំពីសក្យត្រកូលនោះ ដើម្បីប្រាថ្នាកាមក៏ឥតអង្គឹមានទេឡើយ" ។

---

១-គម្ពីរពុទ្ធវង្ស មានសេចក្តីពិស្តារថា តថាគតជាគោតមគោត្រ ចំរើនហើយក្នុងសក្យត្រកូល បានតាំងសេចក្តីព្យាយាមទុករួចហើយ បានសម្រេចសម្ពោធិញ្ញាណដ៏ខ្ពស់បំផុតជាសម្មាសម្ពុទ្ធ ។ល។ នគរទ័ថាគតឈ្មោះកបិលពស្តុ ព្រះបិតាតថាគតឈ្មោះសុទ្ធោទនៈ ព្រះមាតាតថាគតឈ្មោះមាយាទេវី, តថាគតនៅគ្រប់គ្រងផ្ទះ ២៩ វស្សា មានប្រាសាទខ្ពស់ ៣ ខ្នង ឈ្មោះសុចន្ទ ១ ឈ្មោះកោក ១ នឹងកោញ្ច ១ មានស្រ្តីស្អិតស្អាងល្អហើយ ៤ ម៉ឺននាក់, នារីជាភរិយាឈ្មោះយសោធរា បុត្រឈ្មោះរាហុល ។ ដោយហេតុឃើញនិមិត្តទាំង ៤ ទើបតថាគតយកកណ្ឋកៈ ជាពាហនៈចេញចាកគេហដ្ឋាន ដើម្បីធ្វើសេចក្តីព្យាយាមដ៏ធំអស់វេលា ៦ ព្រះវស្សា, តថាគតបានប្រកបកិច្ចដែលបុគ្គលដទៃធ្វើបានដោយកម្រ ។ តថាគតជាជិនៈ ប្រកាសធម្មចក្រនៅឯព្រៃឥសិបតនៈមិគទាយវ័នទៀបក្រុងពារាណសី បានត្រាស់ជាសម្មាសម្ពុទ្ធឈ្មោះគោតម ជាទីពឹងនៃសត្វលោកទាំងឡាយ ។ ភិក្ខុជាអគ្គសាវក ២ រូបគឺៈ កោលិតនឹងឧបតិស្ស, ឧបដ្ឋាកឈ្មោះអានន្ទ, ភិក្ខុនីជាអគ្គសាវិកា ២ រូបគឺ នាងខេមានឹងនាងឧប្បលវណ្ណា, ឧបាសកជាអគ្គឧបដ្ឋាក ២ រូបគឺចិត្តៈនឹងហត្ថាឡវកៈ, ឧបាសិកាជាអគ្គឧបដ្ឋាយិកា ២ រូបគឺ នន្ទមាតានឹងនាងឧត្តរា, តថាគតបានត្រាស់ជាព្រះសម្មាសម្ពុទ្ធដ៏ខ្ពង់ខ្ពស់ទៀបពោធិមណ្ឌល ។ល។

ព្រះបាទពិម្ពិសារទ្រង់ព្រះតម្រិះគិតក្រែងព្រះពោធិសត្វស្តេចមានវិវាទជាមួយនឹងព្រះវង្សព្រះអង្គ ទើបស្តេចត្រាស់សួរទៅថា បពិត្រសមណៈ! ព្រះអង្គស្តេចមកនេះ ប្រកបដោយសិរីសួស្តីប្រសើរណាស់ ខ្ញុំព្រះអង្គក៏ជាអទិដ្ឋសហាយឈ្មោះពិម្ពិសារ ជាធំលើប្រទេសពីរ គឺអង្គរដ្ឋនឹងមគធរដ្ឋ ខ្ញុំព្រះអង្គនឹងបែងចែករាជសម្បត្តិព្រមទាំងដែនទាំងពីរនេះថ្វាយមួយចំណែក ហើយយើងទាំងពីរនាក់ នឹងសោយរាជសម្បត្តិជាសុខសប្បាយតទៅ ។ ព្រះបរមពោធិសត្វទ្រង់ព្រះសណ្តាប់ហើយ ទើបត្រាស់តបថា សូមអរព្រះគុណថ្វីវិសេសដែលទ្រង់ព្រះមេត្តាប្រោសបែងរាជសម្បត្តិប្រទាន តែអាត្មាភាពមកនេះ មិនមែនមានចេតនាចង់បានប្រយោជន៍ក្នុងវត្ថុកាមនឹងកិលេសកាមទេ អាត្មាភាពបានលះបង់នូវចក្រពត្តិរាជសម្បត្តិដែលជាប់មកក្នុងកណ្តាប់ដៃហើយ ដូចជាដុំខេឡៈ ដែលស្តោះចេញចាកមាត់ ព្រោះប្រាថ្នាសម្មាសម្ពោធិញាណ ទើបបានជាអាត្មាភាពចេញបួស ។ ព្រះបាទពិម្ពិសារត្រាស់សួរទៀតថា "បពិត្រសមណៈ! ទ្រង់លះបង់រាជសម្បត្តិដ៏ធំហើយបព្វជ្ជានោះ តើដោយហេតុអ្វី?", ព្រះពោធិសត្វត្រាស់តបថា "បពិត្រមហារាជ! ព្រោះអាត្មាភាពបានឃើញទេវទូត ៤ មានមនុស្សជរាជាដើម ទើបបានជាចេញមកបួស" ។ ព្រះបាទពិម្ពិសារទ្រង់ត្រាស់អារាធនាថា "សូមទ្រង់ព្រះ

*មេត្តាប្រោស ! កាលបើព្រះអង្គបានសម្រេចសព្វញ្ញុតញ្ញាណហើយ សូមអញ្ជើញទ្រង់មកកាន់ដែនរបស់ខ្ញុំព្រះអង្គមុនគេ(១) ព្រះបរមពោធិសត្វទទួលពាក្យបដិញ្ញាថា «សាធុៗ» ហើយព្រះបាទពិម្ពិសារក៏ក្រាបបង្គំលាត្រឡប់មកកាន់ព្រះនគរវិញ សមដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ទុកថា(២)៖*

"ព្រះរាជាពិម្ពិសារ ទ្រង់គង់លើប្រាសាទ បានទតឃើញព្រះពោធិសត្វដែលកំពុងបិណ្ឌបាត ទើបត្រាស់បំពោះអាមាត្យថា អ្នកទាំងឡាយ ចូរមើលសមណៈនេះមើល ! សមណៈនេះមានរូបល្អកំពស់នឹងទំហំសមរម្យ សម្បុរស្អាត ដំណើរសម មើលទៅមុខត្រឹមមួយជួរនឹម សំឡឹងតែចុះក្រោម មានស្មារតី សមណៈនេះដូចជាមិនមែនអ្នកត្រកូលថោកទាបចេញមកបួសទេដឹង ? អាមាត្យតាមមើលរហូតដល់ភ្នំបណ្ឌវៈ បានដឹងសេចក្ដីហើយ ចូលមកក្រាបទូលព្រះរាជាពិម្ពិសារវិញ ។ ព្រះរាជាពិម្ពិសារស្ដេចទៅដោយព្រះរាជរថ ជាមួយរាជបរិវារ

១- ព្រះអដ្ឋកថាចារ្យបំពេញសេចក្ដីថា "សូមទ្រង់មេត្តាត្រាស់ទេសនាប្រោស ខ្ញុំព្រះអង្គមុនគេ" ។ ២- បព្វជ្ជាសូត្រ សុត្តនិបាត មហាវគ្គ សៀវ. ៥៥ ទំព័រ ១៣២ ។

ស្ដេចបួលទៅប្រឋាប់ហើយត្រាស់បំពោះព្រះពោធិសត្វថា "ខ្ញុំ នែលោក នៅកំពុងពេញវ័យ នៅកំឡោះក្មេង ក្នុងបឋមវ័យ មើលទៅដូចជាជាតិក្សត្រិយ៍ ចូរលោកធ្វើជាមេសេនាដ៏រុងរឿង ដែលមានពួកជនប្រសើរជាបរិវារវិញទៅ! ហើយចូរបរិភោគនូវភោគៈទាំងឡាយចុះ! តែសូមប្រាប់នូវជាតិលោកដល់ខ្ញុំ ។

បពិត្រមហារាជ! ត្រង់ទៅខាងនេះ មានជនបទមួយ នៅប្រប ភ្នំហិមវន្ត ជាជនបទបរិបូណ៌ដោយទ្រព្យនឹងជនមានព្យាយាម អាស្រ័យនៅក្នុងដែនកោសល គោត្រជាអាទិច្ចវង្សជាសាក្យៈ អាត្មាចេញពីត្រកូលនោះមកបួស មិនត្រូវការដោយកាមទេ បានឃើញទោសកាមហើយ ចេញចាកកាម ប្រឹងព្យាយាម ត្រេកអរក្នុងព្យាយាមនោះ" ។

## ៤- ទ្រង់ចូលទៅកាន់សំណាក់អាឡារតាបស

*កាលនោះព្រះបរមពោធិសត្វត្រាច់រង្គាត់ស្វះស្វែងរកពួកគណាចារ្យធំៗ ជាតាបសឫស្យី ឬជាពួកនិគ្រន្ថ ដែលមានឈ្មោះល្បីថាជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ពិតប្រាកដ នៅតែនិត្យលទៅសាកសួរដេញដោលឈានសមាបត្តិ*

*ឬ កិច្ចផ្សេងៗ ហើយទ្រង់បានប្រព្រឹត្តតបធម៌ តាមពួកគណាចារ្យនោះៗ ល្បងមើល លុះឃើញថាមិនពេញព្រះទ័យ ហើយក៏ស្តេចចៀសចេញទៅស្វែងរកតទៅទៀត តាមស្រុកនិគមជនបទតូចធំក្នុងមគធរដ្ឋ ។ ថ្ងៃមួយ ទ្រង់ចូលទៅកាន់សំណាក់អាឡារតាបស ដើម្បីនឹងសាកសួរវត្តប្រតិបត្តិ ដូចសេចក្តីដែលទ្រង់បានត្រាស់ដឹងហើយ បានត្រាស់ចំពោះព្រះពោធិរាជកុមារថា* (១)

រាជកុមារ ! កាលតថាគតបានបួសរួចហើយ ស្វែងរកនូវកិំកុសលសន្តិវរបទ(២) ក៏បានចូលទៅរក អាឡារតាបស សូមប្រព្រឹត្តព្រហ្មចរិយធម៌ អាឡារតាបសឆ្លើយតបថា “អ្នកដ៏មានអាយុ ចូរនៅចុះ ធម៌នេះប្រាកដដូច្នោះ បើជាបុរសអ្នកដឹងសេចក្តីហើយ មិនយូរទេឡើយ គង់នឹងធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាចារ្យរបស់ខ្លួន ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤បាន”។ តថាគតបានរៀនធម៌នោះឆាប់រហ័ស មិនយូរទេឡើយ អាចពោលបានដល់ទៅ

១-ពោធិរាជកុមារសូត្រ, រាជវគ្គ, ម ម. សៀវ ២៤, ទំព័រ ៣៦០ ។ ២-ស្វែងរកនូវធម៌អ្វីជាកុសល និងធម៌អ្វីដ៏ប្រសើរដែលមិនមានធម៌ឯទៀតប្រសើរជាង ។

ញាណភិទៈ និងវេរភិទៈ ដោយអាការគ្រាន់តែទន្ទេញដោយបបូរមាត់ និងដោយអាការគ្រាន់តែបរបាៈទៅមកប៉ុណ្ណោះឯង ។

តថាគត បានចូលទៅរកអាឡារតាបសម្តងទៀត ហើយសួរថា “ ម្នាលអាវុសោកាលាមៈ! លោកធ្វើជាក់ច្បាស់នូវធម៌នេះដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងបានត្រឹមតែប៉ុណ្ណោះទេឬ?”អាឡារតាបស បានប្រកាសដល់អាកិញ្ចញ្ញាយតនជ្ឈាន ។ តថាគតមានសេចក្តីត្រិះរិះថា “មិនមែនមានសទ្ធា វីរិយៈ សតិ សមាធិ បញ្ញា បំពោះតែអាឡារតាបសម្នាក់ឯងទេ សូម្បីយើងក៏មានសទ្ធា វីរិយៈ សតិ សមាធិ បញ្ញាដូច្នោះដែរ តែដូចម្តេចក្តី យើងត្រូវតែដឹកល់ក្តីព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ (អាកិញ្ចញ្ញាយតនជ្ឈាន) របស់អាឡារតាបសឲ្យខាងតែបាន”, មិនយូរប៉ុន្មាន តថាគតក៏បានធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ(អាកិញ្ចញ្ញាយតនជ្ឈាន)ដោយប្រាជ្ញាដ៏ឧត្តមយ៉ាងឆាប់រហ័ស ។ លំដាប់នោះតថាគតបានចូលទៅ

សួរអាឡារតាបសម្តងទៀតថា ម្នាលអាវុសោកាលាមៈ លោកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ (អាកិញ្ចញ្ញាយតនជ្ឈាន) ដោយប្រាជ្ញាដ៏ឧត្តម ហើយញ៉ាំងអ្នកដទៃឲ្យដឹងបាន ត្រឹមតែប៉ុណ្ណោះទេឬ? អាឡារតាបសឆ្លើយតបថា ម្នាលអាវុសោ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ (អាកិញ្ចញ្ញាយតនជ្ឈាន) ដោយប្រាជ្ញាដ៏ឧត្តមតែប៉ុណ្ណោះដែរ ។ យើងពេញជាមានលាភហើយ, ភាពជាមនុស្សយើងបានដោយល្អហើយ ព្រោះពួកយើងបានឃើញនូវសព្រហ្មចារីបុគ្គល ប្រហែលដូចជាអ្នកដ៏មានអាយុ, យើងបានដឹងធម៌ណា អ្នកក៏ដឹងធម៌នោះដែរ, អ្នកដឹងធម៌ណា យើងក៏ដឹងធម៌នោះដែរ, ឥឡូវនេះអ្នកចូរមកចុះ យើងទាំងពីរនាក់នឹងនៅជួយគ្នារក្សាគណៈនេះ, ហើយតាំងតថាគត កាលនៅជាអន្តេវាសិកឲ្យស្មើនឹងខ្លួន បូជាតថាគតដោយការបូជាដ៏លើសលុប ។ តថាគតត្រិះរិះម្តងទៀតថា ធម៌នេះមិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បី

សេចក្ដីរលត់ទុក្ខ ដើម្បីសេចក្ដីរម្ងាប់ ដើម្បីសេចក្ដីដឹង ដើម្បីត្រាស់ដឹង, ដើម្បីព្រះនិព្វានទេ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះ តថាគតមិនពេញចិត្តនឹងធម៌នោះ បានជាគេចចេញចាកធម៌នោះ ហើយចៀសចេញទៅ "។

## ៥–ទ្រង់ចូលទៅកាន់សំណាក់ឧទ្ទកតាបស

*លុះព្រះបរមពោធិសត្វបានសិក្សារៀនសូត្រនឹងអាឡារតាបសកាលាមគោត្រហើយ ទ្រង់ចូលទៅកាន់សំណាក់ឧទ្ទកតាបសរាមបុត្រទៀត ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ(១) (មានដំណើរនិទានដូចកាលទ្រង់ចូលទៅសាកសួរក្នុងសំណាក់អាឡារតាបសដែរ តែកាលទ្រង់សាកសួររួចហើយ ទ្រង់បានសម្រេចនេវសញ្ញានាសញ្ញាយតនជ្ឈានជាឈានទី៨ ប្រសើរវិសេសជាងកាលទ្រង់រៀនក្នុងសំណាក់អាឡារតាបស តែទ្រង់ពិចារណាតទៅទៀត ឃើញថាមិនមែនជាផ្លូវត្រាស់ដឹងរបស់ព្រះអង្គទេ ទើបទ្រង់ចេញចាកទីនោះទៅទៀត) ។*

១–ពោធិរាជកុមារសូត្ររាជវគ្គ, សៀវ ២៤, ទំព័រ ៣៦៤ ។

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរព្រះកថាវត្ថុ

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

(តមក)

---

### បុញ្ញបច្ចយកថា

អត្ថិ អរហតោ បុញ្ញបច្ចយោតិ អាមន្តា អត្ថិ អរហតោ បុញ្ញបច្ចយោតិ ឯវមេវំ វត្តព្វេ អរហា បុញ្ញាភិសង្ខារំ អភិសង្ខរោតិ អនេញ្ជាភិសង្ខារំ អភិសង្ខរោតិ ឯវមេវំ វត្តព្វេ អរហា ចិវរំ ឯនេយ្យាតិ ។

ការនេះ នឹងបាននិស្ស័យនាកផ្ទុកបុញ្ញបច្ចយកថាតទៅ មានដំណើរសេចក្តីថា សម្តេចព្រះមានព្រះភាគជាម្ចាស់ កាលត្រាស់ទេសនាគីហិអរហាកថាចប់ចុះហើយ ទើបត្រាស់ទេសនាបុញ្ញបច្ចយកថា មានព្រះពុទ្ធដីកាជាសកវាទី បរវាទី ដូចតទៅ ៖

សកវាទី– បច្ច័យគឺបុណ្យ នៃព្រះអរហន្តមាន ឬគ្មាន ?

បរវាទី – ទទួលថា បច្ច័យគឺបុណ្យ នៃព្រះអរហន្តនោះមាន ។

សកវាទី– អ្នកថាមាន យើងមិនទាន់ជឿទេ ព្រោះឃើញក្នុងព្រះសូត្រថា " បុញ្ញបាបបហីនស្ស ព្រះអរហន្តមានបុណ្យនឹងបាបលះបង់ហើយ " ហេតុអ្វីបានជាអ្នកថាមាន ។

បរវាទី អ្នកថា ព្រះអរហន្តលះបង់បុណ្យបាបនោះក៏ពិតហើយ ប៉ុន្តែបុញ្ញបច្ច័យនៃព្រះអរហន្តនោះនឹងថាគ្មានក៏ថាមិនបាន ព្រោះព្រះអរហន្តអស់អាសវៈហើយ បើទុកជាធ្វើបុណ្យច្រើនដល់ប៉ុន្មានក៏ដោយ ក៏បុណ្យនោះមិនបានជាបច្ច័យកើតភពខាងមុខឡើយ ។

សកវាទី អ្នកថា បុញ្ញបច្ច័យនៃព្រះអរហន្តគ្មាននោះ យើងនៅមិនទាន់ជឿទេ, បើព្រះអរហន្តគ្មានបុញ្ញបច្ច័យព្រោះអស់អាសវៈហើយ តើលោកធ្វើបុណ្យ ដើម្បីប្រយោជន៍អ្វីទៀត បុញ្ញាភិសង្ខារំ អភិសង្ខរោតិ យើងយល់ឃើញថា ព្រះអរហន្តរមែងធ្វើបុញ្ញាភិសង្ខារ, អបុញ្ញាភិសង្ខារ, អានេញ្ជាភិសង្ខារ ធ្វើការកុសលដ៏ប្រព្រឹត្តទៅដើម្បីភព, ដើម្បីការៈនឹងឲ្យបានជាធំ, ដើម្បីភោគសម្បត្តិ ។

បរវាទី- នហេវំ វត្តព្វេ អ្នកកុំថាយ៉ាងនោះឡើយ មិនគួរទេ ។

សកវាទី- ព្រះអរហន្តនឹងគប្បីឲ្យនូវចីវរបិណ្ឌបាតសេនាសនៈ គិលានភេសជ្ជបរិក្ខារ នឹងនមស្ការព្រះចេតិយគប្បីមានខ្លះដែរឬទេ ?

បរវាទី- ក៏ទទួលថាមាន ។

សកវាទី- បើព្រះអរហន្តឲ្យទាន នឹងនមស្ការព្រះចេតិយហើយ ពាក្យដែលអ្នកឆ្លើយថា បុញ្ញបច្ច័យនៃព្រះអរហន្តគ្មាននោះ មិនគួរនឹងជឿបានឡើយ ព្រោះពាក្យមុននឹងពាក្យក្រោយមិនសមគ្នាសោះ ។

បវេទី- សួរត្រឡប់ទៅវិញថា ព្រះអរហន្តបំពេញទាន ទីផ នមស្ការព្រះចេតិយនោះតើ ដើម្បីប្រាថ្នាអ្វី ?

សកវាទី- ឃើញ គារវកិច ព្រះអរហន្តធ្វើយ៉ាងនោះ ដោយអំណាច ទីផឲ្យឃើញជាតួយ៉ាង សត្វតែតមកខាងក្រោយនឹងបានធ្វើតាមតទៅ ដើម្បីនឹងឲ្យព្រះពុទ្ធសាសនាចម្រើនរុងរឿងឋិតថេរចិរកាល ដែលព្រះអរហន្តប្រកបដោយបញ្ញាច្រើន មានលាភច្រើននោះ អាស្រ័យកុសលអំពីបុព្វជាតិ កុសលដែលលោកបានធ្វើក្នុងកាលសម្រេចព្រះអរហត្តរួចនោះហើយ នឹងបានជាបច្ច័យទៅក្នុងខាងមុខក៏ឥតអង្គីមានឡើយ ។

បុញ្ញូបចយកថា ចប់

---

## អបុញ្ញូបចយកថា

ឆដ្ឋិ អរហតោ អបុញ្ញូបចយោតិ អាមន្តា អរហា បហីនបុញ្ញបាបោ យទិទំ បុញ្ញំ គារវេន្តោ បាបំ គារវេយ្យ អបុញ្ញូបចយោតិ អបុញ្ញំ ច គារវេយ្យាតិ បហីនបុញ្ញបាបោតិ មិច្ឆាតិ ។

ពាក្យនេះនឹងបានវិសជ្ជនាក្នុងអបុញ្ញូបចយកថា មានដំណើរសេចក្តីជាសកវាទី បវេទី ដូចតទៅនេះ

សកវាទី- អកុសលកម្មនឹងតាមឲ្យផល ជាបច្ច័យក្នុងខាងមុខ

នៃព្រះអរហន្តនោះ មានឬគ្មានទេ ? យើងចូលចិត្តថា ការបាបនៃព្រះអរហន្តនោះគ្មានទេ តើទីងត្រូវដូចយើងចូលចិត្តដែរឬមិនត្រូវ ?

បរវាទី អើ, ត្រូវដូចពាក្យអ្នកថាហើយ ការបាបនៃព្រះអរហន្តនោះនឹងជាបច្ច័យទៅទៀតមិនបានទេ ព្រោះលោកលះបង់នូវបុណ្យនឹងបាបបានជ្រះស្រឡះហើយ ដែលលោកនឹងធ្វើ ក៏ធ្វើតែកុសល ឯអកុសលលោកលែងធ្វើហើយ ។

សកវាទី- ពាក្យដែលអ្នកឆ្លើយមកនេះ ពាក្យមុននឹងពាក្យក្រោយមិនសមគ្នាទេ កាលដើមយើងសួរអ្នកថា អបុញ្ញាបច្ច័យនៃព្រះអរហន្តមានឬគ្មាន? អ្នកឆ្លើយថាគ្មានទេ ព្រោះលោកលះបង់បុណ្យនឹងបាបដាច់អស់ហើយ ដល់ចុងក្រោយ អ្នកត្រឡប់ជាពោលថា ព្រះអរហន្តបើធ្វើអ្វីៗ ក៏ធ្វើតែបុណ្យ មិនធ្វើបាបសោះ ដូច្នេះយើងនៅមានសេចក្តីសង្ស័យដ្បិតអ្នកនិយាយថា ព្រះអរហន្តបើធ្វើអ្វីៗ ក៏ធ្វើតែបុណ្យ យនិ បុញ្ញាភិសង្ខារ បើព្រះអរហន្តនៅធ្វើបុណ្យ ក៏នៅតែលះបង់បុណ្យមិនបានដែរហើយៈយើងយល់ឃើញថា ការបាបក៏ព្រះអរហន្តនៅធ្វើ ដូចពាក្យក្នុងព្រះវិន័យថា ព្រះអរហន្តរមែងប្រើឲ្យគេធ្វើកុដិ ទីងទទួលចាប់ពាល់របស់ជាទិស្សគ្គិយ៍ ប៉ុន្តែពុំមានអាបត្តិ ។

បរវាទី- សួរត្រឡប់ទៅវិញថា អ្នកថាព្រះអរហន្តលះបង់បុណ្យ

ទឹងបាបមិនបាននោះតើ ដោយហេតុផលដូចម្ដេច ?

សគាទី- យើងឃើញក្នុងព្រះសូត្រថា ព្រះអរហន្តដែលមានសរីរៈពិកលពិការជំពៅក្ដី អង្គខ្លះមានរូបស្រ្ដីដើរតាមពីក្រោយក្ដី ហើយព្រះអរហន្តនោះរមែងឲ្យចីវរបិណ្ឌបាតសេនាសនៈ ទីងគិលានភេសជ្ជៈបំពេញពាន, សំដែងធម្មទេសនា ក្នុងព្រះសូត្រពោលទុកផ្សេងៗ ដូច្នេះ បានជាយើងថាលះបុណ្យទឹងបាបមិនបានទាំងពីរប្រការ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ព្រះអរហន្តលះបុណ្យទឹងបាបមិនបាននោះ សំដៅយកបុណ្យទឹងបាបដែលធ្វើក្នុងបច្ចុប្បន្នកាល ពុំទាន់បានសម្រេចជាព្រះអរហន្ត លុះបានសម្រេចជាព្រះអរហន្តហើយ សូម្បីធ្វើបុណ្យទឹងបាបច្រើនដល់ប៉ុន្មាន បុណ្យទឹងបាបនោះក៏មិនបានតាមឲ្យផលក្នុងអនាគតកាលទេ ទឹងនាំកើតមកសំដែងដោយសង្ខេប ដូចមានសេចក្ដីតទៅនេះ ៖

អង្គុលិមាលត្ថេរពាប៉ិ រមែងពិត ព្រះអង្គុលិមាលត្ថេរនោះសម្លាប់មនុស្សជាច្រើនទឹងប្រមាណមិនបាន គ្រាន់តែកាត់យកម្រាមដៃម្នាក់ ៗ មួយ ១ មកដោតត្រណោតទុកឲ្យបានគ្រប់មួយពាន់នាក់ ម្រាមដៃ ចាស់ ១ នោះពេះតែស្អុយល្អួយអស់ទៅ មិនបានគង់នៅឲ្យគ្រប់មួយពាន់នាក់សោះ លុះបានមកជួបនឹងសម្ដេចព្រះមានព្រះភាគ ក៏បានសម្រេចព្រះអរហត្តព្រោះបានស្ដាប់ព្រះធម្មទេសនា បញ្ចបញ្ញាទៅតាមក្រសែព្រះ

សទ្ធម្មទេសនា លុះបានសម្រេចព្រះអរហត្តហើយ កម្មដែលសម្លាប់មនុស្សនោះមិនបានតាមទៅឲ្យផលឡើយ ព្រោះជាអហោសិកម្ម ។

ព្រះអរហន្តធ្វើការកុសលច្រើនដល់ប៉ុន្មានក៏ដោយ កុសលនោះមិនបានតាមទៅឲ្យផលទេ ដូចព្រះខីណាសវត្ថេរមួយអង្គនិមន្តទៅភិក្ខាចារក្នុងអនុរាធបុរី នៅវេលាស្រុកកើតទុព្ភិក្ខភ័យ បានអាហារបិណ្ឌបាតក៏បែងចែកឲ្យរុក្ខទេវតា កុសលនោះមិនបានតាមទៅឲ្យផលខាងមុខទេ ព្រោះជាអហោសិកម្ម លោកចូលនិព្វានហើយ កុសលនិងអកុសលក៏អស់ដែរ លែងតាមទៅខាងមុខទៀត ។

ព្រះអរហន្តមានលាភច្រើន, មានយសច្រើន, មានបុណ្យច្រើន, មានអានុភាពច្រើន ប្រាកដក្នុងព្រះពុទ្ធសាសនា ហើយបានសោយសុខវេទនានិងទុក្ខវេទនានោះ ហេតុតែផលនៃកុសលនិងអកុសលក្នុងកាលមុនបានកសាងទុកមក ដូចព្រះសីវលិត្ថេរជាដើម បានទីឯតទគ្គៈជាព្រះមហាថេរលើសជាងព្រះមហាថេរទាំងឡាយ ដែលចាត់ថាជាអ្នកមានលាភច្រើនក្នុងព្រះពុទ្ធសាសនា ក៏ព្រោះតែកុសលដែលខ្លួនធ្វើទុកមក ។

ព្រះបូតិគត្តត្ថេរ មានសរីរាវយវៈ កើតដំបៅរលួយស្អុយ ពងបែកហូរខ្ទុះ ក៏អាស្រ័យផលនៃអកុសលកម្មក្នុងជាតិមុន ។ ព្រះបូតិគត្តត្ថេរនោះកាលពីជាតិមុនកើតក្នុងត្រកូលព្រានសត្វស្លាប មានសេចក្តីប្រមាថ

សម្លាប់សត្វស្លាបលក់ចិញ្ចឹមជីវិតជានិច្ចកាល សត្វដែលលក់សល់ដាក់ទ្រុងបង្ខាំងទុកខ្លះ កាច់ស្លាបមិនឲ្យហើររួចខ្លះ ឲ្យនៅរស់បានយូរថ្ងៃ កាលបើលក់អស់ហើយ ទើបទៅរកចាប់យកមកលក់ទៀត យាវជីវំ នាយព្រានធ្វើអំពើអកុសលនេះដរាបដល់អស់ជីវិត, ខាងមុខអំពីចុតិចិត្តទៅ បានទៅកើតក្នុងនរកអស់កាលជាយូរ លុះរួចពីនរកហើយមកកើតជាប្រេត, មកកើតជាសត្វតិរច្ឆាន កើតក្នុងទុគ្គតិជាយូរអង្វែងកំណត់រាប់កាលមិនបាន បេះតែត្រាច់រង្គាត់វិលវល់នៅក្នុងវាលវដ្តសង្សារ សោយទុក្ខវេទនាជាសហ័ស ព្រោះតែផលនៃអកុសលកម្មដែលខ្លួនធ្វើទុកមក ។

ឥមស្មឹ ពុទ្ធុប្បាទេ លុះដល់ព្រះពុទ្ធសាសនានេះ នាយព្រាននោះមកកើតជាមនុស្សនៅក្នុងនគរសាវត្ថី ចេញបព្វជ្ជាបានឧបសម្បទក្នុងព្រះពុទ្ធសាសនា សេសផលនៃអកុសលកម្មនោះ នៅមិនទាន់អស់ ក៏កើតដំបៅ ពងបែកល្មួយហូរខ្ទុះស្អុយពេញទាំងខ្លួន សោយទុក្ខវេទនាជាខ្លាំង ព្រោះកាលពីបុព្វជាតិបានធ្វើកម្មជាអកុសល ។

សម្តេចព្រះបរមទសពលទ្រង់ត្រាស់ថា វិស័យកម្មវិបាកនេះជាអចិន្ត្រៃយ៍ គឺបុគ្គលមិនគួរគិត បើមិនបានដល់ព្រះនិព្វានដរាបណា កុសលនិងអកុសលរមែងជាប់តាមខ្លួនទៅដរាបនោះ ព្រោះផលនៃអកុសលនោះ មានច្រើនស្ថាន ដោយអំណាចនៃកម្មជាអបរាបរវេទនីយ៍ បាន

បន្ទោះឧតាសកាលណា ក៏ឲ្យផលកាលនោះ ។

ដែលថាព្រះអរហន្តលះបុណ្យនិងបាបបាននោះ សំដៅយកបុណ្យនិងបាបដែលខ្លួនធ្វើក្នុងជាតិបានសម្រេចព្រះអរហត្ត កើតជាអង្គព្រះអរហន្តហើយបាបនិងបុណ្យមិនបានតាមទៅឲ្យផលក្នុងព្រះនិព្វានទេ ហេតុនោះបានជាថា អបុញ្ញាបច្ច័យនៃព្រះអរហន្តគ្មានទេ ។

អបុញ្ញាបច្ច័យកថា ចប់ ។

## សញ្ញាវេទយិតនិរោធកថា

លំដាប់នេះ និងវិសជ្ជនាក្នុងសញ្ញាវេទយិតនិរោធកថា ដោយពាក្យជាសកវាទី បរវាទី ដូចសេចក្ដីតទៅនេះ ៖

សកវាទី- សញ្ញាវេទយិតនិរោធសមាបត្តិ ជាលោកិយឬជាលោកុត្តរៈ ?

បរវាទី- ជាលោកុត្តរៈ ។ អ្នកកុំចូលចិត្តថា សញ្ញាវេទយិតនិរោធសមាបត្តិជាលោកិយ ព្រោះថាបុគ្គលអ្នកចូលនិរោធសមាបត្តិបាននោះ ចំពោះតែបុគ្គលបានសម្រេចព្រះអរហត្ត និងបុគ្គលបានសម្រេចព្រះអនាគាមីពួកនេះប៉ុណ្ណោះ ។ ឯការដែលបានធ្វើសក្ការបូជាឬប្រគេនទូសក៏យដល់ព្រះអរិយបុគ្គលអ្នកចូលនិរោធសមាបត្តិ និងចេញពីនិរោធសមាបត្តិវិញនោះ ក៏បានសោយផលនៃកុសលនិងអកុសលនោះជាទិដ្ឋធម្មវេទនីយ៍

បានសោយផលឃើញជាក់ស្តែងក្នុងកាលជាបច្ចុប្បន្ន ដូចកាលពីស្មើយ បុរសជាមនុស្សកំសត់ទុគ៌ត ក៏យោបានប្រគេនបង្អាន់បិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរដែលចេញពីនិរោធសមាបត្តិ ខ្លួនត្រេកអរណាស់ ពុំមានពោមនស្សសោះ ព្រោះភោជនាហារនោះ ក៏យោយកមកបម្រុងឲ្យខ្លួនបរិភោគ ហើយបែរជាប្រគេនទៅព្រះមហាកស្សបត្ថេរវិញ បានសោយផលជាទិដ្ឋធម្មវេទនីយកម្ម ព្រះមហាក្សត្រទ្រង់ព្រះមេត្តាប្រោសព្រះរាជទាននាទីឲ្យធ្វើជាមហាសេដ្ឋី ។

ឯបុគ្គលអ្នកប្រទូស្តក៏យដល់ព្រះអរិយជាម្ចាស់ដែលចូលនិរោធសមាបត្តិ បានសោយផលនៃអកុសលជាទិដ្ឋធម្មវេទនីយ៍នោះ ដូចនន្ទយក្ស ប្រទូស្តក៏យដល់ព្រះសារីបុត្តត្ថេរ ដែលគង់នៅក្នុងទីអព្ភោកាសចូលនិរោធសមាបត្តិ ។ នន្ទយក្សប្រហារព្រះសិរនៃព្រះថេរៈ បំណងនឹងឲ្យបែកធ្លាយ ។ តាមការពិត ព្រះអរិយជាម្ចាស់ទាំងឡាយ ដែលចូលនិរោធសមាបត្តិ សូម្បីបុគ្គលកាប់នឹងដាវ ចាក់នឹងលំពែង ឬ ដែកស្រួច បាញ់នឹងធ្នូ ស្នាកាំភ្លើង នឹងគ្រឿងសស្ត្រាវុធអ្វី ៗ ក្តី សរីរឥន្ទ្រិយរបស់លោក នឹងបានដាច់ដាចធ្លុះធ្លាយ បែកបាក់បន្តិចបន្តួចកំឥតអង្គឹមានសោះឡើយ សូម្បីតែឈើចាប់បន្តិចបន្តួចប៉ុនសរសៃរោមមួយប៉ុណ្ណោះ ក៏គ្មានឈើចាប់ដែរ ឯនន្ទយក្សនោះ លុះប្រទូស្តក៏យដល់ព្រះធម្មសេនាបតីសារីបុត្រ

រួចហើយក៏ធ្លាក់ចុះមកលើប្រថពី ។ ស្រុបចុះទៅកន្លែងអវិចិមហានរក ហេតុតែប្រទូស្តរ៉ាយដល់ព្រះអរិយជាម្ចាស់ ដែលកំពុងចូលនិរោធសមាបត្តិ ។

សកវាទី- បុគ្គលដែលបានសម្រេចព្រះអរហត្តហើយនោះ ខ្លួនស្លាប់ដែរឬមិនខ្លាចទេ ?

បរវាទី- ន កាយតិ បុគ្គលដែលបានសម្រេចព្រះអរហត្តហើយនោះ មិនខ្លាចស្លាប់ទេ ។

សកវាទី- ដូចជាយើងបានឮមកថា បឋមពោធិយំ កន្លងកាលសម្តេចព្រះបរមសាស្តាបានត្រាស់ដឹងជាដំបូងថ្មីៗនោះ មនុស្សទាំងឡាយបបួលគ្នានាំលាភសក្ការៈដ៏ច្រើនមកបូជាកន្លែងព្រះពុទ្ធសាសនា ពាល់តែពួកអន្យតិរ្ថិយសាបសូន្យបាត់លាភសក្ការៈ ។ ទើបពួកអន្យតិរ្ថិយនាំគ្នាចូលទៅកន្លែងស្ងាត់គិតគានប្រឹក្សាគ្នាថា ភោ ជាជាម ពួកយើងដឹងឬទេ? ។ មានអន្យតិរ្ថិយមួយពួកឆ្លើយថា ជាជាម យើងដឹងថាលាភសក្ការៈនេះកើតមានដល់ព្រះសមណគោតម ព្រោះអាស្រ័យតែព្រះមហាមោគ្គល្លានទេវលោកា គន្តា ព្រះមហាមោគ្គល្លាននោះទៅឯទេវលោក សួរអំពីកុសលដែលទេវបុត្រទេពធីតាទាំងឡាយធ្វើ លុះទេវបុត្រទេពធីតាទាំងនោះប្រាប់ឲ្យដឹងហើយ ក៏នាំពាក្យនោះមកប្រាប់មនុស្សទាំងឡាយថា ឯវរូបំ កាត្វា ទេវបុត្រឈ្មោះនេះ ទេពធីតាឈ្មោះនេះ កាលទៅ

ក្នុងមនុស្សលោក កើតក្នុងស្រុកនោះ ជនបទនោះបានធ្វើកងការកុសលយ៉ាងនេះ ៗ លុះអស់ជីវិតហើយបានទៅកើតក្នុងស្ថានសួគ៌ បានសោយទិព្យសម្បត្តិយ៉ាងនោះ ៗ មានបរិវារចំនួនប៉ុណ្ណោះ ៗ ។

ប្រការមួយទៀត ព្រះមហាមោគ្គល្លាននោះទៅឯស្ថាននរកហើយ សួរអំពីអកុសលកម្មដែលសត្វនរកធ្វើ ដឹងហើយនាំនាំពាក្យសត្វនរកនោះយកមកប្រាប់ពួកមនុស្សថា ឯវរូបំ កត្វា សត្វនរកឈ្មោះនោះ ៗ បានសោយទុក្ខវេទនាក្នុងនរកនោះយ៉ាងនេះៗ ព្រោះហេតុកាលខ្លួននៅក្នុងមនុស្សលោកនេះ បានធ្វើអំពើអកុសលយ៉ាងនោះៗ ។

តស្ស កថំ សុត្វា មនុស្សទាំងឡាយបានស្តាប់ពាក្យនៃព្រះមហាមោគ្គល្លាននោះប្រាប់នូវកម្មផ្សេង ៗ ក៏នាំយកលាភសក្ការៈមកធ្វើបុណ្យ បំពេញចីវរទានជាដើមដល់ព្រះសមណគោតម ដោយហេតុបានស្តាប់ពាក្យនៃព្រះមហាមោគ្គល្លាន បើពួកយើងសម្លាប់ព្រះមហា-មោគ្គល្លានឲ្យស្លាប់បាត់ទៅហើយ លាភសក្ការៈនៃព្រះសមណគោតមក៏មុខជាសាបសូន្យអស់ទៅ ត្រឡប់ជាកើតលាភសក្ការៈដល់ពួកយើងវិញ ។ អញ្ញតិរ្ថិយ៍ទាំងឡាយយល់ព្រមគ្នាថា ឧបាយនេះនឹងនាំឲ្យបានសម្រេចប្រយោជន៍ ញុំាងលាភសក្ការៈឲ្យកើតឡើងបាន ។

សន្និដ្ឋានំ កត្វា លុះសម្រេចចិត្តគ្រប់គ្នាដូច្នេះហើយ ក៏បបួល

ជនទាំងឡាយដែលជាឧបដ្ឋាក ឲ្យប្រាក់បានមួយពាន់កហាបណៈហើយ មករកចោរទាំងឡាយ ឲ្យប្រាក់មួយពាន់នោះទៅពួកចោរ ប្រើពួកចោរឲ្យទៅសម្លាប់ព្រះមហាមោគ្គល្លាន ៗ សម្បដិច្ឆិត្វា ពួកចោរទទួលពាក្យអនុត្តរិយ៍ហើយ ទៅព័ទ្ធកុដិព្រះមហាមោគ្គល្លាន ៗ ក៏ជ្រាបថាពួកចោរមកព័ទ្ធកុដិគេចចេញទៅតាមចន្លោះខ្ទប ពួកចោររកលោកមិនឃើញនាំគ្នាវិលទៅផ្ទះវិញ លុះដល់ថ្ងៃគំរប់ពីរនាំគ្នាមកព័ទ្ធកុដិម្តងទៀត ៗ ព្រះមហាមោគ្គល្លានត្រូវគេចចេញទៅតាមហោជាង ៗ

កាលបើមានរឿងយ៉ាងនេះ ទីងថាព្រះអរហន្តមិនខ្លាចស្លាប់ដូចម្តេចកើត បើមិនខ្លាចស្លាប់ហើយ មុខជាមិនគេចវេះទៅណា មុខជានៅឲ្យចោរសម្លាប់មិនខានឡើយ ៗ ហេតុនេះ យើងយល់ឃើញថាព្រះអរហន្តខ្លាចស្លាប់ទីងខ្លាចអាជ្ញា ៗ

បរវាទី- អរហា ឆាម ឈ្មោះថាបុគ្គលអ្នកបានសម្រេចអរហត្តហើយនោះ មិនខ្លាចស្លាប់ទេ សមតាមពាក្យក្នុងព្រះសូត្រមួយ សម្តេចព្រះបរមសាស្តាត្រាស់ទេសនាទុកថា សព្វេ សន្តា តសន្តិ សត្វទាំងឡាយទាំងពួងរមែងខ្លាចអំពីមរណភ័យ គឺខ្លាចស្លាប់ទីងខ្លាចអាជ្ញា ចត្តារោ ឋបេត្វា វៀរលែងតែសត្វបួនជំពូក គឺដំរីអាជានេយ្យ ១ សេះអាជានេយ្យ ១ គោឧសភរាជអាជានេយ្យ ១ ព្រះខីណាស្រព ១

គ្រប់ជាប្អូនជំពូក ៗ

សត្វបីជំពូកនេះគឺ ដំរីអាជានេយ្យ ១ សេះអាជានេយ្យ ១ គោអាជានេយ្យ ១ បានជាមិនខ្លាចស្លាប់នោះ ព្រោះហេតុមិនបានឃើញថា សត្វពួកណានឹងហ៊ានមកជាសត្រូវនឹងខ្លួនសោះ សុទ្ធតែខ្លាចខ្លួន ៗ

ចំណែកព្រះខីណាស្រពទាំងឡាយ មិនខ្លាចស្លាប់នោះ ព្រោះហេតុយល់ឃើញថា គ្មានសត្វណាមិនស្លាប់ទេ សុទ្ធតែស្លាប់ដូចគ្នាទាំងអស់ ៗ បើនឹងថាព្រះអរហន្តខ្លាចសេចក្ដីស្លាប់ ឃើញថាខុសក្រសែព្រះពុទ្ធដីកា; ដែលព្រះមហាមោគ្គល្លានគេចរត់ទៅនោះ ព្រោះលោកពុំបានពិចារណា លុះលោកពិចារណាឃើញហើយ ក៏លែងរត់ មកនៅចាំឲ្យចោរចាប់វាយប្រហារ ៗ ព្រះមហាមោគ្គល្លាននេះមានឫទ្ធិច្រើនណាស់ លោកចង់សំដែងឫទ្ធិយ៉ាងណា ៗ ក៏បានសម្រេចតាមសេចក្ដីប្រាថ្នាគ្រប់ប្រការ បើលោកតដៃនឹងពួកចោរ ៗ វាយលោកមិនបានទេ ព្រះមហាថេរមិនបានតបតនឹងពួកចោរសោះ លោកបណ្ដោយឲ្យពួកចោរវាយតាមចិត្ត ហេតុតែលោកមិនខ្លាចស្លាប់ ៗ អ្នកប្រាជ្ញទាំងឡាយគប្បីសន្និដ្ឋានថា ព្រះអរហន្តទាំងឡាយមិនបានខ្លាចសេចក្ដីស្លាប់ដោយន័យដូច្នេះ ៗ

សញ្ញាវេទយិតនិរោធកថា ចប់ ។

អសុចិសុក្កវិសដ្ឋិកថា

នត្ថិ អរហតោ អសុចិសុក្កវិសុដ្ឋីតិ អាមន្តា អត្ថិ អសុចិសុក្កវិសដ្ឋិ មារកាយិកានំ ទេវតានន្តិ នហេវំ វត្តព្វេ ។ មារកាយិកានំ ទេវតានំ នត្ថីតិ នោ វត្តរេ មារកាយិកា ទេវតា ឧបសំហរន្តីតិ ។

*ពាក្យនេះ ទីងវិសជ្ជនាក្នុងអសុចិសុក្កវិសដ្ឋិកថាតទៅ គាំងជាសកវាទី បរវាទីដូច្នេះ៖*

*សកវាទី- អសុចិសុក្កវិសដ្ឋិ ប្រែថា ការបញ្ចេញទឹកអសុចិជាសុក្កនៃព្រះអរហន្ត ដែលអស់អាសវៈហើយ មានដែរឬទេ?*

*បរវាទី- គ្មានទេ, ព្រះអរហន្តទាំងឡាយដែលអស់អាសវៈហើយ លោកមិនបញ្ចេញទឹកអសុចិជាសុក្កៈនោះឡើយ ។*

*សកវាទី- បើជាគ្មានដូច្នោះ ចុះហេតុដូចម្តេច ភិក្ខុទាំងពួងដែលចូលទៅនៅក្នុងដងព្រៃបានសម្រេចព្រះអរហត្តហើយ នៅតែបញ្ចេញទឹកអសុចិសុក្កៈ ទាល់តែសម្តេចព្រះបរមសាស្តាទ្រង់បញ្ញត្តសិក្ខាបទ ដូចមានសេចក្តីនៅក្នុងសិក្ខាបទបញ្ញត្តស្រាប់ ពាក្យដែលអ្នកថាព្រះអរិយបុគ្គលបានសម្រេចព្រះអរហត្តហើយ មិនបញ្ចេញទឹកអសុចិសុក្កៈនោះ យើងនៅមិនទាន់ជឿទេ បើលោកអស់អាសវៈហើយមិនបញ្ចេញទឹកអសុចិសុក្កៈនោះ ចុះហេតុអ្វីបានជាសម្តេចព្រះសុគតទ្រង់បញ្ញត្តសិក្ខាបទ ។*

(នៅមានត)

# មធុរសវាហិណី

## សម្ដេចព្រះធម្មលិខិត លី-ឯម ប្រែរៀបរៀង

(តមក)

---

ឯនាងទេពធីតានោះ បានសោយសិរីសម្បត្តិក្នុងស្ថានសួគ៌នោះ ជាសុខដ៏ប្រសើរដរាបរៀងមក តែងអន្ទោលទៅមក តែក្នុងសុគតិភពពុំដែលធ្លាក់ទៅកើតក្នុងទុគ្គតិភពឡើយ តែងសោយសុខតែក្នុងស្ថានមនុស្សលោកនិងទេវលោក កន្លងទៅ ៩១ កប្ប រាប់អំពីកប្បយើងនេះថយក្រោយ, លុះដល់មកក្នុងកាលព្រះមានព្រះភាគជាម្ចាស់នៃយើង នាងទេពធីតានោះក៏បានច្យុតចុះមកចាប់បដិសន្ធិក្នុងផ្ទៃនាងព្រាហ្មណី ជាភរិយារបស់ជេដ្ឋព្រាហ្មណ៍ ជាត្រកូលដ៏ខ្ពង់ខ្ពស់ ក្នុងទេវបុត្រនគរឰដ៏ជម្ពូទ្វីបនេះឯង ។ នាងបានអាស្រ័យនៅក្នុងផ្ទៃមាតាគ្រប់ខែដប់បរិបូណ៌ហើយ ក៏កើតចេញអំពីផ្ទៃមាតាមកដោយសួស្តីឥតមានភ័យអន្តរាយអ្វីឡើយ ។

ចាប់ដើមតាំងតែអំពីនាងធីតានោះកើតចេញចាកផ្ទៃនៃមាតាហើយ មានអង្ករស្រូវសាលីសុទ្ធប្រមាណ ៨ នាឡិ ១ កើតឡើងសម្រាប់នាងសព្វ ១ ថ្ងៃ ពុំដែលដាច់ឡើយ ។ ដោយផលានិសង្សដែលនាងបានថ្វាយបង្អែមព្រមទាំងភេសជ្ជៈដល់ភិក្ខុអ្នកមានជម្ងឺ ក្នុងសាសនាព្រះពុទ្ធវិបស្សីនោះឯង ។

ឯមាតាបិតាលុះបានឃើញរូបសម្បត្តិនាងធីតានោះហើយ ទើបសន្មតនាមថានាង «រូបទេវី» ព្រោះមានរូបឆោមមានលំអគួរជាទីត្រេកអរដល់ប្រជុំជននានា ។

លុះកាលជាខាងក្រោយ នាងធីតាចំរើនវ័យធំឡើង បានអាយុប្រមាណ ១៥ ឬ ១៦ ឆ្នាំ មាតាបិតាព្រមទាំងញាតិសាច់សាលោហិតទាំងឡាយ បានរៀបចំធ្វើមង្គលអាពាហ៍ពិពាហ៍ជាមួយនឹងយុវបុរសដទៃមានត្រកូលស្មើគ្នា ហើយបញ្ជូនឲ្យទៅនៅក្នុងត្រកូលស្វាមីរបស់នាង ។ កាលបើធីតានោះបានកើបយកអង្ករមួយនាឡិហើយ ប្រុងប្រៀបនឹងចំអិនបាយ ស្រាប់តែមានម្ហូបគ្រឿងជាច្រើនមុខ គឺត្រីនិងសាច់ជាដើមផង គោរសទាំងប្រាំមានសប្បិ ខ្វនីត ទធិ និងទឹកដោះស្រស់ជាដើមផង គ្រឿងហិលមានជីរនិងម្រេចជាដើមផង គ្រឿងឧបករណ៍មានស្ករបេកទឹកឃ្មុំនិងស្ករអំពៅជាដើមផង សឹងបំពេញភាជន៍ទាំងឡាយឲ្យពេញកើតឡើងព្រមគ្នាជាទីអស្ចារ្យ ដោយផលានិសង្សដែលនាងបានថ្វាយអាហារព្រមទាំងភេសជ្ជៈនោះឯង ។ វត្ថុសម្រាប់បរិភោគ ទោះបីបន្ថែមក្តី បំអាបក្តី សូម្បីបន្តិចបន្តួចដែលនាងធីតានោះ បានកាន់យកដោយដៃរបស់ខ្លួនហើយ វត្ថុទាំងនោះពុំដែលប្រែទៅជាវត្ថុរប្អូមឡើយ សឹងនៅគង់កំណត់ជាប្រក្រតីដដែល ។

កាលបើនាងរូបទេវីបានដាំបាយមួយឆ្នាំងហើយ ដោះបាយនោះចែកឲ្យមនុស្សដែលនៅក្នុងនគរទាំងមូល ឲ្យបរិភោគដកបដល់ឆ្អែតកល់គ្នា តែនាងពុំទាន់ដាក់ដៃបេញដកបណា បាយក្នុងឆ្នាំងក៏គង់នៅពេញឆ្នាំងដដែលដកបនោះ ។ កិត្តិស័ព្ទរបស់នាងរូបទេវីនោះ ក៏ល្បីឮសុសសាយប្រាកដក្នុងទេវបុត្រនគរទាំងអស់ បីដូចជាព្រះចន្ទនិងព្រះអាទិត្យរះឡើងក្នុងលោកដូច្នោះឯង ។

ឯនាងរូបទេវីនោះសោត តែងនិមន្តភិក្ខុប្រាំអង្គទៅឆាន់ចង្ហាន់ ក្នុងទីលំនៅរបស់នាងអស់កាលជានិច្ច ពុំដែលដាច់ឡើយ ។

គ្រានោះ មានព្រះថេរៈមួយអង្គ មាននាមជាព្រះមហាសង្ឃរក្ខិត ក្នុងចំណោមភិក្ខុទាំងឡាយ លោកបែកធ្លាយនូវបដិសម្ភិទាទាំងបួន លោកបានឃើញនូវបុញ្ញានុភាពនៃនាងរូបទេវីនោះ ដោយទិព្វចក្ខុរបស់ខ្លួន ឯនាងធីតានេះពុំបានដឹងនូវបុញ្ញកម្ម ដែលខ្លួនបានធ្វើមកក្នុងកាលមុនឡើយ ។

ព្រះថេរៈនោះត្រិះរិះថា បើដូច្នេះត្រូវតែអាត្មាអញប្រកាសប្រាប់នូវបុញ្ញកម្មនោះដល់នាងធីតានេះ ឲ្យបានដឹងសព្វគ្រប់ទើបគួរ ។

ឃគាធិរសិំ មានសម័យថ្ងៃមួយព្រះថេរៈឆាន់ចង្ហាន់ក្នុងទីលំនៅរបស់នាងធីតានោះរួចស្រេច បានធ្វើអនុមោទនាកថាហើយក៏សួរថា ម្នាលឧបាសិកា! នាងបានដឹងនូវបុញ្ញកម្មដែលនាងបានធ្វើមក ក្នុងកាលមុនដែរឬទេ ? ។

នាងពីតាទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ! ខ្ញុំម្ចាស់ពុំបានដឹងទេ តែ ថាខ្ញុំម្ចាស់មានប្រាថ្នាចង់ស្តាប់ នូវបុញ្ញកម្មនោះដោយពិស្តារតទៅទៀត ។

ឯព្រះមហាសង្ឃរក្ខិតត្ថេរ កាលដែលលោកនឹងប្រកាសសំដែងនូវ បុព្វកម្មនៃនាងរូបទេវីនោះ ក៏បានពោលជាបទព្រះគាថាដូច្នេះថា:

ឯកនវុតិ ឥតោ កប្បេ វិបស្សី នាម នាយកោ
អហោសិ លោកេ លោក- ការកយោ ចិន្តព្វោ
.. ជាដើម

សេចក្តីថា: ក្នុងកប្បកៅសិបមួយ រាប់អំពីកប្បនេះថយក្រោយ មានព្រះសម្មាសម្ពុទ្ធមួយព្រះអង្គទ្រង់ព្រះនាមវិបស្សី ជានាយក ក្នុងលោក ព្រះអង្គបានកាត់ចំណងជាគ្រឿងចងក្នុងភពដាច់ស្រឡះហើយ ទ្រង់ប្រទាន នូវព្រះនេត្រដ៏ប្រសើរពោលគឺប្រាជ្ញា ដល់សត្វនិករក្នុងត្រៃលោក, កាល នោះនាងបានកើតជាគាមទារិកាម្នាក់នៅក្នុងបុរីនោះដែរ ។ ថ្ងៃមួយនាងបាន ដើរចូលទៅកាន់ព្រះវិហារ ក៏ឃើញនូវសាវក ១ អង្គរបស់ព្រះជិនស្រី មាន រោគជាទម្ងន់ មានសម្បុរលឿងស្លាំងស្លម ថយកំឡាំង នាងមានចិត្ត អនុគ្រោះបាននិមន្តទៅប្រគេនភេសជ្ជៈនឹងភត្តដល់សាវកនោះ លុះភិក្ខុនោះ បានឆាន់ភេសជ្ជៈនោះហើយ សេចក្តីទុក្ខដែលកើតពីជម្ងឺបៀតបៀនកាយ ក៏រសាយរលាយបាត់ទៅ ប្រែជាមានសរីរកាយធាត់ធំមាំមួនជាប្រក្រតីវិញ ដោយបុញ្ញកម្មនោះ ទើបនាងច្យុតចាកអត្តភាពនោះបានឡើងទៅកើតក្នុង

សោតាបត្តិផលជាអរិយសាវិកា ក្នុងព្រះពុទ្ធសាសនាដោយពិត ៗ

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយលោកពោលជាបទព្រះគាថាដូច្នេះថា:

ឥតិ តរុណកុមារី បុញ្ញមាគាកិញ្ញាតា
បមុទិតមនចិត្តា តស្ស ឧត្វាន ឆាដំ
អរិករសុចំ សា លទ្ធអម្ហេសុ បុញ្ញ
វិធិតកុសលធាតា លច្ឆជ កោ នុ តុម្ហេ ៗ

អធិប្បាយថា តរុណកុមារី (កុមារីពេញជំទង់) បានកំណត់ដឹងថា អាត្មាអញបានធ្វើបុណ្យ ហើយក៏មានចិត្តរីករាយ ព្រោះបានឲ្យកេសបដ្ឋ-ទានដល់ភិក្ខុអ្នកមានធម៌ ដូចបានពណ៌នាហើយនេះ កុមារីនោះបានសោយសេចក្ដីសុខក្នុងភពតូចធំជាលំដាប់ ដរាបដល់ព្រះនិព្វាន ៗ ម្នាលអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយក្នុងចំណោមនេះ សុទ្ធតែជាអ្នកមានបុណ្យ មានកុសលដែលបានដឹងច្បាស់ហើយ មុខជានឹងបានទូវព្រះនិព្វានដោយពិត ៗ

សំដែងរឿងនិទាននាងរូបទេវី ជាគំរប់ ១០ ក្នុងវគ្គទីមួយ ក៏ចប់សេចក្ដីដោយសង្ខេបតែប៉ុណ្ណោះឯង ៗ

ចប់ធម្មសោណ្ឌកវគ្គទី ១

ស្ថានសួគ៌ទេវលោកនាយ បានសោយសម្បត្តិទិព្វ សម្រេចដោយកាមគុណទាំងពួង ជាសុខក្សេមក្សាន្ត ស្ថិតនៅក្នុងប្រាសាទកែវ ៧ ប្រការ ប្រដាប់ដោយគ្រឿងកែវមណីប្រមាណមួយរយជាន់ មានផ្ទះកំពូលដ៏វិចិត្រ ដោយវល្លិ៍មួយរយមួយ មានទីដេកទីអង្គុយដ៏ដេរដាសទៅដោយស្រីទេព-អប្សរកែងប្រកបបម្រើ មានភំទឹងគ្រឿងជាដើមជាប្រក្រតី ៗ ដោយផលានិសង្សដែលនាងបានឲ្យភេសជ្ជទានដល់ភិក្ខុមានជម្ងឺនោះឯង ៗ

សេចក្ដីពិតថា បុគ្គលដែលប្រាថ្នាចង់បាននសេចក្ដីសុខគប្បីខំធ្វើនូវបុណ្យគ្រប់កាលទាំងពួង ៗ ម្នាលនាងដ៏ចំរើន ! ព្រោះហេតុដូច្នេះ ត្រូវតែនាងខ្វល់ខ្វាយក្នុងការជាកុសលសព្វ ៗ កាល កុំឲ្យដាច់ឡើយ ៗ

ព្រះមហាសង្ឃត្ថេរ លោកបានប្រកាសសំដែងនូវបុព្វកម្មដែលនាងរូបទេវីនោះ បានធ្វើពីកាលមុនមកយ៉ាងនេះហើយ ក៏លោករំឭកដាស់តឿនថា ឥឡូវនេះត្រូវនាងកុំប្រមាទប្រហែសធ្វេស ក្នុងបុញ្ញកម្មឡើយ ៗ

ឯនាងរូបទេវី លុះបានស្ដាប់ព្រះធម៌ទេសនានៃព្រះថេរៈហើយ ក៏មានសេចក្ដីសោមនស្សដ៏ក្រៃលែង តែងខ្វល់ខ្វាយចំណាយទ្រព្យធ្វើបុណ្យមានការបរិច្ចាគទានជាដើម តាំងពីថ្ងៃនោះមកជាដរាប ៗ ដោយសេចក្ដីសោមនស្សដែលនាងបានស្ដាប់ព្រះធម៌ទេសនានោះហើយ ក៏បានដល់នូវខយវយធម៌ (ការអស់ទៅនិងសូន្យទៅ) ក្នុងអត្តភាព បានសម្រេច

ពីនាយ ប្រណម្យមកថ្វាយព្រះអគ្គីហោង ។ ថាបើព្រះអគ្គីនឹងនាំស្រះញីទៅពុំបានឡើយ ក៏យើងខ្ញុំនឹងនាំស្រះឈ្មោលមកពុំបានដែរ ដូចព្រះអគ្គីនោះហោង ។

រីអស់មហាជនធនទាំងឡាយ ស្តាប់ពាក្យព្រះមហោសថបង្គាប់ប្រើហើយ ចាំអស់ឥតសំណល់ដំកល់ទុកក្នុងចិត្តស្រេចហើយ ក្រាបលាព្រះមហោសថ ទៅធ្វើដូចបង្គាប់នោះហោង ។

រីព្រះមហាក្សត្រាធិរាជស្តាប់ហើយ មានព្រះបន្ទូលដណ្តឹងថា ម្នាលអ្នកទាំងឡាយអើយ អ្នកឯណាមានប្រាជ្ញាអាចរិះគិតជាអាថ៌ប្រស្នាតបមកដូច្នោះហ្ន៎ ។ រីអ្នកផងទាំងឡាយ បង្គំប្រណម្យទូលថា សូមទានព្រះមហោសថជាបុត្រសិរីវឌ្ឍកសេដ្ឋីនោះឯង ប្រើយើងខ្ញុំមកធ្វើជាអាថ៌ប្រស្នាតបទឹងព្រះអគ្គីហោង ។ ព្រះមហាក្សត្រាធិរាជជ្រាបហើយ មានព្រះហឫទ័យដ៏ពេញនូវព្រះអំណរអរក្រៃពេកហោង ។

ឧយ្យានឆត្តិ នេះទឹងស្រដីពីការលេងឧទ្យាននោះវិញ ។

បុនេកាធិវសំ មយំ ឧយ្យានគាមិទ្យំ កាមិទ្យុតុកាមោ អម្ហាកញ្ច ឧយ្យានំ ចោរភណារុក្ខា ឱកក្តិវិកក្តំ ចាច៌· ឆយវមជ្ឈគាមភសិនោ សុបុប្ផិតតរុណរុក្ខាសញ្ឆន្នំ ឆវឧយ្យានំ បេសេន្តុ អបេសេន្តានំ សហស្សទណ្ឌោតិ

# មហោសថជាតក

(តមក)

លោក អ៊ឹម.ភន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-តូរ ពិនិត្យ

---

ហេតុនោះ សូមពានយើងខ្ញុំមកក្រាបទូលព្រះអង្គចង់សូមស្រះញី អំពីបុកណា ដ្បិតធ្លាប់នៅស្គាល់ថ្មឹកមិនក្អឹកមិនខ្លាចនឹងមនុស្សម្នាមហាជន ផងទាំងឡាយ ហើយសូមឲ្យនាំទៅជាគ្នាក់ យើងខ្ញុំនឹងកៀងនាំស្រះ យើងនោះមកឲ្យជាកំដរស្រុកជាមួយនឹងស្រះញីព្រះអង្គហោង, ថាបើព្រះ មហាក្សត្រមានព្រះបន្ទូលមកនឹងអ្នកទាំងឡាយថា នៃព្រះស្ដែង ! អំពីមុន រៀងមក អញមិនដែលឮថា ស្រះមានញីមានឈ្មោលឡើយ, ហើយ អញពុំដែលបានប្រើស្រះញីឲ្យទៅយកស្រះឈ្មោល អន្ទូងមកជួបព្រះ ស្ដែងស្រដីនោះឡើយ ម្ល៉ោះហើយអ្នកទាំងឡាយក្រាបថ្វាយបង្គំប្រណម្យ ទូលឆ្លើយវិញថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ៚ បើព្រះ អង្គមានព្រះបន្ទូលថា មិនដែលមានដូច្នោះហើយ ហេតុអ្វីឡើយព្រះអង្គ ប្រើទៅកាន់សិរីវឌ្ឍកសេដ្ឋី ប្រើឲ្យនាំស្រះមកថ្វាយព្រះអង្គ ? លុះព្រះអង្គ ឲ្យនាំស្រះញីអំពីកាយទៅនោះ ទើបបានយើងខ្ញុំងាយនឹងនាំស្រះឈ្មោល

បហាណឹសុ ។

មានកាលសម័យថ្ងៃមួយវិញទៀត, ព្រះមហាក្សត្រាធិរាជ ស្តេចនឹកចង់ល្បងប្រាជ្ញាព្រះមហោសថ ទើបស្តេចប្រើរាជអាមាត្យទៅថានឹងសិរីវឌ្ឍកសេដ្ឋីនោះទៀតថា ព្រះបន្ទូលពិសេសត្រាស់ប្រើឲ្យមកថានឹងអ្នក ដ្បិតស្តេចមានព្រះបំណងនឹកចង់ក្រសាលប្រពាតឧទ្យាន នាឧទ្យានព្រះមហាក្សត្រាធិរាជអំពីបុណ្ណោះ, មានឈើចាស់បាក់បែក ស្លឹកជ្រុះមែកធ្លាក់ចុះ រង្គោះអស់ហើយ; ហេតុនោះហោង ឲ្យអ្នកនាំឧទ្យានថ្មីឲ្យមានឈើនោះកម្លោះខ្ចី មានដើមនោះធំ លំពង់ ទ្រង់នូវផ្កាដុះរីកស្រស់ស្គាយពណ្ណរាយល្អនាំទៅថ្វាយ, ថាបើអ្នកនាំឧទ្យាននោះទៅថ្វាយបានក៏ជាការឥតទោសឡើយ, ថាបើពុំបាននាំឧទ្យានថ្មីនោះទៅថ្វាយហើយសមអ្នកនឹងមានទោសត្រូវរាជទណ្ឌ ជាដំណាំងមួយពាន់ដងពុំខានឡើយ ។

រីសិរីវឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកផងទាំងឡាយ សឹងទៅដណ្តឹងសួរព្រះមហោសថនោះហោង, ទើបព្រះមហាសត្វអ្នកទ្រង់ព្រះពិចារណាអាថិប្រស្នានេះថា បើដូច្នេះមានតែរិះគិតធ្វើជាអាថិប្រស្នាតបទៅវិញទើបបាន, ទើបពោធិសត្វប្រើអ្នកផងទាំងឡាយ ឲ្យទៅរិះគិតធ្វើជាអាថិប្រស្នាតបទៅវិញ ដូចន័យនៃពាក្យដែលយើងស្រដីនិយាយអាថិប្រស្នានោះឯងហោង ។

។ព្រះមហាក្សត្រាធិរាជ ស្ដេចជ្រាបជាបអស់អាថិសេចក្ដីនោះហើយ ទើបមានព្រះហឫទ័យដ៏ពេញទូវព្រះអំណរអរក្រៃពេកហោង ៗ ហើយ មានព្រះបន្ទូលដណ្ដឹងទៅកាន់អាចារ្យសេនកថា អើអាចារ្យសេនកអើយ បើដូច្នោះ សមគួរយើងនឹងឲ្យទៅនាំមហោសថនោះ មកជាអ្នកប្រាជ្ញ ឬដូចម្ដេចហ្ន៎ ? ។អាចារ្យសេនកស្ដាប់ព្រះបន្ទូលព្រះមហាក្សត្រនូវប្រការអម្បាលនោះហើយ ហេតុតែជាអ្នកកំណាញ់យសលាភសក្ការៈនោះម៉ិញ ទូលតាស់ព្រះមហាក្សត្រាធិរាជថា មហារាជ ! បពិត្រមហារាជអើយ ។មហោសថបុត្រគហបតីនោះ បេះអាចប្រស្នាអម្បាលនោះម៉ិញ មិនហៅថាអ្នកប្រាជ្ញឡើយ, ចូរព្រះអង្គឈប់ស្ទះទៅនេះសិនហោង ៗ

។ព្រះមហាក្សត្រ ស្ដាប់ពាក្យអាចារ្យសេនកនូវប្រការអម្បាលនោះហើយ ស្ដេចទ្រង់ព្រះចិន្ដាពិចារណាថា មហោសថអ្នកប្រាជ្ញអាចឆ្លើយប្រស្នាយល់ឥតលាក់លៀមកំបាំងអំពីក្មេង ៧ ឆ្នាំដូច្នេះ បេះមានចិត្តគំនិតម៉ិនឲ្យខុសដល់គិចឡើយ មិនយល់ថាមហោសថជាក្មេង ៧ ឆ្នាំ មកឆ្លើយអាថ៌ប្រស្នានេះឡើយ យល់សុទ្ធសាធខាតដូចព្រះពុទ្ធបានត្រាស់ហើយ ក៏មកឆ្លើយ អាថ៌ប្រស្នាទីងអស់ទេវតា ឥន្ទព្រហ្មផងទាំងឡាយនោះ មានប្រការដូចម្ដេចម៉ិញ ? ក៏ដូច្នេះ ហេតុអ្វីអាចារ្យសេនកអ្នកប្រាជ្ញមិនអាចអរ ឲ្យអញទៅនាំមហោសថនោះមកយកជាអ្នកប្រាជ្ញហ្ន៎ ? ថាបើដូច្នេះ អញកុំជឿយតាមពាក្យអាចារ្យសេនកនេះឡើយ អញនឹង

ទៅនាំមហោសថនោះមកឯងហោង ។ ព្រះមហាក្សត្រាធិរាជ ទ្រង់ព្រះ
ចិន្តាពិចារណានូវប្រការអម្បាលនោះហើយ ស្ដេចឲ្យប្រដាប់ប្រដាដោយ
នូវព្រះដំណើរ ស្ដេចនឹងលីលាយាត្រាចេញអំពីព្រះនគរ មួយអន្លើនឹង
អស់អាមាត្យមុខមន្ត្រីសេនាបតីក្រស្ដីប្រជា មហាជនផងច្រើនជាបរិវារ
ស្ដេចត្រាច់លកណ្ដាលផ្លូវ រីឯដំណើរសេះអាជានេយ្យមង្គលនោះមិញ ជាន់
ផុងទៅក្នុងក្រហែងដី បាក់ថ្លស់គ្រេច ស្ដេចខានពុំបានទៅឡើយ ហើយ
ត្រឡប់វិលមកកាន់ប្រាសាទព្រះរាជមន្ទីរនោះវិញហោង ។

កាលនោះ, អ្នកប្រាជ្ញទាំង ៤ ឮថា ព្រះមហាក្សត្រស្ដេចខានពុំបាន
ទៅដូច្នោះហើយ សឹងនាំគ្នាឡើងទៅគាល់ ហើយធ្វើជាសួរទូល
ទូលដំណឹងថា មហារាជ ! បពិត្រព្រះសម្មតិទេពមហារាជអើយ រយើងខ្ញុំឮ
បន្តិចថា ស្ដេចលីលាយាត្រាទៅកាន់ស្រុកបាចីនយវមជ្ឈគ្រាម ប្រយោជន៍
ដើម្បីនឹងទៅនាំមហោសថបុត្រសិរីវឌ្ឍកសេដ្ឋីនោះមកពិតមែនឬអម្ចាស់ ?
ព្រះមហាក្សត្រស្ដាប់ហើយមានព្រះបន្ទូលថា ហៃអាចារ្យសេនកអើយអញ
ទៅមែនពិតឯងហោង ។ រីអាចារ្យសេនកទូលវិញថា បពិត្រមហារាជ
អើយ ម្ដេចឡើយព្រះអង្គមកធ្វើនូវអំពើឥតប្រយោជន៍អ្វីដូច្នេះ, មករំលង
ឯគំនិតយើងខ្ញុំចង់ម្យៀតវិញ យើងខ្ញុំបានទូលអម្ចាស់អំពីដើមហើយមិញ
តើ អម្ចាស់, ឲ្យព្រះអង្គឈប់ស្ងេះនៅខេះសិន បន្ទាន់អ្វីព្រះអង្គរលះ

រលំងគ្រាលចេញទៅអំពីព្រះនគរ ព្រះបាទអម្ចាស់ទើបស្តេចលីលាយាត្រាទៅជាប្រថម ក៏ដើរសេះព្រះទីនាំងមង្គលមិញ បាក់កើតជាស្កុទព្រះដំណើរដូច្នេះ ។

មានកាលសម័យថ្ងៃមួយវិញទៀត, ព្រះបាទវិទេហរាជ មួយអន្ទើទូវអាចារ្យទាំង ៤, ស្តេចបន្ទូលថា ហៃអាចារ្យសេនក ឥឡូវនេះ តើយើងនឹងឲ្យទៅយកអ្នកប្រាជ្ញនោះមកបុដូចម្តេចហ្នឹង ? អាចារ្យសេនកទូលថា មហារាជ! បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ ព្រះអង្គអម្ចាស់កុំបីស្តេចទៅឡើយ អម្ចាស់ប្រើតែរាជទូតទៅឲ្យថានឹងទៅអ្នកប្រាជ្ញថា ហៃទៅអ្នកប្រាជ្ញអើយ យើងមកការទៅឲ្យទៅរកជើងសេះ ព្រះទីនាំងមង្គលអស្សតរយើងបាក់, ឥឡូវនេះ ចូរឲ្យសិរីវឌ្ឍកសេដ្ឋ ទូលទៅមហោសថអ្នកប្រាជ្ញរកសេះអស្សតរក្តី សេះសេដ្ឋតរក្តី ឲ្យបានសេះប្រសើរទាំង ២ នេះ ហើយឲ្យនាំទៅថ្វាយជាជំនួសសេះព្រះទីនាំងហោង, ថាបើបាននាំទៅថ្វាយនោះ ក៏ជាការឥតទោសឡើយ, ថាបើពុំបាននាំទៅថ្វាយទេ នោះនឹងឲ្យត្រូវព្រះរាជទណ្ឌជាទម្ងន់មួយពាន់ជង, យើងធ្វើជាប្រស្នាដូច្នេះហើយប្រើទៅ ព្រោះយោបីអាចមានប្រាជ្ញាដឹងក្នុងលក្ខណៈអាថ៌ប្រស្នានេះ ថាឲ្យជូនសេះអស្សតរនេះមក ឬក៏អ្នកប្រាជ្ញនោះនឹងមកខ្លួនឯង, ព្រោះយោបីនឹងឲ្យសេះសេដ្ឋតរមក ឬ ក៏នឹងអាពុកមកហោង ។ ប្រស្នា

យើងនេះនឹងលុះបរិបូណ៌ហោង ។

ព្រះបាទវិទេហរាជ ទទួលយកពាក្យនោះថាគាប់ហោង, ទើបស្តេចប្រើរាជអាមាត្យនោះទៅថាទឹងសិរិវឌ្ឍកសេដ្ឋី ទូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាម មានសិរិវឌ្ឍកសេដ្ឋីឯងជាធំ មកជំនុំរិះគិតអាថ៌ប្រស្នានោះ ពុំឃើញទេឡើយ, ទើបទៅហៅព្រះមហោសថអំពីទីកំឡាល្បែងនោះមក ហើយប្រាប់អស់អាថ៌សេចក្តីនោះ ។ ព្រះមហោសថអ្នកប្រាជ្ញ ស្តាប់ពាក្យនោះហើយ អ្នកដឹងប្រាជ្ញមួយរំពេចនោះឯង ហើយអ្នកសំពះអាពុកថា បពិត្រអ្នកអាពុកអើយ កុំបីអម្ចាស់បារម្ភឡើយ ដ្បិតស្តេចមានព្រះបំណងនឹកបង់យល់អ្នកអាពុកខ្ញុំសោតហោង ។ ឥឡូវនេះ បូរអម្ចាស់អ្នកទៅមួយអន្ទើដោយពពួកសេដ្ឋីមួយពាន់ជាបរិវារ កាលណាបើអម្ចាស់ទឹងទៅនោះ កុំទៅតែដៃទទេឡើយ, បូរអម្ចាស់យកប្រអប់ចន្ទន៍ ដំពេញទូវគ្រឿងគន្ធពិដោរ ដំមានដំថ្លៃនោះមួយសែនដំឡឹងមាសទៅជាដង្វាយនៃព្រះមហាក្សត្រ ។ កាលណាបើអ្នកចូលទៅគាល់ហើយ ព្រះមហាក្សត្រសូមព្រះអង្គទឹងធ្វើប្រស្រ័យសួរទទួលអ្នកអាពុកថា រៃគហបតី ព្រះស្តេងមើលបានបង្គុយឯណាសមគួរ បូរព្រះស្តេងអង្គុយហោង ។

លំដាប់នោះ, អ្នកអាពុកមើលបានឯណាសមគួរទឹងអាត្មា បូរអម្ចាស់អង្គុយហោង ។ កាលណាបើអ្នកអាពុកអង្គុយហើយ គឺខ្ញុំទឹងទៅឯក្រោយៗ

លំដាប់នោះ, អ្នកស្ដេចមិនធ្វើប្រស្រ័យសួរទទួលមួយអន្ទើរដោយខ្ញុំហើយ អ្នកនឹងមានព្រះបន្ទូលទៅថា ហៃបាមានប្រាជ្ញា បាមើលហានបង្គុយណាសមគួរ បាអង្គុយហោង ។ លំដាប់នោះ, បើអញខ្ញុំក្រឡេកទៅអ្នកអាពុក កំអ្នកអាពុកដឹងដោយសំគាល់នោះ ហើយក៏ចូរអម្ចាស់ដោះឡើងអភិបង្គុយនោះ ចូរអម្ចាស់ថា ហៃបាមហោសថ ចូរបាមកអង្គុយនាហានអាពុកនេះហោង វិភាថប្រស្នាខ្ញុំនេះ នឹងលុះបរិបូណ៌ញដំកាលនោះហោង ។

វិសិរីវឌ្ឍកសេដ្ឋីមិញ ទទួលយកពាក្យគូននោះថាតាប់ហោង ។ ទើបប្រដាប់អាត្មាទៅមួយអន្ទើនឹងសេដ្ឋីទាំងមួយពាន់ជាបរិពារ លុះទៅដល់ទ្វារព្រះរាជវាំងហើយ ឲ្យចូលទៅក្រាបទូលដោយទូវដំណើរមកឈប់នៅទ្វារនោះហោង ។ ទើបស្ដេចបានជ្រាបហើយមានព្រះបន្ទូលថា ឲ្យសិរីវឌ្ឍកសេដ្ឋីនោះចូលទៅ, វិមហាសេដ្ឋីនោះ ទៅឈរនៅហានមួយអន្ទើ ហេតុតែស្ដេចចង់យល់ព្រះមហោសថឆាប់មិញ ស្ដេចមានព្រះបន្ទូលដណ្ដឹងថាហៃគហបតីអើយ, វិមហោសថកូនព្រះស្ដេង តើនៅឯណា ? វិមហាសេដ្ឋីទូលថា ព្រះបាទអម្ចាស់អើយ ថានឹងមកឯក្រោយខ្ញុំព្រះបាទនោះឯងហោង ។

វិព្រះបាទវិទេហរាជ ឮថាចៅមហោសថអ្នកប្រាជ្ញនឹងមកដូច្នោះក្ដី ស្ដេចមានព្រះរាជហឫទ័យត្រេកអរសោទរ ហើយមានព្រះបន្ទូលថា ហៃ

គហបតី ចូរព្រះស្ដេចទតមើលឋានបន្ទប់ឯណា សមគួរដល់ព្រះស្ដេច ចូរព្រះស្ដេចគង់ចុះហោង ៗ ឯមហាសេដ្ឋីនោះ អ្នកដឹងឋានបន្ទប់តាមសមគួរហើយ គាត់អង្គុយព្វជឋានមួយអន្ទើនោះហោង ៗ

ឯមហោសថអ្នកស្អាងព្រះអង្គផងប្រដាប់ប្រដា ដ៏មានក្មេងផងទាំងមួយពាន់ជាបរិវារ អ្នកគង់លើកដំរីដ៏ប្រដាប់ប្រសើរដ៏មានដំរៀបថ្ងៃហើយ អ្នកលីលាទ្រង់ចូលទៅក្នុងកំឡុងព្រះនគរ កំអ្នកយល់លាមួយនៅលើខ្នងក្បួ ហើយទើបអ្នកប្រើកំណោះឯណាមានកំលាំង ហើយអ្នកបង្គាប់ថា ចូរព្រះស្ដេចទៅតាមលានោះ ហើយព្រះស្ដេចឃុំមាត់វាះឲ្យខ្លាចកុំឲ្យស្រែកបានឡើយ ហើយព្រះស្ដេចនាំនឹកទ្រលកណ្ដៀតនៅចង្កេះយកមកហោង ផ្ដំកំណោះផងធ្វើដោយទូវបង្គាប់នោះ ៗ ពោធិសត្វព្រះអង្គលីលាទៅមួយអន្ទើដោយបរិវារ ចូលទៅក្នុងកំឡុងព្រះនគរ ៗ ដំណើរពោធិសត្វនោះដ៏ប្រកបទូវលំអសិរីសួស្ដីដូចសម្ដេចឥន្ទ្រាធិរាជ កំស្ដេចលីលាគង់លើពេជយន្តប្រាសាទ ដ៏មានពពួកទេវតានៅពិតពាក្រៃត្រឹង្ស ហោមរោមជាបរិវារនោះហោង ៗ

ឯអស់មហាជនផង សឹងបបួលគ្នាមកមើលពោធិសត្វនោះ ពោលឡើងកងរ ហើយមានពាក្យស្រដីសរសើរថា ខ្ញុំយើងបានឮរៀនមកនេះ ឯអ្នកនេះជាកូនសិរិវឌ្ឍកសេដ្ឋីឈ្មោះចៅមហោសថបណ្ឌិត ឮថាកាល

រត់តមកកាន់ទាំងកំណាត់ថ្នាំទិព្វ ចេញមកអំពីព្រះទ្វារព្រះវរមាតា ហើយស្រដីសំណេះសំណាលមួយអន្លើនឹងព្រះវរមាតា នាកាលថ្ងៃកើតនោះឯង ហើយថា មានប្រាជ្ញាអាចដោះអាថ៌ប្រស្នាល្បងទាំងពួងឥតឯកំបាំងបាន ឡើយ, រីអស់អ្នកផងនោះ សឹងដឹកកូនមកមើលព្រះមហោសថនោះ ដំរូបគូកូនចៅអំពីដៃពុំដឹង ពុំចេះខ្ពុតខ្ពន់ដល់តិចឡើយ ។ រីព្រះមហោសថនោះ អ្នកទៅដល់ទ្វារព្រះរាជវាំងហើយ ឲ្យអ្នកផងចូលទៅទូលព្រះមហាក្សត្រនោះហោង ។

រីព្រះមហាក្សត្រាធិរាជ ស្តេចឮពាក្យនោះហើយ ព្រះអង្គមានព្រះរាជហឫទ័យនោះ ដំពេញនូវព្រះអំណរក្រេកអរសាទរមានព្រះបន្ទូលថា ព្រះស្តែងឲ្យមហោសថចូលមកហោង ។ រីព្រះមហាសត្វអ្នកមានក្មេងផងទាំងមួយពាន់ជាបរិវារ ហែហមចោមរោមស្រេចហើយ អ្នកឡើងលើប្រាសាទព្រះរាជមន្ទីរថ្វាយបង្គំស្រេចហើយ ចិតនោញដំហានមួយអន្លើនោះហោង ។ កាលណាបើស្តេចបានយល់ព្រះមហោសថនោះហើយ មានព្រះហឫទ័យនោះដំលុះនូវសោមនស្សបន្ទូលប្រស្រ័យសួរទូល នូវព្រះបន្ទូលនោះពីរោះថា ម្នាលចៅអ្នកប្រាជ្ញអើយ, ចូរបាមើលហានបណ្ឌិយ តាមសមគួរនឹងការគ្នា ចូរបាអង្គុយហោង ។

(នៅមានត)

## ដ្ឋកាអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ បម្រុងពីសាស្ត្រាស៊ីករិត

---

ឥសីអាណិតជីតា ខ្ញែតខ្ញិតទុក អនាថអាណិតពេកក្តាត់ ៗ ឥសីប្រណី ស្រីវត្ថ ដ្បិតនាងប្រាសព្រាត់ ដូចកូនបង្កើតស្មោះស្មាន ៗ ទើបព្រះឥសី សីលសាន្ត តាក់តែងទីឋាន សមគួរហើយថ្វាយក្សត្រី ៗ នាងតែង បំរើឥសី សព្វថ្ងៃប្រក្រតី ដងទឹករកទសសារពើ ៗ ផលាផ្លែឈើ ផ្កាឈើ បេះបានទូលទេរ នាំយកមកថ្វាយឥសី ៗ តាមសមានចិត្ត ប្រណី អាសូរក្សត្រី ពុំដែលឲ្យអាក់ព្រះទ័យ ៗ

បទកាកគតិ

នៃនេះស្វេះទី– ទានទៅអំពី បរមក្សត្រថ្ងៃ វិមលបពិត្រ រៀង
ឫទ្ធិជាញជ័យ ស្តេចលើកពលក្រៃ ចេញចាកភាព ៗ ប្រាបខ្មាំង
តិរ្យេ ចាញ់ព្រះបារមី ព្រះបាទពកជា ស្រេចស្តេចប្រពាត រុក្ខជាតិ
អដ្ឋា សប្បាយទយា ក្នុងព្រឹក្សាសាន្ត ៗ គម្រប់មាសា ប៉ែខក្សត្រា
ភ្នកទឹកពជឋាន ទឹកនាងសារិកា ចិន្តាពុំក្សាន្ត ស្តេចលើកទាហាន

ចូលក្រុងភាព ៗ ស្រេចដល់ប្រាសាទ ស្តេចយាងព្រះបាទ ដើរ
ដោយមាគ៌ា ព្រះនេត្រទតទៀង ពល់រៀងនានា ឈើឥតគណនា
រលួសមាសមៃ ៗ ផ្លែផ្កាពេញពាស ដូចគល់ក្ងមាស ប្រាស់ប្រាល
ពេកក្រៃ ទតស្រេចក្សត្រា លីលាធាប់វៃ ឡើងវៃទនទិព្វថ្ងៃ តែងទុក
សារិកា ៗ សុំស្និទ្ធទាំងឡាយ ខុខណាងអក់រយាយ ឡើងគាល់
ក្សត្រា ស្តេចទៀងទតច្បាស់ ទើបត្រាស់សួរថា ម្តេចបាត់សារិកា ពុំ
ឃើញមកផង ៗ អក់រយាយសុំស្និទ្ធ ទូលថាបពិត្រ ក្សត្រថ្លៃច្បាស់ច្បង
កាលស្តេចចេញច្បាំង ប្រាបខ្មាំងច្រើសឃ្លង ស្តេចយាងកន្ទង បាន
បីទិវា ៗ សារិកាកែវបាត់ យើងខ្ញុំរកស្កាត់ សព្វទីនានា ពុំយល់
ឃើញគិត ភ័យភិតមហិមា រកពល់គ្រឹហា ផ្សារផ្សាទីឋាន ៗ ពុំ
យល់សារិកា កើតទោមនស្ស ទៀងទុក្ខគ្រប់ប្រាណ សូមទានក្សត្រ
ថ្លៃ ប្រពៃថ្កើងថ្កាន មេត្តាប្រោសប្រាណ យើងខ្ញុំគ្រប់គ្នា ៗ កាល
ឆន្ទាចាប់ សារិកាប្រញាប់ ឲ្យទាសីវ៉ា បោកបោចពេមស្លាប ដកប
អង្គា ឈើមាសត្រាំត្រា ស្រពោនជ្រុះស្លឹក ៗ លុះនាងសារិកា បាន
ក្សាន្តសុខា រីងរាជព្រឹក្ស លូតលេចបុប្ផា ផលាសន្ធឹក សាខាញែកញឹក
ដូចកាលប្រក្រតី ៗ ហេតុនោះព្រះបាទ វិមលនរនាថ ធិរាជចក្រី
ស្តាប់ពាក្យសុំស្និទ្ធ ទូលពិតអស់ក្តី ទើបព្រះចក្រី ស្ងៀមពុំចរចា ៗ

ស្តេចទ្រង់ត្រេកត្រះ ថាសារិកានេះ ហិចហើរយាត្រា ទៅព្រៃហិមពាន្ត ទើបានព្រឹក្សា រកទេពធីតា ឲ្យប្រោសប្រែប្រាណ ៗ ជាមនុស្សរូបរ័ត្ន ហេតុនោះទើបបាត់ ពុំយល់កូនបាន ស្តេចទ្រង់ចិន្តា ហើយមហាក្សត្រ ក្សាន្ត ស្ងៀមស្ងប់ពុំមាន ទុក្ខាទៀតទៅ ៗ

ន័យនេះស្ទើរនៅ និងនិទានទៅ ទេវបុត្រមួយណា វិមានគង់ ថិត តុសិតសួគ៌ា សន្តតនាមា បច្ចេកពោធិ ៗ កំណត់ជន្មា និង សោយវិលា- ល័យចុះបាកទី តាកតួទេវបុត្រ ច្យុតមកទី. មិន្ទ ជាតិជាទី កំសត់ជាតិជា ៗ បដិសន្ធិ យកជាតិកូនទី ជាបទុមា នៅស្រះឥសី មិត្តាជិនា កំណត់ទិវា ប្រាំពីរថ្ងៃបាន ៗ ទើបកើតជាអង្គ បរិបូណ៌ព្រាយទ្រង់ ជាមនុស្សប្រុសប្រាណ រីឯឈូកនោះ ជាលដុះ ឡើងបាន ធំក្រៃប្រមាណ ប៉ុនដុំថោ ៗ ល្អល្អះចិញ្ចៀន ធំក្រៃឯកឯង លើសលែងអស់ផ្កា គ្របគស្រទាប់ ខ្ទន់ខ្ទប់បុប្ផា ធរីជ្រះថ្លា កណ្តាលជលស័យ ៗ ចាតោរសោ ព្រឹកស្រោងស្មុំយោ ឥសីសីល ថ្ងៃ បចុះទៅស្រង់ កំពង់ជលស័យ ឃ្លៀងទេត្រវៃ ទតទៅបុប្ផា ៗ យល់ធំចម្លែក ល្អល្អះអនេក ក្រៃលែងអស្ចារ្យ ឥសីបេះយក មកបក បុប្ផា មើលឃើញកុមារ កូនផ្កាឈូកនោះ ៗ តក្រាំបព្រង ទ្រង់ព្រាយឃ្លៀងឈ្ងង ល្អល្អះពេញប្រុស ប្រកបលក្ខណា សោភា

ទ្រង់យស ជាមហាបុរស ឯកអគ្គវង្ស ៗ ឥសីអរសល់ នាំយកទៅដល់ បណ្ណសាលា ហើយថ្វាយក្សត្រី មរណមាតា ឲ្យនាងរក្សា ជាបុត្រ ស្ងួនគ្រង ៗ មរណមាតា ទទួលកុមារ ត្រេកអរកន្លង ទើបនាង សច្ចា អធិដ្ឋានផ្សង បង្គំទេពផង កង់ព្រឹក្សាសាន្ត ៗ ថាបើកុមារ នេះមានសំការ មានបុណ្យថ្កើងថ្កាន មានចិត្តសប្បុរស ចំពោះប្រុស ប្រាណ ដឹងគុណអ្នកមាន- គុណគួររក្សា ៗ សូមឲ្យទឹកដោះ ខ្ញុំហូរមកស្មោះ ចូលមាត់កុមារ បើមនុស្សទុច្ចរិត ជួជាតិពង្សា ពុំស្គាល់មាតា បិតាប្រធាន ៗ កុំឲ្យទឹកដោះ ខ្ញុំហូរចេញស្មោះ នោះខ្ញុំនឹងបាន ដឹងជាក់ស្មានស្មោះ ចំពោះកុមារ នាងអធិដ្ឋាន ស្ងួរចេកាលណា ៗ រីឯទឹកដោះ ហូរចេញមកស្មោះ ចូលមាត់កុមារ នាងមានព្រះទ័យ មេត្រីករុណា ចិញ្ចឹមកុមារ បានមួយឆ្នាំគត់ ៗ រូបរាងល្អឈ្នះ កក្រោគ្រប់ គ្រប់ង់បរិសុទ្ធ អស់អង្គល្អសល្អុន ទន់ ក្ខនបានបទ ឥសីសន្មត តាមជាតិកង្ខា ៗ ថ្វាយនាមព្រះអង្គ ឈ្មោះថាទុមវង្ស កុមារថ្ងៃថ្វា ព្រះអង្គជាតិធំ សក្តិសមរូបា លុះ ដល់ជន្មា ពីរដណ្តប់ឆ្នាំ ៗ សំដីពីរោះ ផ្អែមល្ហែមស្មានស្មោះ ស្មោះតែចង់ ចាំ ប្រាជ្ញាជ្រះថ្លា ទស្សនាហម្ចូនមាំ មាតានាងនាំ ទៅថ្វាយឥសី ៗ ឲ្យរៀនសិល្បសិទ្ធ ឥសីទ្រង់ប្រុទ្ធ ប្រដៅបាលី លិខិតអក្ខរៈ

សិល្បៈសាស្ត្រគ្គី រៀនចប់ឥតបី ទើសពាល់ប្រាជ្ញា ។
មានកាលមួយថ្ងៃ បទុមវង្សវៃ ដណ្ដឹងមាតា បពិត្រព្រះមេ តាមតែ
មេត្តា ហេតុម្ដេចអាត្មា យើងនៅក្នុងព្រៃ ។ តែព្រះមាតា ទីងអយ្យ-
កោណា កំព្រាឃ្លាតឃ្លៃ ឥតញាតិសន្តាន ព្រៀងលានដទៃ ព្រះបិតា
ថ្ងៃ ខ្ញុំមានឬទេ ? ។ សាគំសុត្វា ឯព្រះមាតា ស្ដាប់បុត្រទូលថៃ
នាងមានសរទីយ៍ ថាហៃមាសម៉ែ កូនអើយវង អង្គព្រះបិតា ។
នៃបាត្មានទេ បាមកអំពី សួគ៌សុខកាមា មកយកកំណើត បង្កើត
ក្នុងផ្កា ឯអញមាតា បាងនសត្វថ្ងៃ ។ សោកសិងឥតញាតិ កំព្រា
ឃ្លាឃ្លាត ស្វះស្វែងក្នុងព្រៃ ជួបទីងតាបស សប្បុរសពេកក្រៃ
ឲ្យម្ដាយអាស្រ័យ នៅនេះណាំបា ។ បទុមវង្សស្ដាប់ មាតាថ្លែង
ប្រាប់ ជាសន្ទេបណា ហើយអ្នកធ្វើយធ្វៀត សួរទៀតទៅថា
បពិត្រមាតា សូមទ្រង់ប្រណី ។ ថ្លែងប្រាប់ប្រការ រឿងអ្នកមាតា ឲ្យ
អស់សេចក្ដី អ្នកត្រាច់ព្រឹក្សា ប្រាជ្ញារកអ្វី តើមកអំពី នគរជានណា ។
ព្រះវរជននី នាងថ្លែងប្រាប់ពី រឿងខ្លួននាងថា ហៃកូនសំឡាញ់
ពាលពេញរូបា ខ្លួនអញមាតា ជាកូនកុដុម្ពិក ។ នៅនគរ វិទេសរដ្ឋា
បុរីជាទី កុដុម្ពិកបិតា ភរិយានោះនៃ ឈ្មោះកុលកេសី ម្ដាយអញណាំ
បា ។ មួយឈ្មោះកាលី ប្រពន្ធបុងថ្មី ចិត្តកាចឫស្យា ញុះញង់អាពុក

ធ្វើទុកមាតា អញស្លាប់គេតជា មច្ចាដ៏រ ៗ មានទេពធីតា ប្រាប់ពីមាតា
សព្វគ្រប់សេចក្តី ម្តាយយកអង្ករ ល្អិតល្អពិសី ទៅបាចឲ្យត្រី បានបរិ-
ភោគ្គា ៗ កាលដឹងជាក់ ប្រើកូនពីរនាក់ បញ្ចោតមច្ចា យកមកសម្លាប់
ធ្វើជាភោជនា នៅសល់ស្រកា ត្រីពីរទើបមាន ៗ ទាញមួយគិត ស្ទុះ
ទៅហូហិត ស្រកាត្រីបាន មកឲ្យទើបម្តាយ កកាយដីក្កាន ដាំដុះឡើង
បាន ជាដើមត្រប់ទ្វី ៗ កាលលួចដក ដើមត្រប់យកមក បេះផ្លែ
ស្ងួស៊ី ទាញមួយពាំ យកឫសត្រប់ទ្វី នាំទៅពីទី កាលឫស្សា ៗ
នាំយកឲ្យម្តាយ ទើបម្តាយកកាយ ដីដាំកាលណា ដុះឡើងពេញ
លូតលេចផ្លែផ្កា ជាដើមព្រឹក្សា រលួសមាសល្អ ៗ ពីដើមល្អល្អះ
ភ្លឺផ្ទេកគ្រប់ គ្របធំសន្ធៅ ដូចកល់ក្តីមាស ទុកាសក្តិនល្អ
ម្តាយបេះផ្កានូវ ក័ស្ដុភោជនា ៗ ទន្ទឹងត្រត្រកយ នាំយកទៅថ្វាយ
សំពះបូជា សព្វថ្ងៃរៀងពល់ ពុំសល់ទិវា កាលនោះពជា ព្រះបាទក្សត្រ
ថៃ ៗ វិមលបពិត្រ ធិកជទ្រង់ឫទ្ធិ ស្តេចចេញលេងព្រៃ យល់ដើម
ព្រឹក្សា ទេ្វហាល្អក្រៃ ដែលម្តាយអាស្រ័យ ដាំទុកនោះណា ៗ ស្តេច
សូមយកទៅ ម្តាយថ្វាយព្រះចៅ ចមបក្រចេស្តា ស្តេចយកទៅដាំ ថៃ
ទាំរក្សា ហើយមហាក្សត្រា ប្រើមុខមន្ត្រី ៗ ទទួលម្តាយទៅ
ដល់ហើយព្រះចៅ ចមក្រុងបុរី អភិសេកម្តាយជា អាយិអគ្គមហេសី

នៅបានឆ្នាំបី កាលីបុស្សា ៗ វាប្រើកូនស្រី មួយឈ្មោះចន្ទណី មួយនោះឈ្មោះថា ចន្ទាចិត្តកាច កំណាចឫស្សា បញ្ឆោតម្ដាយថា បិតាឈឺធ្ងន់ ៗ ម្ដាយទៅដល់នោះ វានាំចូលចុះ ចូលជាន់ក្ដារយន្ត ធ្លាក់គង្គប្រេងក្ដៅ ដល់ទៅដីពង់ទួ កាលីមិនគន់ មិនគិតអនិច្ចា ៗ វាយកឆ្អឹងម្ដាយ ទៅចោលព្រៃឆ្ងាយ មានទេពធីតា យកថ្នាំមកប្រោះ រស់ជាមនុស្សា ទើបទេពធីតា យកថ្នាំដាក់ទៃ ៗ ឲ្យសេពកាលណា កើតជាសារិកា ម្ដាយហើរលៃ ចូលក្រុងកាព គាល់មហាក្សត្រថ្លៃ ព្រះបាទជៀសផ្ចង់ វិមលចេស្ដា ៗ ម្ដាយទូលអស់ក្ដី ព្រះបាទចក្រី ជ្រាបគ្រប់ប្រការ ទើបស្ដេចប្រើជាង ឲ្យស្អាងរចនា ទ្រុងមាសថ្លៃថ្លា ឲ្យម្ដាយនិត្យនៅ ៗ មានកាលមួយថ្ងៃ ព្រះមហាក្សត្រថ្លៃ ស្ដេចលើកទ័ពទៅប្រាបខ្មាំងក្រៅស្រុក ស្ដេចទុកម្ដាយនៅ មានស្នំម្នាក់ខ្មៅ ចិត្តកាចឫស្សា ៗ ចាប់យកម្ដាយបាន ដកស្លាបពេមប្រាណ ម្ដាយវេទនាឯធន្ទានោះ វាចុះលីលា ម្ដាយតែយាត្រា ទៅតួនទិត្យនៅ ៗនឹងវង្គគណ្ដរ- សសោតបានយល់ ម្ដាយហើយហៅហើ ថៃទាំងក្បាឥតមានហ្វូងសៅ ម្ដាយនៅយូរទៅ លុះត្រាស្លាបជា ៗ ទើបម្ដាយលាស្ដេច គណ្ដរសត្រាច់ ចេញចរលីលា មកដល់ឈើធំ គ្រសុំសាខា ម្ដាយទំព្រឹក្សា សម្រាន្តអង្គកាយ ៗ ទើបមានស្ដេចខ្លា

ស៊ីផ្លែព្រឹក្សា បួនផែកកើតក្លាយ ផែកមួយកើតជា បក្សាគបកាយ ផែកមួយកើតក្លាយ ជាប្រើសមាសធំ ៗ ផែកមួយជាស្វា ផែកមួយកើតជា មនុស្សស័ក្តិសម ម្តាយយល់ដូច្នោះ ហើរឆ្ពោះទៅចំ ឈើឈើឧត្តម ជាថ្នាំទិព្វល្អ ៗ ហើយម្តាយកោក្កា កើតជាមនុស្ស រូបកង់ចរ ត្រាច់ដើរស្វះស្វែង ម្នាក់ឯងចេញចរ មកនៅខេះប-រិបូណ៌បានសុខា ៗ នៅទីឥសី គំរប់ឆ្នាំបី នេះហើយណ៊ាបា កុមារបានស្តាប់ សាសព្ទមាតា មានចិត្តអនិច្ចា សង្វេគពេកពន់ ៗ ហើយអ្នករំពឹង ថាអញនេះនឹង ចង់សងព្រះគុណ មាតាបិតា ឧត្តមមហាធ្ងន់ ដោយនៅដំបន់ ឋានឆាយឯណ៊ា ៗ លុះគិតដោយន័យ យល់ហេតុប្រពៃ ថាគួរអាត្មា ចូលទៅនគរ សួររក៍បិតា មើលឈើសុវណ្ណ រាជព្រឹក្សតីរពង្ស ៗ គិតហើយទូលថា បពិត្រមាតា កាលអ្នកត្រាច់ត្រង់ ចេញពីនគរ បវររដ្ឋរង់ បិតាបានទ្រង់ប្រទានទ្រព្យអ្វី? ៗ នាងស្តាប់ឆ្លើយថា ហៃកូនស្នេហា ម្តាយជាសាក្សី កាលនោះបិតា មេត្តាប្រណី យកចិញ្ចៀនថ្មី មាសផ្ទិនរចនា ៗ ដាំត្បូងមរកត ចាំងពីរសន្ធត ជាកងសុវណ្ណ ដាក់ដើងម្តាយអ្នក ខាំដាក់ណ៊ាបា នេះទ្រព្យបិតា ប្រទានមកម្តាយ ៗ សោតំសុត្តា ព្រះរាជកុមារ រឿងរិទ្ធិប្រាជ្ញប្រាយ បានស្តាប់មាតា វោហារអធិប្បាយ

អ្នកជ្រាបសព្ទសាយ សព្ទសុសសេចក្តី ។ ទើបអ្នកទូលថា បពិត្រ មាតា សូមទ្រង់ប្រណី ខ្ញុំសូមលាទៅ លំនៅបុរី មើលឈើតាំងទី ទ្រព្យអ្នកមាតា ។ សូមព្រះទំរង់ ជាំត្បូងបញ្ចង់ ជាកងនោះណា ដែលបិតាដាក់ ដើងអ្នកមាតា គ្រាន់ខ្ញុំបានជា សំគាល់សាក្សី ។ មាតាស្តាប់បុត្រ ទូលលាចំបុត ទីងទៅបុរី នាងមានព្រះទ័យ អាល័យ ប្រណី ដ្បិតក្មេងសេចក្តី នាងឃាត់ទៅថា ។

បទព្រហ្មគីតិ

ហៃកូនស្ងួនសំឡាញ់ បាពាលពេញចិត្តចិន្តា កូនអើយកុំបីបា បរទេញឆ្ងាយម្តាយបាម្ក ។ ហេតុត្បិតបានៅក្មេង ដើរម្នាក់ឯងក្នុងព្រៃ ធំ ព្រៃស្ងាត់ ។ ទុគិម សោកសីងសត្វពាឡយង់ឃ្នង ។ មួយក្រងអត់ គោជនា គ្មានអ្នកណាជាតំរេង សព្ទថ្ងៃម្តាយស្ងួនគ្រង ពុំឲ្យហ្មង ចិត្តនៃបា ។ បទុមវង្សប្រុសក្មេ ព្ទម្តាយឃាត់ដូច្នោះណា អ្នកទូលអង្វរថា បពិត្រអ្នកមានគុណថ្លៃ ។ កុំបីអ្នកបាម្ក ទីងខ្លួនខ្ញុំឡើយម្ចាស់ថ្លៃ មេត្តាឲ្យផ្លៃជ្រៃ ឲ្យបរិភោគថ្លែងកាយា ។ ជាសត្វបក្សធំ ហើយទើប ខ្ញុំហើរយាត្រា ដោយហានអាកាសា គ្មានសត្វពាឡអ្វីបៀតបាន ។ បើបានដល់នគរ ហើយចុះចរចាកប្រែប្រាណ បរិភោគមួយទៀតបាន ក្លាយជាមនុស្សចរយាត្រា ។ នាងស្តាប់កូនបុត្រក្មេ ខានពុំឃាត់ពុំទាំងទា

ទើបនាំយកផលា ផ្លែឈើឲ្យបុត្រគ្រប់ថ្ងៃ ៗ ហើយឲ្យព្រះទំរង់ ទាំងគូផ្គង់ល្អប្រពៃ ហើយឲ្យព្រះពរជ័យ បុត្រកំសត់ដោយស្នេហា ៗ ហើយឲ្យបុត្រប្រិមប្រិយ លាឥសីជាធីតា កុមារស្តាប់មាតា អ្នកឲ្យទៅថ្វាយបង្គំ ៗ ក្រាបទូលលាឥសី សព្វសេចក្តីស្រេចហើយផ្គង់ ក្រាបលាម្ចាស់ ឱគុណ៌ ទៅនគរសួរបិតា ៗ ឥសីព្រមបើកទៅ ទើបប្រដៅមន្តគាថា មួយឈ្មោះមណីចិន្តា អ្នកទន្ទេញចាំគ្មានភ្លេច ៗ ហើយទើបព្រះឥសី ប្រាប់អស់ក្តីសព្វសេចគ្រប់ ឧបទេសមនុស្សឧបកិច្ច ឲ្យការពារសព្វវេលា ៗ កុំបីទៅប្រហែស ដើរក្រអែសភ្លេចការពារ បើសូត្រសព្វវេលា ជាស្នេហ៍មុខមនុស្សទាំងឡាយ ៗ ទោះបីពួកសត្វម្រឹគ កាចពន្លឹកសឹងចៀសឆ្ងាយ ការភ័យការអន្តរាយ ការឧបទ្រពផងនានា ៗ ទោះមនុស្សសត្វណាក្តី យក្ខិនីព្រាយហិង្សា បិសាចកាចសឹងជា សឹងស្រឡាញ់ឃាត់ពុំបាន ៗ ផ្តាំស្រេចព្រះឥសី សូត្រស្តុតឲ្យពរក្សាន្ត ថាចៅទៅឲ្យបានឈ្នះសត្រូវផងនានា ៗ ឲ្យបានដល់នគរ រក្សាបវរដូចប្រាថ្នា ដូចចិត្តប៉ងប្រាថ្នា ដែលសត្វាកុំបីឃ្លាត ៗ ឲ្យពរស្រេចកុមារ ឱនសិរសាក្រាបអភិវាទ ចេញចរសីហនាទ ត្រាច់កណ្តាលក្នុងអដ្វា ៗ និទានតខ្សែប្រាំ ដូចចាប់ចាំពោលពណ៌នា តាំងពីនាងជាយ៉ា ជាសារិកាកែវកល្យាណ ៗ លុះបានសោយផ្លែជ្រៃ ទើបប្រពៃកាយប្រែប្រាណ ជាមនុស្សលុះដល់

បាន បុត្រសាទៅនគរ ។ បន្ទំបន្ទាបលើក សូត្រល្បងល្បិចល្បើកពោល ពណ៌នា បរិបូណ៌ជួបចូលជា ខែប្រាំមួយសួរបើហោង ។

បទកាកគតិ

ន័យនេះថ្ងៃឥត ដំណើរដំណា ដំណាលទំនង តពីខែប្រាំ-មួយចាំជួបចង ចរចាទំនង ពីពជកុមារ ។ បទុមវង្ស ស័ក្តិសមឧត្តុង្គ ឧត្តមអតុលា ស្តេចយាងសីហនាទ គគាតយាត្រា ចេញចាកលំលា អាស្រមកុដី ។ ម្នាក់ឯងទុគ៌ម ស្ងប់ស្ងាត់ជ្រងំ ព្រៃតបក្ស ចចាតខ្វក់ ក្អែក យំស្រែកពេញព្រៃ អ្នកទឹកអាល័យ ដល់ព្រះមាតា ។ មយូរពេនពន់ ក្រៀលក្រចហែមហង្ស សត្វសារិកា ក្ងោកទុំពោម សេកសោម សេកយា ហិចហើរខ្សៀវខ្សា យាសយំអឹងកង ។ អ្នកយាងបណ្តើរ ឆ្មៀងនេត្រមៀងមើល បក្សាសាសង អ្នកតែងការនា គាថាមន្តផង ខ្យល់បក់មួង ៗ សាយសព្វទិសា ។ មានស្តេចប្រើសមាស បរាំពេញពាស ក្នុងព្រៃហិមវា ប្រើសមាសដើរដល់ យន់យល់កុមារ មានចិត្តស្នេហា ស្រឡាញ់អ្នកក្រៃ ។ ដោយតេជះបុណ្យ វិសេសពេកពន់ ត្រូវប្រើស មាសមៃ ប្រើសមាសគន់គិត ចាប់ចិត្តអាល័យ អាណិតអ្នកថ្ងៃ ដោយ ដើរម្នាក់ឯង ។ ប្រើសមាសគិតថា ចង់ជូនជាគ្នា សោះស្ងាត់កណ្ដាន កុំឲ្យកុមារ យាត្រាតែឯង គិតស្រេចចារចៃង សាកសួរកុមារ ។ ថា

អ្នកកម្លោះ មុខមាត់ស្រស់បស់ អញ្ជើញទៅណា កុមារស្តាប់ហើយ
ឆ្លាស់ឆ្លើយទៅថា យើងនឹងយាត្រា ទៅវិទេសពស្ត្រ ។ ប្រើសស្តាប់
ឆ្លើយថ្កាន អ្នកទៅតើមាន ហេតុអ្វីអ្នកមាស កុមារស្តាប់ស្រេច ប្រាប់
ស្តេចប្រើសមាស ថាយើងយានយាស ទៅមើលព្រឹក្សា ។ សុវណ្ណ-
ពជព្រឹក្ស ពីរពន្សអធិក ជាទ្រព្យមាតា ប្រើសមាសឆ្លើយទៀត សួរ
ទៀតទៅថា ឯព្រះមាតា អ្នកឯងនោះក្តី ។ ស្តេចគង់ឋានណា កុមារ
ឆ្លើយថា មាតាក្សត្រី អ្នកគង់អាស្រម បរមកុដិ ជិតព្រះឥសី មិត្តា
ជិនជាក់ ។ ប្រើសមាសឆ្លើយថា រីឯមាតា បិតានៃអ្នក មកដល់កុដិ
ក្សត្រីវល័ក្ខណ៍ ព្រះមាតាអ្នក នោះឆ្ងាយមហិមា ។ ម្តេចអ្នកស្ទះស្វែង
ហានត្រាច់ម្នាក់ឯង កណ្តាលកព្រោ ចេះខ្ញុំជូនអ្នក វល័ក្ខណ៍សោភា
កំដរជាគ្នា តាមផ្លូវទៅហោង ។ សូមអ្នកស្នេហ៍ស្និទ្ធ អញ្ជើញឡើង
បិត ឡើងគង់លើខ្នង ខ្ញុំនឹងនាំហោះ ផ្លេកផ្លោះកន្ទួង ហួសព្រៃព្រឹក្ស
ផង ឆាប់ដល់ពុំលង់ ។ កុមារស្តាប់ជាក់ ត្រេកអរហើយអ្នក យាង
យាសឡើងគង់ លើខ្នងប្រើសមាស ឲកាសវារវង្ស ហាប់ហោះដម្រង់
វិទេសរដ្ឋា ។ គំរប់បីថ្ងៃ បានដល់ក្រុងត្រៃ នៃពជកាក
បុរីរដ្ឋនោះ ហើយចុះយាត្រា ដើរដល់សាលា នៅក្រៅនគរ ។
ទៀបទីសាលា នោះមានគង្គា ស្រះមួយដំល្អ កុមារចុះស្រង់ ជ្រះគង្គា

កាយគេ ហើយអ្នកចំរេះ ឡើងលើសាលា ៗ បរិភោគភោជន ស្រេច
ហើយអ្នកគង់ អ្នកគិតមេត្តា បើកប្រើសមាសទៅ ។គេស្មោះភោក្តា ស្រេច
ហើយកុមារ សម្រាកអង្គកាយ ៗ អស់អ្នកនគរ ប្រុសស្រីកវេរ ប្រាប់
គ្នាសុះសាយ ថាមានកុមារ រូបាឆើតឆាយ ល្អល្អះអង្គកាយ ដូចជាទេវ-
បុត្រ ៗ ជិះលើប្រើសមាស ភ្លឺផ្លេកឲ្យកាស ល្អល្អះបរិសុទ្ធ ឯអង្គកុមារ
សមជាពជបុត្រ មិនគឺកស្រុតស្រុទ្ធ ជយលោកតព៌្យ ៗ ដោយតេជបុណ្យ
ស័ក្តិសិទ្ធិលើសលន់ បញ្ញានចិត្តា គ្រប់មនុស្សក្នុងស្រុក គគុកត្រៀបត្រា
មានចិត្តស្នេហា ស្រឡាញ់ក្រៃពេក ៗ សឹងនាំចំណី គស្តុភោជន៍សាលី
អនន្តអនេក មកជូនកុមារ ត្រៀបត្រាពន់ពេក ចំណីចម្លែក ពុំហ៊ាន
ភោក្តា ៗ ខ្លះថាអ្នកប្រុស មុខមាត់ស្រស់បស់ បែរមកការយក៏ ខ្លះភ្លេច
វិញ្ញាណ មើលប្រាណកុមារ ខ្លះលាន់មាត់ថា យើល្អអើម្ល៉េះ ៗ ឲកូន
អ្នកណា ម្ល៉េះសមមាត់ា ស្រឡាញ់ម្តេចអេះ បើជាកូនអញ ពាល
ពេញដូច្នេះ ហើយអញមិនបេះ ឡេះនៀយព្រួយទេ ៗ ឯអស់មនុស្សម្នា
ឡើងលើសាលា ជល្តិនិស្សូរថៃ ថាអ្នកមាសថ្លៃ ប្រពៃស្នាលស្នេហ៍
អ្នកមកនេះតែ ម្នាក់ឯងឯកា ៗ វិងទីឋាន បុរីបុរណ អ្នកនៅឋានណា
កុមារស្តាប់ហើយ ទើបឆ្លើយទៅថា យើងនៅព្រឹក្សា ព្រៃព្រះហិមពាន្ត ៗ
មហាជនសួរថា វិញ្ញាតិកា ត្រៀនលានសន្តាន គ្រកូលពូជពន្ស

ជាតិវង្សប៉ុន្មាន ក្នុងស្រុកនោះមាន ខ្វះដៃឬទេ ? ។ កុមារឆ្លើយថា
យើងជាអ្នកព្រៃ យើងមកព្រោះតែ ចង់មើលរាជព្រឹក្ស ពន្លឺកចាំងទ្វេ
ហេតុត្បិតព្រះកេរ្តិ៍ មាតាបិតា ។ រីឯញាតិផៅ បងប្អូនកូនចៅ គ្មានស្គាល់
អ្នកណា ជាញាតិសន្តាន ព្រៀងលាងពង្សា គ្រង់ញាតិកា មានគ្មានមិន
ដឹង ។ មហាជនបានស្តាប់ កុមារថ្លែងប្រាប់ សព្វគ្រប់សោកសឹង ធ្វល់
ក្នុងចិន្តា គ្រប់គ្នាជញ្ជឹង ថាបើដោយដឹង សំបុត្រក្សត្រា ។ ជាអម្ចាស់
យើង ទើបរូបល្អក្រើន ដួងភក្ត្រជ្រះថ្លា ដំណើរសីហនាទ គតាគក្រៀវក្លា
ថ្កល់ថ្កើនឥរិយា កណ្តាលជំនុំ ។ ឈាមមុខថ្លាជ្រះ កបកាយល្អល្អះ
ប្រកពារម្យទំ សម្លេងពីរោះ សព្វនោះរងំ ផ្អែមល្ហែមសួនសម
ជាបុត្រក្សត្រា ។ គិតហើយសួរទៅ ថាអ្នកល្អញល្អៅ ជាបុត្រអ្នកណា
ចូលអ្នកថ្លែងប្រាប់ យើងស្តាប់វាចា រីនាមបិតា មាតាឈ្មោះអ្វី ? ។
ព្រះបទុមវង្ស ស្តាប់ហើយអ្នកទ្រង់ គតបសំដី ម្តេចអ្នកហ៊ានសួរ
មិនគួរគប្បី យើងប្រាប់អ្នកអ្វី មាតាបិតា ។ គួរសួរឈ្មោះយើង
ម្តេចហ៊ានចចើង សួរហួសមាត្រា ដល់ព្រះនាមថ្លៃ នៃព្រះមាតា បិតា
នោះណា យើងប្រាប់ម្តេចបាន ។ មហាជនបានស្តាប់ អ្នកថ្លែងសារសព្វ
ហាក់ក្រោធពុំក្សាន្ត កិតភ័យខ្ជបខ្ជាច អំណាចគ្រប់ប្រាណ ស្ងៀមស្ងាត់
ពុំហ៊ាន ហើចហាទាត់ស្តី ។ លាចុះយាត្រា ទៅផ្ទះអាត្មា ចាំងប្រុស

ចាំងស្រី សឹងតែទំហាយ ព្រួសាយឥតបី សរសើរបារមី នៃកជបុត្រា ៗ ព្រះបទុមវង្ស លុះយប់ផ្អកទ្រង់ ផ្ទំលើសាលា ជាសុខក្សេមក្សាន្ត សម្រាន្តកាយា ប្រើសមាសសោតណា ចាំយាមពុំឃ្លាត ៗ

នឹងថ្លែងទៅដល់ ព្រះបាទវិមល ជម្ពូជលោកនាថ ស្តេចផ្ទំសុខា វេលាអធ្រាត្រ ទេវបុត្រជាតិ ឈ្មោះទេពធីតា ៗ គឺកុលទេសី តែនៅប្រក្រតី រក្សាព្រឹក្សា រលួសមាសទ្វី ក្នុងទីក្សត្រា ដឹងថាកុមារ ឈ្មោះបទុមវង្ស ៗ កូនតាងមរណ- មាតាសោកគ៏ យាត្រាដល់ក្នុងបុរីផ្ទា ចិន្តាបម្រុង ចង់ស្គាល់នូវអង្គ ព្រះវរបិតា ៗ ទើបទេពទេវី នាងចូលទៅទី- មិត្តប្រាប់ស្តេចថា ចៅបទុមវង្ស ជាអង្គបុត្រា មរណមាតា ចូលក្នុងបុរី ៗ គង់លើប្រើសមាស រុងរឿងទុកាស ផ្ទះផ្ទាស់ទង្សី ឈប់នៅសាលា វេលារាត្រី នៅក្រៅបុរី ផ្ទំសុខសយនា ៗ ព្រឹកនេះចូលមក ប្រាថ្នានឹងរក ស្តេចជាបិតា ប្រាប់ស្រេចនិម្មិត បាត់ចិត្តកាយា រីឯក្សត្រា វិមលធិបតី ៗ ស្តេចផ្ទំសុខា លើទីសយនា ព្រឹកព្រាងសូរ្យ៍ សូរ្យសែងរឿងរះ ក្តីច្បាស់ស្មើ ព្រះបាទចក្រី តើនចាកសយនា ៗ ស្តេចទ្រង់វិតក្ក វិចារណ៍ពុំសុខ សង្ស័យគិតថា នាងនាថវរល័ក្ខណ៍ មរណមាតា កូនទឹងនរណា នឹងអញឬគេ ៗ មរណមាតា នាងក្សយជន្មា ហើយក្លាយប្រាណប្រែ

ជាសត្វសារិកា បក្សាវិញទេ ច្នេះតើកូនគេ មិនកូនអាត្មា ៗ បើកូន
ក្សត្រី នាងមានស្វាមី បុរសឯណា អញនឹងទៅចាប់ សម្លាប់អាសារ
បើជាក្សត្រា នគរដទៃ ៗ អញនឹងលើកទ័ព ទៅច្បាំងចោមចាប់
សម្លាប់ឲ្យក្ស័យ រីអញនឹងក្ដោយ បណ្ដាយដោះដៃ ឲ្យបានស្រីថ្លៃ
ទៅគេកាលណា ៗ ហើយក្សត្រឧត្ដម ចេញចាកបន្ទំ ទីទិព្វសយនា
គន់ចុងពេងរត្ន មហាក្សត្រត្រាស់ថា ហៃអស់សេនា អមាត្យទាំងឡាយ ៗ
ចាត់គ្នាចេញទៅ ចាំទ្វាកំផែងក្រៅ ទាំង ៤ ទិសឆ្ងាយ បើឃើញក្មេងប្រុស
មុខស្រស់ឆើតឆាយ ជិះប្រើសមាសកាយ នាំមកឲ្យអញ ៗ អមាត្យ
បានស្ដាប់ ទទួលបង្គាប់ បង្គំលាចេញ ចាំគ្រប់ទ្វារ ៤ គ្រប់ខ្លួននៅមិញ
មាត់តែងទះទ្រូញ ទន្ទឹងកុមារ ៗ ឯកុមារពេ ព្រឹកព្រាងសុរិយោ
ចាំងបែងជ្រះថ្លា ព្រះបទុមវង្ស ទ្រើសទ្រង់ចេស្ដា តើនចាកសយនា
បន្ទំសុខសាន្ត ១ ស្រេចក្រគ្រស្អាងស្អាត សោយគន្ធជាត អាហារ
ស្រេចបាន ហើយសោយផ្លែជ្រៃ ប្រពៃឆ្ងើងឆ្ងាន ថ្នាំទិព្វដែលបាន
ពីព្រះមាតា ៗ គេដ:ផ្លែជ្រៃ ថ្នាំទិព្វប្រពៃ ប្រែប្រាណរូបា ល្អល្អះ
លើសមនុស្ស ល្អនល្អាសកាយា ហាក់ដូចទេព្ដា ចុះចាកសួគ៌ថ្ងៃ ៗ
ហើយអ្នកគាវិនា មណីចន្ទា សិល្បសិទ្ធសាស្ត្រស័យ រូបកាយល្អល្អះ
ថាជ្រះប្រពៃ គន់ប្រើសមាសមៃ ចេញចរយាត្រា ៗ មហាជនទាំង

ឡាយ ឃើញរូបឆើតឆាយ ជាប់ចិត្តស្នេហា មកមើលជួបជុំ កុះករ
ត្រៀបត្រា ហែជាបរិវារ ច្រើនក្រៃក្រខ្ដុលខ្មៅ ។ ព្រះបទុមវង្ស ក្តល់
ថ្កើងតួជពង្ស ថ្កើង ឋសឥតសៅ ស្តេចយាងយាត្រា មនុស្សម្នាហែទៅ
ចូលដល់កំពង់ក្រៅ ខាងទិសបូពា៌ ។ មនុស្សក្នុងនគរ ជ្រួលច្របល់
វឹកវរ បង្ហាញគ្នីគ្នា មើមេហើយមើលទៀត ច្រើនជ្រៀតមហិមា
ប្របៀតជ្រៀតគ្នា តាមមើលមិនឆ្អួន ។ សង់ខាងមាត៌ ខ្លះសួរសន្ធនា
ជាអ្នកប្រុសគន់ អ្នកមកពីណា កាយាល្អាសល្អន់ អ្នកអើយចូលគន់
មកនេះខ្លះក៏ ។ ស្រីខ្លះឥតខ្មាស លូកស្ទាបប្រើសមាស ស្ទាបដល់កុមារ
ខ្លះស្រែកពីចាយ អ្នកអើយមេត្តា បែរមកកាយក៏ យើងមើលមុខផង ។
ព្រះបទុមវង្ស ស្តាប់ហើយអ្នកទ្រង់ ញញឹមម្តង១ ស្រីខ្លះហុចស្លា ហុចផ្កា
កម្រង ឲ្យទឹកអប់ផង ស្រឡាបអង្គកាយ ។ ខ្លះបានចំណី បេកនំ
ដូងខ្ចី ខ្នុរលុតត្រពាំងស្វាយ ចចឹមរៀបចំ ទូលទំពាំងឡាយ សែងរែក
ទូលស្វាយ តាមជូនត្រៀបត្រា ។ ព្រះបទុមវង្ស យាត្រាត្រាច់ត្រង់
ដល់ទ្វារទិសា ពីមុខរាជវាំង ជួបទាំងអមច្ច អមាត្យក្សត្រា ឲ្យចាំនោះ
នៃ ។ អមាត្យបានយល់ កុមារវិមិល រូបកងល្អមល្មៃ មានចិត្តស្រឡាញ់
ពេកពេញហឫទ័យ ហើយហៅថាហៃ អ្នកមានរូបល្អ ។ អញ្ជើញមក
កាយ យើងនឹងនិយាយ សួរសោកនាមករ ព្រះបទុមវង្ស ទ្រើសទ្រង់

បវរ ស្តាប់ហើយចូលចរ ចូលជិតអមច្ចា ៗ អមាត្យទាំងអស់
សួរថាកម្លោះ អ្នកមកពីណា កុមារបានស្តាប់ ឆ្លើយប្រាប់ទៅថា យើង
ចរយាត្រា មកពីហិមពាន្ត ៗ អមាត្យសួរថា អ្នកមានប្រាជ្ញា រកអ្វី
ឬមាន ញាតិផៅនៅឆាយ តាយាយព្រៀងណាន ចូលអ្នកព្រមាន ប្រាប់
យើងផងក៏ ៗ ព្រះបទុមវង្ស ស្តាប់ហើយអ្នកទ្រង់ តតបវាចា ថា
យើងត្រាច់ដើរ មានបើប្រាជ្ញា ចង់យល់ព្រឹក្សា ទាំងគូមាសម្ពៅ ៗ
ជាទ្រព្យមាតា អ្នកតាមរក្សា ពីដើមទុកនៅ អមាត្យបានស្តាប់ អ្នក
ប្រាប់ហេតុខ្លៅ ខំសួរទៀតទៅ ថាឯមាតា ៗ អ្នកតើឈ្មោះអ្វី ចូរអ្នកស្រដី
ប្រាប់យើងផងក៏ កុមារស្តាប់ជាក់ ហើយអ្នកឆ្លើយថា អ្នកសួរអាត្មា
យើងនេះហៅគួរ ៗ មិនសួរឈ្មោះយើង សួរម្តេចចចើង ដល់ម្តាយជា
ម្តង មិនគួរយើងប្រាប់ សារសព្វសួរបង អ្នកឯងហៅគួរ សួរស្ងៀម
ទៅជា ៗ អមាត្យស្តាប់ហើយ ថាឱអ្នកអើយ អ្នកកុំក្រោធា យើង
មិនសួរឯង សំដែងវិជ្ជា ព្រោះព្រះរាជា ត្រាស់ប្រើសួរទេ ៗ កុមារ
ឆ្លើយថា បើមហាក្សត្រា បរមខត្តិយេ ដល់យើងឡើងទៅ គាល់
ហៅគង់តែ ស្តេចសួរយើងថៃ សឹមទូលក្សត្រា ៗ អមាត្យស្តាប់ហើយ
ឆ្លើយថាអ្នកអើយ ឯនាមមាតា ពុំគួរពុំសម យើងពុំសួរថា សួរតែ
នាមា អ្នកឯងឈ្មោះអ្វី ៗ បទុមវង្សា ទ្រើសទ្រង់បេស្តា បានស្តាប់

សំដី អមាត្យចំឡៀត សួរទៀតជាថ្មី ទើបអ្នកស្រដី ប្រាប់នាមអាត្មា ៗ
ថាយើងប្រាប់ត្រង់ ឈ្មោះបទុមវង្ស កុមារបុត្រា យើងនៅសព្វថ្ងៃ
អាស្រ័យព្រឹក្សា គឺព្រៃហិមវា បរមសុខសាន្ត ៗ អមាត្យស្តាប់ជាក់
ថាប្អេះប្អូរអ្នក សណ្ឋិតឈប់ខាន ចាំយើងទូលក្សត្រ ចក្រពត្តិថ្កើងថ្កាន
អមាត្យបួលបាន ឡើងគាល់ក្សត្រា ៗ ហើយក្រាបទូលផ្ទង់ ថាកាលព្រះ
អង្គ មានព្រះវាចា ត្រាស់ប្រើយើងខ្ញុំ មើលក្មេងកំព្រា ឥឡូវយាត្រា
មកដល់ក្រៅវាំង ៗ ស្តេចត្រាស់សួរថា ជាកូនអ្នកណា ពង្សាសន្តាន
មាតាបិតា កុមារថ្កើងថ្កាន ទៅសួរគេបាន ប្រាប់ថាឈ្មោះអ្វី ៗ
អមាត្យទូលថា សួរនាមមាតា បិតានោះក្តី ថាពុំគួរប្រាប់ សារសព្វ
ធ្វើអ្វី បើព្រះចក្រី ទ្រង់សួរអាត្មា ៗ សឹមក្រាបទូលអស់ ចេញតាំង
នាមឈ្មោះ បំពោះភក្ត្រា មហាក្សត្របានស្ដាប់ សារសព្ទវាចា មាន
ព្រះបញ្ជា ត្រាស់ប្រើរត់ទៅ ៗ នាំពជកុមារ ចរចូលត្រកាល តាំង
ប្រើសមាសឆ្នៅ ឲ្យចូលមកឆាប់ ប្រញាប់ណាទៅ អមាត្យរត់ស្ទៅ
អញ្ជើញកុមារ ៗ ព្រះបទុមវង្ស ឮថាស្តេចទ្រង់ ហៅខ្លួនប្អោះណា
អ្នកគង់ប្រើសមាស នុកាសថ្ងៃថ្វា ដូចពជសីហា នរនាថឥតក្អើក ៗ
តម្រួតទាហាន ចតុរង្គប៉ុន្មាន ហែប្រចិនពន្ទឹក ឡៀងក្ងស់បើកប៉ាំង ត្រែ
ស័ង្ខសន្ធឹក សេនាគគឹក ចោមហែកុមារ ៗ ព្រះបទុមវង្ស ថ្កុំថ្កើងពូជ

ពង្ស កណ្តាលសេនា ច្រើនគ្រឿងខ្ពង់ខ្ពស់ ច្រើនយសសក្តា ច្រើនរទេះ
គ្រឿងគ្រា អានុភាពស្ងប់ស្ងែង ៗ គង់លើប្រើសមាស ក្តីផ្ទុកឧកាស
ចិញ្ចាចចិញ្ចែន កន្ត្រាស្រៀវស្រស់ ខ្ពង់ខ្ពស់ឯកឯង ឆើតឆាយលើស
លែង កណ្តាលនគរ ៗ មហាជនទាំងឡាយ តាមមើលក្លួចកាយ
ស្ទាំងកាំងឈប់ឈរ មើលឃើញសេនា យោធាវិករ ពលពោលនិករ
ហោមរោមកុមារ ៗ តម្រួតពាហន ធ្វើដំណើរប៉ុន្មាន ហោមជាបរិវារ
មហាជនស្ងប់ស្ងែង គិតក្រែងក្សត្រា ធ្វើទោសកុមារ រូបរ័ត្នឆោម
ឆាយ ៗ ខ្វះរត់យ៉ាងខ្វាំង រលះរលាំង តាមមើលទៅឆ្ងាយ ដល់ទ្វារ
រាជវាំង ភ័យភាំងភយមាយ ក្លួចគិតសប្បាយ ដោយចិត្តស្នេហា ៗ
ព្រះបទុមវង្ស យាងចូលដល់ក្នុង វាំងហើយសួរថា សុវណ្ណពជព្រឹក្ស
ពន្ទឹកថ្ងៃថ្ងា តើទៅទីណា ជាជិតឬឆ្ងាយ ៗ អមាត្យប្រាប់ថា
សុវណ្ណព្រឹក្សា ទាំងគូឆើតឆាយ នៅទៀបប្រាង្គមាស ឧកាសក្តីសាយ
រាងត្បូងពុំឆ្ងាយ បន្ទំក្សត្រា ៗ បទុមវង្សស្តាប់ អមាត្យថ្លែងប្រាប់
សព្វគ្រប់ហើយណា ចុះពីប្រើសមាស យាងយាសយាត្រា ដើរដល់ក្រឡា
ទីចុងរោងរ័ត្ន ៗ ដល់ហើយអ្នកថ្វាយ បង្គំបកាយ គង់គាល់
មហាក្សត្រ ស្តេចយល់កុមារ សោភារូបរ័ត្ន ដួងក្រត្រូវផាត់ កប
នូវលក្ខណា ៗ ស្តេចពេញព្រះទ័យ ស្រឡាញ់ពេកក្រៃ ដូចសង្ខាក

ចុះពីទីនាំង បល្ល័ង្កអាសនា ព្រះហស្តប្រវ៉ា ឱបអង្គពជបុត្រ ៗ ថៃ
ថើបកេសា ហើយត្រាស់សួរថា ហៃកូនបរិសុទ្ធ ទ្រង់ឆោមនិមល
ដូចកល់ទេវបុត្រ លក្ខណាវិសុទ្ធ ស្ដួស្ដីសមកាយេ ៗ កូនអើយមាតា
នៃអ្នកយាត្រា មកផង៏ឬទេ អ្នកស្ដាប់ទុក្ករ ទូលថាអ្នកម៉ែ ពុំបានមក
ទេ សូមជ្រាបចិត្តា ៗ ស្ដេចត្រាស់សួរទៅ ហៃកូនពាលពៅ ទ្រង់
ឆោមឆាយា អាយុអ្នកបាន ប៉ុន្មានវស្សា ចូរប្រាប់បិតា ណាមាស
ឧត្តម ៗ កុមារទូលថា បានបីវស្សា អាយុនៃខ្ញុំ ស្ដេចគិតថាបើ
ប្រមើលឲ្យសម ប៉េតាមទំហំ សោឡសវស្សា ៗ កូននេះមានបុណ្យ
រឿងឫទ្ធិលើសលន់ រូបធំឧត្តមា ទើបត្រាស់សួរបុត្រ បរិសុទ្ធថៃថ្លា
ថានាមមាតា នៃអ្នកឈ្មោះអ្វី ? ៗ កុមារទូលថា នាមមាតា នោះ
ព្រះបត្រី ព្រះអង្គបានជ្រាប ដកបសេចក្ដី ស្ដេចសួរថាបី–តាអ្នកឯណា ៗ
កុមារបង្គំ ថាបិតាខ្ញុំ សោយរាជ្យនគរ នេះឯងអនេក ជាឯកពជា ស្ដេច
ថាបិតា អ្នកនុះឈ្មោះអ្វី ? ៗ កុមារទូលថា នាមព្រះបិតា ធិកជបក្រី
មាតាខ្ញុំប្រាប់ ដកបសេចក្ដី ស្ដេចសួរទៀតខ្ញុំ ថាឯមាតា ៗ អ្នក
ឲ្យទ្រព្យអ្វី មកជាសាក្សី សំគាល់ខ្លួនបា កុមារបានស្ដាប់ .សារសព្ទ
ទូលថា កាលព្រះមាតា ចេញចាកបុរី ៗ ជាសត្វសារិកា ទោះ
ព្រះបិតា ទ្រង់ប្រោសប្រណី ប្រទានទំរង់ រត្នធ្នំរង្សី ចាំងគួពីសី

ដាក់ដើមមាតា ៗ ទូលហើយអ្នកយក ព្រះទំរង់មក លើកថ្វាយ
ក្សត្រា ស្តេចទទួលរៃ ពីដៃកុមារ ទតហើយក្សត្រា ស្តេចស្គាល់
ជៀងជាក់ ៗ ជ្រាបក្នុងព្រះទ័យ ពុំមានសង្ស័យ សន្ធិះអន់អាក់
គិតថាកុមារ សោភាទ្រង់លក្ខណ៍ កូនទាងមរណៈ មាតាមែនពិត ៗ
ទើបស្តេចត្រាស់ថា ហៃកូនសង្ក្រា សំឡាញ់មាសមិត្រ មាតាអ្នកថ្លៃ
ប្រពៃស្នេហ៍ស្និទ្ធ ឥឡូវថេរបិត តំបន់បានណា ៗ ព្រះបទុមវង្ស
បានស្គាល់ស្តេចទ្រង់ សួរបានមាតា អ្នកទូលទៀតទៅ ដោយទូវសក្យា
ថាថានមាតា គង់ព្រៃហិមពាន្ត ៗ ស្តេចស្តាប់ថាអើ មាតាអ្នក
តើ នៅនិត្យបិតបាន ទីងអ្នកឯណា មេត្តានៃប្រាណ សព្វថ្ងៃតើ
បាន អ្វីបរិភោគ្គា ៗ រមូសស្រាំងស្រួយ ពិសពាស់ក្អុបខ្លួយ ម្រឹគ-
មហឹង្សា ទីងមានទៀបប្រាណ ទៀបបានមាតា ឬមួយសុខា
កាយជាឬទេ ៗ កុមារទូលថា ឯអ្នកមាតា សុខក្នុងកាយេ
សត្វម្រឹគពាលា ហឹង្សាគ្មានទេ សព្វថ្ងៃសោយតែ ផ្លែឈើមើមឈើ ៗ
អ្នកគង់នៅនិត្យ អាស្រមទៀបជិត ឥសីប្រសើរ អ្នកទ្រង់រាប់អាន ប្រ-
ពានសារពើ ផ្លែឈើមើមឈើ ឲ្យបរិភោគ្គា ៗ តាបសនោះឯង ចិត្តល្អ
គួរស្ងែង ទ្រង់សាងសីលា ស្តេចទ្រង់ស្តាប់ថៃ ពាក្យឯកុមារ ទូលទើប
ក្សត្រា ត្រេកទ្រង់អំណរ ៗ ស្តេចគិតថៃថា មរណមាតា នៅបរិសុទ្ធល្អ

ថ្មមានស្វាមី បក្រីស្លូត ដោយមានអំណរ ត្រាស់សួរទៀតថា ៗ
ហៃបទុមវង្ស កុមារទ្រើសទ្រង់ បុត្ររ័ត្នសង្ហារ មាតាអ្នកតើ ដំណើរ
ប្រការ ហេតុម្តេចឃ្លាតឃ្លា ពីបិតាទៅ ៗ ព្រះពជកុមារ បានស្តាប់
បិតា ត្រាស់សួរបោះកូវ ត្រូវដូចអ្នកគិត ពិនិត្យទុកនៅ គិតដោះ
ហ្មង់សៅ មន្ទិលមាតា ៗ ស្រេចហើយទូលទៅ បពិត្រព្រះពៅ បម
បក្រក្សត្រា មាតានិយាយ ប្រាប់ប្រាយខ្ញុំថា កាលដើមមាតា ជាកូន
កុដុម្ពិក ៗ ឯកុដុម្ពិកមាន ករិយាពីព្រោណ រួមសុខមួយទី ប្រពន្ធ
ចុងឈ្មោះ កាលីទីពីរ សម្លាប់ជននី មាតាខ្ញុំទៅ ៗ ចាប់ជាតិជា
ត្រី កាលីអប្រិយ វាប្រើកូនទៅ សម្លាប់ត្រីទៀត គង់ខ្ទៀតសល់
នៅ ស្រកាពីរកូវ ទេវអ្នកមាតា ៗ យកមកដាំចុះ រំពេចដាល
ដុះ ជាត្រប់ទ្វេហា កាលីលួចដក យកបោលអសារ សល់ប្ញសទ្វេហា
មាតាដាំបាន ។ ដុះជាព្រឹក្សា លេសសុវណ្ណា កាលនោះក្សត្រក្សាន្ត
ចេញទៅប្រពាត វុក្ខជាតិទូរដ្ឋាន យល់ឈើមាសមាន ស្មើជ្រះថ្លា ៗ
ស្តេចសព្វព្រះទ័យ ទើបមហាក្សត្រថ្លៃ សុំឈើនោះណា មាតាលើក
ថ្វាយ ឥតស្តាយសោះសា ស្តេចប្រើសេនា ជីកគាស់ពុំបាន ៗ
ទើបព្រះមាតា អញ្ជើញព្រឹក្សា រួចថ្វាយក្សត្រក្សាន្ត ព្រឹក្សាអណ្តែត
ត្រសែតលើឋាន អាកាសមកថ្កាន ដល់វាំងពុំលង់ ៗ ទើបព្រះមាតា

អញ្ចើញព្រឹក្សា បានចុះដល់ក្នុង អាងមាសរបនា ទើបបិតាទ្រង់ រៀប
ពេនរ័ត្នរុង អភិសេកមាតា ៗ ជាអគ្គមហេសី នៅបានឆ្នាំបី ព្រះវរ
បិតា ចេញប្រាបសត្រូវ ស្រុកក្រៅសីមា កាលបុស្សា លួងមាតាទៅៗ
ឲ្យជាន់ក្ដារយន្ត ភ្ជាត់ធ្លាក់លើសលន់ ក្នុងខ្ទះប្រេងក្ដៅ អ្នកក្ស័យជន្មា
កាលគ្រានោះទៅ កាលីយោរយៅ ចិត្តកាចបុស្សា ៗ យកឆ្អឹងអ្នកម្ដាយ
ចាក់ចោលអន្ទពយ ក្នុងព្រៃអសារ បានទេពទេវី នៅទីព្រឹក្សា ប្រស់
ប្រាណមាតា រស់ដូចប្រក្រតី ៗ ទើបទេពធីតា ឲ្យទុសថា លេប
ជាបក្សី ជាសត្វសារិកា ហោមកបុរី ឡើងគាល់ព្រះបិ- តាទ្រង់
មេត្តា ៗ ទើបព្រះពជា ស្ដេចឲ្យនៅនា ទ្រុងមាសរបនា នៅយូរ
ប្រមាណ បានមួយវស្សា ព្រះវរបិតា ចេញប្រាបសត្រូវ ៗ ឯក្រោយ
នោះមាន សាវឡឹកមួយប្រាណ ចិត្តកាចខ្ចីខ្វ ឈ្មោះនាងឆន្ទា ចំជា
សត្រូវ ខេរខឹងក្រញូវ ចាប់យកសារិកា ៗ បោចរោមជាប់ជាប ឆន្ទា
ចិត្តកាច មិនគិតអនិច្ចា ហើយទុកជិតខាង ទឹកអាងវេងថ្វា គ្រជាក់
កាយា ភ្ញាក់ដឹងស្មារតី ៗ ហើយក្រោកឡើងស្ទុះ ឈានដើរកៀរកោះ
ចឹកចាប់ឫស្សី រនាបបទ្វារ ហោតស្ទុះដល់ដី ចូលពួនក្នុងទី ស្ដេច
កណ្ដុរស ៗ កណ្ដុរមេត្តា រៀបឲ្យភោគ្គា ចំណីយ៉ាងល្អ អ្នក
នៅជពប រោមស្លាបដុះប- រិបូណ៌ហើយចរ ចាកចេញយាត្រា ៗ

ក្រែងឆន្ទាគេ ឃើញហើយនឹងយក មកចងទោសា លោកណាស
ចេញចរយាត្រា ដល់ដើមព្រឹក្សា ឈើធំមួយមាន ។ ហើយឃើញ
ស្តេចខ្លា ស៊ីផ្លែព្រឹក្សា ផ្លែកមួយបែរបាន ជាបក្សីធំ ស័ក្តិសមរូប
ប្រាណ ស៊ីផ្លែកមួយបាន ជាប្រើសមាសធំ ។ ផ្លែកមួយជាស្វា ផ្លែក
មួយកើតជា មនុស្សសួនសម ហើយនិម្មិតបាត់ សូន្យស្ងាត់ជ្រងំ
ទើបអ្នកហោរទំ ចឹកចាប់ផលា ។ ជាថ្នាំទិព្វថ្ងៃ គ្រប់ផ្លែកប្រពៃ ហើយ
ហោរយាត្រា ទៅដល់កុដី ឥសីស៊ីលា សន្មតនាមថា មិត្តាជិនជាក់
ទើបបរគេថ្នា ថ្នាំទិព្វកាលណា ប្រែប្រាណឥតអាក ជាមនុស្សដូច
មុន ល្អសល្អន់ទ្រង់លក្ខណ៍ គ្រាច់ដើរស្រែងស្ងាត់ តាមជងមាគា ។
ដើរដល់កុដី អាស្រមឥសី ចូលថ្វាយវន្ទា នៅនឹងឥសី បានបីទិវា
ឥសីមិត្តា- ជិនបរបុះស្រង់ ។ ទឹកស្រះរើសខ្ញុំ កុងផ្កាបទុម
ហើយនាំគ្រាច់គ្រង់ ឲ្យអ្នកមាតា ភេក្សយូរលង់ លុះធំពេញអង្គ
បានបីឆ្នាំហើយ ។ ឯព្រះជននី វេលាពត្រី សោកពុំមានស្បើយ
នកដល់កូត្រា ពុំមានភ្លេចឡើយ នឹកឈើមាសហើយ អ្នកសោយ
សោកា ។ ខ្ញុំយល់ជនទិ អ្នកកើតទុក្ខី ទុក្ខពាមនស្សា
កណ្តៀកណ្តោច គេមោចឯកា ផ្សាខ្លោចនឹក សង្រេងសង្រៃ ។
ខ្ញុំយកអាសារ មិនឲ្យមាតា កើតទុក្ខពេកក្រៃ ខ្ញុំគ្រាច់ដើរមក សួរគេ

ក្បត្រថ្ងៃ មើលឈើមាសថៃ ឲ្យដឹងកិច្ចការ ៗ ផ្សៀវព្រះអង្គ ក្បែមក្សត្រ បានទ្រង់ ឥតមានពេកា ឈើមាសទាំងគូ ដុះដួរសាខា សព្វគ្រប់ ប្រការ ពុំមានអន្តរាយ ៗ សូមលាក្សត្រក្សត្រ ទីងនាំពតិមាន ទៅ ប្រាប់អ្នកម្ដាយ កុំឲ្យអ្នកមាន ព្រួយប្រាណគិតឆ្ងាយ គិតក្សត្រឯនាយ ឲ្យស្បើយទុក្ខា ៗ ទើបស្ដេចយាត់ទៅ ហៃកូនពាលពៅ កុំគាល យាត្រា ចូរអ្នកឈប់ចាំ ទំពំបិតា កេណ្ឌពលសេនា ជូនអ្នកទៅផង ៗ ទើបស្ដេចតាក់តែង ប្រាង្គមាសចំពោង លួល្អះកន្ទង់ ហើយរើស កេងស្រី ប្រិមប្រិយមិត្តហុង ប្រាំរយឲ្យផង បំរើបុត្រា ៗ កេងប្រុស មួយពាន់ ថ្វាយជាកំណាន់ បទុមវង្សា តែងពេងមុខបួន សមសួន សោភា បំពមាសរចនា ប្រពានប្រើសមាស ៗ មានពលប្រាំរយ រែក ស្មៅដើយ ប្រក្រតីពេញពាស រើសរកស្មៅខ្ចី ចំណីប្រើសមាស គ្រាល ពេងទុកាស កន្ទួលបីជាន់ ៗ គ្រាលក្រោមស្ពាន់ស្ពាស កន្ទួលទុកាស ទង់ដៃងសំខាន់ ខាងលើគ្រាលប្រាក់ ឆ្នៅឆ្លាក់ច្រើនជាន់ ពួកពលកំណាន់ ផ្ទាស់គ្នារក្សា ៗ យាមយប់ដើរល្បាត តាមថៃព្រោងព្រាត ពេញពេង រចនា ពេលថ្ងៃលាងទឹក ពេលព្រឹករក្សា ឲ្យស្មៅភោក្តា ដាក់ទឹកផ្ទន មាស ៗ គាងមាសដាក់ទឹក ឲ្យប្រើសមាសផឹក ចេញអង្គទុកាស ព្រះ បទុមវង្ស អ្នកគង់ប្រាង្គមាស មន្ត្រីពស្ដេពាស ឡើងតាល់គ្រៀបត្រា ៗ

ព្រះបាទបពិត្រ វិមលទ្រង់ថ្កើង ឡើងសេនា ទាហានចតុរង្គ ប្រៀបប្រុង
អាត្មា ពលពលរថា គជេន្ទ្រអស្សេរ ៗ ពលថ្មើរជើងស្ទាត់ រូបកង់ធំ
ធាត់ ប្រុងប្រាណកាន់ករ កាន់គ្រឿងគ្រប់ដៃ រាងវៃឈានឈរ មាន
ចិត្តត្រេកអរ ចង់យល់ហឹមពាន្ធ ៗ ពលច្រើនគោឡា ប្រាំពីរអក្ខោ-
ភិនីបីមាន លុះបានឫក្សពារ ពេលាជោគញាណ ផ្ទុំត្រែស័ង្ខសាន
ប្រគំជន្ទ្រី ៗ ស្តេចយាងយាសគង់ គជេន្ទ្រវរម – ង្គលគាប់វង្ស សុទ្ធ
សឹងរចនា ជ្រះថ្លាវង្ស ខ្នុនណាងសាវស្រី សង់ជំងះសេះណា ៗ ព្រះ
បទុមវង្ស ពីលាឡើងគង់ ប្រើសមាសថៃថ្វា បេញជាទំពស្រួច គ្រង់ដួច
ទៀវខា នាំថ្ងៃបិកា នរទាបឥតក្រេង ៗ បើកបាំងអភិរម្យ គៀវកូស់គ្រស់ុ
ចាមស្បៀវសែង វីងទីជាយជាត់ (១)រូវ័ត្នចំពោង សូរសេពួកគ្រេង
ខ្ទរខ្ទាយពសុធា ៗ ឆ្លូលីផ្ទៃផ្ទៃព្រួ ហៃហូសត្រឡប់ ទ្រលោមព្យោមា
ស្រទំអាកាស ដេរដាសមេឃា ដោយបុទ្ធិសម្ភារ ព្រះបទុមវង្ស ៗ
ទង់ជ័យជាមុខ ប្រាលច្រើនគគុក ទាហានពលពង្ស ក្រោយនោះពលជួ
ប្រព័ទ្ធរៀណរង្គ ពលសេះទ្រទ្រង់ ស្ទុះស្ទាត់ក្ងៀវក្លា ៗ គជេន្ទ្រ
សារសឹក ខ្ញៀវខ្លាអធិក បន្ទាប់ក្សត្រា ពលថ្មើរប្រូងប្រាង សង់ខាង
មាគា ប្រាំជួរជិតគ្នា គ្រឿងគ្រប់ដោយដៃ ៗ ស្តេចលើកទាហាន
ចេញចាកពជដ្ឋាន សប្បាយក្សត្រថ្ងៃ ចូលព្រៃព្រឹក្សា សាខាត្រៃឈើ

---

១– រូ: ពាក្យបុរាណ ប្រែថា: ឆ្លូច, ឆ្លូចដា ៗ រូវ័ត្ន ប្រែថា: ឆ្លូចកែវ ៗ

ត្រុំឈឹងល្វឹងល្វៃ លូតលេចបុប្ផា ។ ឈើផ្កាទាំងឡាយ ដុះជិតពុំឆ្ងាយ តាមដងមាគ៌ា ម្លិះរត្នទួទស្រី ចំប៉ីចម្ប៉ា រំដួលក្តាំងផារ ខ្ទីងខ្ទម្ព មាលតី ។ ធត្រូតឈូករ័ត្ន ប្បាសែតច្រើនក្តាត់ ស្រឡិតស្រឡី សារ៉ាវុតមហាហង់ ប្រយង្គុកាកី កាកៃសពីសី រំចេកទន្សៃ ។ ឈើឈរធំ ៗ ដើមដុះជាំជុំ ជាម្លប់ដង្ហៃ ទីងចតទីងឈប់ បើយប់តាមតែ ដេកដោយសព្វកែ មិនព្រួយព្រោសផាត់ ។ ដ៏ពុំបស្នើធេង ស្នោស្នើរល្ងើង ស្អាតដូចគេខាត់ មិនស្ពៀចមិនស្អុះ ដេកចុះលក់ថ្ងាត់ មិនគិតខ្លាចសត្វ សាហាវពាធា ។ ព្រះពាយរំភើយ គ្រសៀកល្ហៃល្ហើយ មនោរមា ជាទីត្រេក ចិត្តត្រេកត្រប់ត្នា មានទីគន្ធាស្រះស្រង់រៀងទៅ ។ ឈូករ័ត្នពេញពាស ផ្ការីកដេរដាស ក្រអូបចាំនៅ ត្រីត្រាច់ហែបហែល ក្រាស់ក្រែលមកទៅ កងទឹកជ្រៅ ត្រីធំនរនាថ ។ សេនាពលពាល ត្រេកត្រេះត្រអាល ចាប់ក្ខុនរុក្ខជាតិ ពីដោរស្កប់ស្កល់ ដោយខ្យល់មន្ទូរ៉ាត សប្បាយក្ខុចញាតិ ក្ខុចបុត្រភរិយា ។ ព្រះបាទបពិត្រ ធិកជទ្រង់ថ្វី ស្តេចលើកយោធា ព្រះបទុមវង្ស ទ្រើសទ្រង់សំភារ អ្នកនាំមាគ៌ា ព្រះបិតាទៅ ។ ស្តេចយាងយូរថ្ងៃ ប្រាំដណ្ដប់ថ្ងៃ ទៀបទីលំនៅ អាស្រមមាតា ក្សត្រត្រាចមចៅ បញ្ឈប់ទ័ពនៅចម្ងាយប្រមាណ ។ ពីអាស្រមបទ បានមួយយោជន៍គត់ ដល់ទ័ពក្សត្រ

កំហុន្ត ព្រះបទុមវង្ស ស្តេចទ្រង់គិតច្បាន់ បញ្ជប់ពាហាន ទៀបទីគង្គា ។ ស្រះស្រង់ធំធ្លាយ ប្រវែងចម្ងាយ មួយយោជន៍គណនា អស់ពលរៀបឈប់ ដោយម្លប់ព្រឹក្សា រៀបបរិភោគ្គា ដោយតួទីទៃ ។ ព្រះបទុមវង្ស ស្តេចឡើងលាអង្គ បិតាជៀស្លជ័យ ទៅប្រាប់មាតា ទីងមហាឥសី កុំឲ្យគិតភ័យ ទីងពលសេនា ។ ព្រះបិតាស្តាប់ បុត្រពកប្រញាប់ ទៅឯមាតា ហើយទូលសារស័ព្ទ ប្រាប់ដោយប្រការស្តេចបើកបុត្រា ទៅតាមបំណង ។ កុមាររវាស ឡើងគង់ប្រើសមាស យាត្រាត្រាច់ត្រង់ ដល់ទីមាតា កុមារខុមអង្គ លុតលើកកំបង់ បង្គំមាតា ។ ទូលសព្វសេចក្តី នាងអរផគប់ ឥតឧបមា នាងនាំបុត្រទៅគាល់ហៀព្រះមហា ឥសីសីលា ទូលសព្វសេចក្តី ។ ថាត្បិតព្រះបាទវិមលនរនាថ ជាព្រះស្វាមី ស្តេចលើកយោធា សេនាមន្ត្រី ឈប់នៅស្រះស្រី នាទីបព្វតា ។ មកទទួលខ្ញុំ ទៅបុរីរម្យ វិទេហ៍រដ្ឋា ខ្ញុំលាព្រះអង្គ សូមទ្រង់មេត្តា ទៅសួរព្រះមហា ក្សត្រជាស្វាមី ។ ឥសីបានស្តាប់នាងទូលគួរគាប់ ទើបព្រះឥសី ថ្វាយព្រះពរថា បើមហាក្សត្រី ទៅសួរស្វាមី អាត្មាភាពអរ ។ នាងស្តាប់ឥសី បើកស្រួលក្សត្រី នាំបុត្រចេញចរទៅទទួលក្សត្រ ចក្រពត្តិបវរ ប្រើសមាសសោភចរ តាមក្រោយបុត្រក្សា ។ ក្សត្រីវរវង្ស នាងយាងពីអង្គ ទីងកពជបុត្រា ជល់ទៀបពួកពល សកល

សេនា ទើបមហាក្សត្រា ទតយល់ពីឆ្ងាយ ៗ ត្រាស់ប្រើសាវ៉ៃ ស្រីង្គារ ឆាប់រៃ រូតរត់ប្រញាយ ទទួលមហេសី ក្សត្រីឆោមឆាយ ស្នំស្និទ្ធទាំងឡាយ ទទួលធីតា ៗ ខ្លះថ្វាយទឹកអប់ ឲ្យនាងលាយលុប លាបលាងភក្ត្រា ខ្លះថ្វាយផ្កាក្រង កម្រងរចនា ខ្លះថ្វាយគន្ធា ព្រះស្រីជូនចន្ទ ៗ នាងស្រង់ទឹកអប់ រ៉ៃតន្ទូខលាយឡប់ ឯស្រីកំណាន់ ខ្លះដុសកាយា ភក្ត្រាសោភ័ណ ថ្វាដូចដួងចន្ទ បូណ៌មីចាំងវែង ៗ អក់រយាយខុនណាង យកគ្រឿងសំអាង រចនាទិព្វទេង រៀបស្អាងមហេសី ប្រិមប្រីមចរៃញូង ល្អល្អះឯកឯង ឯកអគ្គនារី ៗ ភក្ត្រាដូរផង់ រស្មីរលង់រលីងឆើវ បំព្រងព្រះខាត់ រូបវត្ថមណី នេត្រាទាំងទ្វី ដូចនិលរតនា ៗ ព្រះស្នំសំអាង ស្អាងរូបហៃនាង ឡើងគាល់ក្សត្រា នាងថ្វាយបង្គំ ប្រណម្យចេស្តា ហើយនាងធីតា គង់ទីគួរសម ៗ ស្តេចទតយល់ព្រះមហេសីល្អល្អះ ដួងកក្តិសក្តិសម ធើតឆាយលើសលន់ ល្វាសល្ងន់រម្យទំឡើងហៃសួនសម សមស័ក្តិលក្ខណា ៗ បំឡែកលើសមុខ ជារយពាន់គុណ ព្រោះសោយផលា ថ្នាំទិព្វថ្កើងថ្កាន ប្រែប្រាណធីតា ជាក្រមុំណា ល្អល្អះគួរស្នេហ៍ ៗ ស្តេចរៃងបេតី ស្រឡាញ់មហេសី ពេកក្រៃលើសលែង ដួងកក្ត្រពុំផា សោភាចរៃញូង រស្មីស្បូវសែង សួស្តីសមកាយា ៗ (នៅមានត)

# រឿងព្រេងនិងរឿងបុរាណជប៉ុនក្នុងមធ្យមសម័យ

លោក ភិយ-ប៊ុក ប្រែរៀបរៀង

(តមក)

នាងព្រាយក៏សួរទៅលោក អ៊ីតូសូជា ថា «ម្តេចក៏លោកមិនសម្រាន្តឲ្យលក់ដូចទាហានឯទៀត, ខ្ញុំឆ្ងល់ណាស់ ? ។ អ្វីនេះ. ឈាមហូរចេញពីក្បាលជង្គង់អ្នក ។

លោកអ៊ីតូសូជា ក៏តបទៅនាងព្រាយថា: «ខ្ញុំធ្វើឲ្យរបួសក្បាលជង្គង់ដោយចិត្តស្មោះស្ម័គ្រ ដើម្បីឲ្យសេចក្តីឈឺចាប់ដោយរបួសនោះធ្វើឲ្យខ្ញុំស្មារតីនៅបើកភ្នែកជានិច្ច, មិនឲ្យខ្ញុំដេកលក់ទៅបាន» ។

នាងព្រាយក៏ឆ្លើយតបទៅលោកអ៊ីតូសូជាថា «ខ្ញុំគួរសរសើរចំពោះអ្នកពន់ពេក; អ្នកឯងត្រូវតែគេកោតសរសើរពេញលក្ខណៈ» ។

លោកអ៊ីតូសូជា ក៏តបទៅវិញថា: «របួសនេះដូចជាស្នាមអេះប៉ុណ្ណោះ មិនត្រូវនិយាយទេ ! ខ្ញុំនឹងអាចបំពេញករណីយកិច្ចឲ្យបានប្រសើរជាងនេះទៅទៀត, បើចៅហ្វាយនាយលោកត្រូវការខ្ញុំ» ។

នាងព្រាយក៏ឆ្លើយមកវិញថា: «អ្នកឯងជាទាហាន គួរជាទិដ្ឋានុគតិដល់ទាហានទាំងឡាយ ហើយជាអ្នកបម្រើដការប្រកបដោយសុក្រិតភាព» ។

នាងព្រាយក៏ញញឹមទៅរកលោកអ៊ីតូសូដា យ៉ាងស្រស់ស្រាយសប្បាយក្នុងចិត្ត ទឹកមុខរីកសមដូចបុប្ផាត្រូវព្រះសុរិយាពេលបុព្វណ្ហ-សម័យ, ចិត្តព្រឺព្រួចកបស្នេហាគួរប្រាថ្នាពិស័យ រូបឆោមឆាយាស្រស់ប្រិមប្រិយ គួរស្ងួនទៅឧបកែវថ្មីមថ្ងៃ ។

នាងព្រាយក៏គិតថា "អញធ្វើឲ្យលោកអ៊ីតូសូដាបាក់ចិត្តទៅកាន់សេចក្តីស្នេហា ហើយនាងងាកមុខទៅរកព្រះអង្គម្ចាស់ នឹកក្នុងចិត្តថា: « តើព្រះអង្គយ៉ាងណាទៅ យប់នេះ» នាងព្រាយក៏ទទកាយរបស់ខ្លួនទៅលើព្រះអង្គម្ចាស់ ។

លោក អ៊ីតូសូដា ទប់ទល់បាននូវសេចក្តីស្នេហាចំពោះនាងព្រាយ, លោកក៏ក្រោកឡើងមកឃាត់ហាមនាងព្រាយ កុំឲ្យពាល់ព្រះអង្គម្ចាស់បាន ។ នាងព្រាយអស់តំរេះក៏ចេញពីក្រឡាព្រះបន្ទំព្រះអង្គម្ចាស់ទៅខាងក្រៅបាត់ទៅ ។

លុះដល់ពេលព្រឹក ពួកទាហានដែលយាមព្រះអង្គម្ចាស់ភ្ញាក់ពីនិទ្រាទាំងអស់គ្នាឡើង មានសេចក្តីកោតសរសើរទាហានអ៊ីតូសូដា ដែលស្ថិតនៅយាមពេញលក្ខណៈឥតបានដេកសោះឡើយ ដោយប្រើមធ្យោបាយថែក គឺធ្វើរបួសក្បាលជង្គង់នោះឯង, ហើយខ្លួនមានការអៀនអន់ស្រពន់-ចិត្តដោយមិនបានប្រើនូវមធ្យោបាយបែបនេះ ។

លោកអ៊ីតូស៊ូជា ក៏បានទៅកាន់គេហដ្ឋានលោកអ៊ីសាហាយ៉ាប៊ុយហៀន ទីប្រឹក្សាព្រះអង្គម្ចាស់ហើយ ក៏ជំរាបលោកអំពីរឿងរ៉ាវតាំងពីដើមឲ្យលោកជ្រាបសព្វគ្រប់ ។ លោកទីប្រឹក្សាក៏ថ្លែងនូវសេចក្ដីសរសើរចំពោះចាហ្វាងអ៊ីតូស៊ូជា ។ លោកទីប្រឹក្សាគិតក្នុងចិត្តថា ថ្ងៃនេះអញមុខជាបានទទួលរង្វាន់ដ៏ជាទីគាប់ចិត្ត ដោយតាំងពីដើមនាងព្រាយមិនបានទៅជិតព្រះអង្គម្ចាស់ ដោយចាហ្វាងអ៊ីតូស៊ូជាហាមឃាត់ ហើយព្រះអង្គម្ចាស់ទ្រង់ផ្ទំលក់ស្កប់ស្កល់, ទ្រង់តើនឡើងពាក់សយនា មានព្រះកាយពលសុខស្រួលពន់ពេក ។

ដល់ពេលយប់ស្អែក ចាហ្វាងអ៊ីតូស៊ូជា ក៏ត្រូវចាត់ឲ្យយាមទៀត ។ ដល់ពេលអធ្រាត្រស្ងាត់, ទ្វារក៏របើក, ស្រាប់តែមាននារីរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ ចូលមក (មានគេប្រាប់លោកអ៊ីតូស៊ូជាថា: នារីនោះ មាននាមឈ្មោះថា ព្រះនាងអូតូយ៉ូ ) ។

លោកអ៊ីតូស៊ូជា បានឃើញនាងព្រាយដែលខ្លួនសំគាល់ថា ព្រះនាងអូតូយ៉ូ ចូលទៅក្នុងក្រឡាព្រះបន្ទំព្រះអង្គ ។ តែដល់នាងឃើញចាហ្វាងអ៊ីតូស៊ូជា ស្ទុះមកឃាត់ហាមប្រាមនាងមិនឲ្យចូល, ក៏នាងថយចេញទៅក្រៅវិញទៅ, ឥតមានប៉ះពាល់ដល់ព្រះកាយព្រះអង្គឡើយ ។

ដល់យប់ក្រោយៗ មកនាងព្រាយលែងហ៊ានមកក្នុងក្រឡាព្រះបន្ទំ

ព្រះអង្គម្ចាស់ ។ ក៏ទ្រង់ធូលក់សុខព្រះកាយសប្បាយព្រះកជហ្ឫទ័យ ។ មួយទៀត ទាហានទាំងឡាយក៏លែងដេកលក់តទៅទៀត ។ ព្រះអង្គម្ចាស់ ទ្រង់លែងមានព្រះកជហ្ឫទ័យសោប់សល់ដូចយប់មុន ។ ព្រះសុខភាព ព្រះអង្គ ក៏ចម្រើនស្រួលតាមលំដាប់ ។

ទាហានអ៊ីតូសូជា ត្រូវបានព្រះអង្គម្ចាស់ទ្រង់ប្រោសព្រះកជតានឲ្យឡើងឋានន្តរស័ក្តិជានាយទាហាន ព្រមទាំងទ្រង់បំពេញព្រះកជអំណោយដ៏មួយកន្លែងជាកម្មសិទ្ធិរបស់ទាហាននេះ ដោយទាហានអ៊ីតូសូជា មានគុណូបការៈដ៏ធ្ងន់ចំពោះទ្រង់ ។

តែលោកអ៊ីតូសូជាយល់ថា ខ្លួនមិនទាន់បានបំពេញករណីយកិច្ចជាស្ថាពរនៅឡើយ ។ លោកក៏បានអញ្ជើញ ទៅជួបនឹងលោកទីប្រឹក្សាអ៊ីសាហាយ៉ាប៉ុយហ្សេន ក៏ជំរាបលោកថា :

"កល្យាណមិត្រ នឹងអ្នកដែលមានស្វាមីភក្តិនៃព្រះអង្គ នឹងមិនអាចទុកចិត្តបានថា ទ្រង់នឹងផុតពីភយន្តរាយនោះបានឡើយ " ។

លោកទីប្រឹក្សាប៉ុយហ្សេន ក៏យល់ព្រមតាមយោបល់លោក អ៊ីតូ-សូជា ។ ក៏បន្ថែមតទៅទៀតថា :

"ព្រះអង្គម្ចាស់ទ្រង់ប្រហែលជាត្រូវអំពើគេ ។ បើទាហានដែលយាមព្រះអង្គបេះតែដេកលក់ ប្រហែលជាមានហេតុអ្វីមួយ ដែលធ្វើស្ពាន

ភាពមនុស្សឲ្យទៅជាដូច្នោះបាន ។

លោកប៉ុយហ្សេន ក៏តបទៅលោកអ៊ីតូសូជាថា «គឺពិតប្រាកដដូចលោកថា» ។

លោកអ៊ីតូសូជា ក៏ពោលតទៅទៀតថា «ក្នុងពេលដែលខ្ញុំបាទយាមល្បាតព្រះអង្គម្ចាស់, មានតែនារីម្នាក់ទេ ដែលចូលទៅក្នុងក្រឡាព្រះបន្ទំទ្រង់ គឺព្រះនាងអូតូយ៉ូ[១] ។ កាលណាព្រះនាងនេះលែងយាងទៅកាន់ក្រឡាព្រះបន្ទំព្រះអង្គ ៗ ក៏ផ្ទំលក់ស្រួល លែងមានអាកប្បកិរិយាសោបសល់ដូចមុនៗទៀត ។ ខ្ញុំបាទមានសេចក្តីព្រួយបារម្ភជាខ្លាំង ដោយខ្ញុំបាទចោទប្រកាន់លើនារី ដែលទ្រង់សព្វព្រះរាជហឫទ័យ ។ តែខ្ញុំបាទគ្មានអ្នកណាសង្ស័យ ក្រៅពីព្រះនាងនេះទេ ។ ពួកព្រាយសាចដែលជាហេតុនាំឲ្យកើតអាការរោគ ប្លែកពីធម្មតាចំពោះព្រះអង្គ គឺនាងនេះឯង ។

លោកបព្រឹក្សអ៊ីសាហាយ៉ាប៉ុយហ្សេន ក៏ពោលពាក្យតិចៗថា

---

១– យោបល់អ្នកប្រែលោក អ៊ីតូសូជា មិនបានដឹងថា: ឆ្មាខ្មៅនោះវាពិឃាតព្រះនាងអូតូយ៉ូយកទៅកប់ក្នុងទីស្ងាត់ទៅហើយ ហើយវាប្រែក្រឡាខ្លួនវាជាព្រះនាងអូតូយ៉ូ ។ ឯឆ្មាខ្មៅ–ជ្រឹងពាក្យបារាំងថា: chat, vampire ត្រូវយល់ថា vampire ប្រែជាភាសាខ្មែរថាជ្រឹង ជាពួកសត្វរត្តិចរឬរាត្រីចរដែលរកស៊ីតែពេលយប់, ជាចម្មបក្សី (chéiroptéres) ដែលមានស្បែកខ្លួនវែងទៅជាស្លាប, ហើយតែងជញ្ជក់ឈាមសត្វនិងមនុស្សដែលដេកលក់ ។ ព្រោះហេតុដូច្នេះ នារីនេះមានរូបរាងជាឆ្មាខ្មៅ តែមានលក្ខណៈជាបក្សាជ្រឹង គឺបេះជញ្ជក់ឈាមធ្វើឲ្យមនុស្សថមថយកំឡាំង ។

« ខ្ញុំជឿជាក់ណាស់ដែរ . . . ខ្ញុំខ្វាចណាស់ចំពោះរឿងនេះ ។ មិនអីទេ លោក ចាំខ្ញុំសួរយោបល់លោកទីប្រឹក្សាឯទៀតសិន, ចូរលោកអញ្ជើញមកជួបនឹងខ្ញុំម្ដងទៀត, ពេលស្អែក ។

ដល់ពេលស្អែក,. លោកទីប្រឹក្សាអីសាហាយ៉ាប៊ុយហេង្ស ក៏ប្រាប់លោកអ៊ីតូសូជាថា «លោកបានសួរដោយសម្ងាត់ចំពោះពួកលោកទីប្រឹក្សាឯទៀតៗ ក៏យល់ស្របនឹងយោបល់លោកនឹងខ្ញុំហើយ, គឺព្រះនាងអ៊ូតូយ៉ូនេះឯង ជាបុព្វហេតុនៃអាការរោគព្រះអង្គម្ចាស់ ។

លោកអ៊ីតូជាក៏ពោលថា "ដើម្បីនឹងធ្វើឲ្យព្រះអង្គម្ចាស់មានព្រះសុខភាពដ៏ពេញលេញឡើងវិញ ត្រូវតែសម្លាប់មេព្រាយនោះចេញ ។ សូមលោកទីប្រឹក្សាមេត្តាអនុញ្ញាតឲ្យខ្ញុំបាទសម្លាប់មេព្រាយនេះចុះ ខ្ញុំបាទនឹងសម្លាប់ភ្លាម ក្នុងពេលថ្ងៃនេះ, សូមតែព្រះតេជព្រះគុណ ចាត់ឲ្យជាក់តាហានយាម ៨ នាក់ចំពីមុខទ្វារបន្ទប់វាំ កុំឲ្យវារត់រួច ។

ដល់សាយណ្ហសម័យ, លោកអ៊ីតូសូជា ក៏បានទូលព្រះនាងអ៊ូតូយ៉ូថា លោកនឹងយកប្រអប់តូចមួយ ដែលមានព្រះសារលិខិតព្រះអង្គម្ចាស់មកថ្វាយព្រះនាង ។ គេក៏អនុញ្ញាតឲ្យលោកអ៊ីតូសូជា ចូលទៅជួបនឹងព្រះនាងអ៊ូតូយ៉ូ ។

ព្រះនាងអ៊ូតូយ៉ូទ្រង់មានបន្ទូលថា: ចូរលោកឲ្យប្រអប់នោះមកខ្ញុំ ...

ខ្ញុំសូមឲ្យតែព្រះអង្គម្ចាស់ជាទីស្នេហារបស់ខ្ញុំ កុំឲ្យមានអាការរោគតទៅទៀត . . . ។

លោកអ៊ីតូសូជា ក៏តបទៅព្រះនាងអូតូយ៉ូថា "ព្រះអង្គម្ចាស់ឥតមានរោគាពាធអ្វីសោះឡើយ . . .តែសូមព្រះនាងទ្រង់ទតព្រះសារលិខិតព្រះអង្គ រួចឲ្យព្រះនាងឆ្លើយទៅព្រះអង្គឲ្យឆាប់" ។

គង់ពេលដែលព្រះនាងអូតូយ៉ូកំពុងបើកប្រអប់នោះ លោកអ៊ីតូសូជា ក៏ហូតដាវគ្រវីក្វម ។ តែព្រះនាងអូតូយ៉ូក៏ក្ដាក់បានព្រះខ័នមានដងស្រោបមាស ហើយក៏តយុទ្ធជាមួយនឹងលោកអ៊ីតូសូជា ។ ព្រះនាងមានបន្ទូលខ្លាំងៗថា "ម្ដេចឯងហ៊ានតយុទ្ធនឹងស្ត្រីក្នុងព្រះបរមរាជវាំង ហើយជាស្ដ្រីសំណប់ព្រះអង្គម្ចាស់ថែមទៀត អញនឹងដេញឯងចេញពីព្រះបរមរាជវាំងៗ

លោកអ៊ីតូសូជា ក៏យកដាវគៀសព្រះខ័នព្រះនាងធ្លាក់ហើយក៏កាត់ក្បាលព្រះនាងអូតូយ៉ូបាន ។

ស្រាប់តែនៅលើផែនដី, មិនមែនជាសាកសពស្ដ្រីប្រែទៅជាសាកសពឆ្មាខ្មៅធំ ដែលមានក្បាលដាច់ពីខ្លួនទៅវិញ, ឆ្មាខ្មៅ-ជ្រីនដែលរាល់យប់ វាមកជញ្ជក់ព្រះលោហិតព្រះអង្គម្ចាស់ណាបេស៊ីម៉ា ហើយមានតែលោកអ៊ីតូសូជាទេ ដែលជាអ្នកធ្វើឲ្យព្រះសុខភាព ព្រះអង្គបានស្រួលដូចដើមវិញ ។

# អធិប្បាយសុភាសិត

## ទំពក់វាទៅ ទើបល្ពៅវាជ្រុះ

លោក ស្ដើង-ធូ រៀបរៀង

លោក ឧត្ដមប្រីជា ជាប-ពិន ពិនិត្យ

---

## សេចក្ដីអធិប្បាយ

ដើម្បីញុំាងចរិយានៃពពួកជនណាដែលខ្ជិលច្រអូស ក្នុងកិច្ចសិក្សារៀនសូត្រ ក្នុងការងារសព្វសារពើ, កុំឲ្យដេកចាំព្រេងវាសនាជូនផលមកឲ្យនោះ ចាស់ទុំបរមបុរាណ បានចងក្រងជាភាសិតមួយបទទុកក្រើនរលឹកជនទាំងនោះថា: "ទំពក់វាទៅ ទើបល្ពៅវាជ្រុះ" ។

តាមអត្ថានុរូប ភាសិតនេះ បានប្រាប់ន័យយ៉ាងជាក់ច្បាស់មកយើងរួចស្រេចទៅហើយ គឺផ្លែល្ពៅដែលជាប់នៅនឹងសណ្ដាន់នៅឡើយ មិនអាចនឹងជ្រុះមកចូលក្នុងកញ្ជើរបស់យើង នៅពេលដែលយើងគ្រាន់តែហាមាត់និយាយថា: ចង់បានផ្លែល្ពៅ ៗ នោះទេ ។ ដូច្នេះ, បើយើងចង់បរិភោគផ្លែល្ពៅ ត្រូវតែយើងយកទំពក់ទៅថ្កក់បេះវាទើបបាន បើពុំនោះសោតទេ ច្បាស់ជាយើងអង្គុយលេបទឹកមាត់ផ្អួស ៗ ពិតប្រាកដ ។

តាមអត្ថប្បដិរូបវិញ ភាសិតនេះមានន័យថា: បើយើងចង់បានផល

អ្វីមួយ ៗ ដូចជាប្រាថ្នាទ្រព្យសម្បត្តិឲ្យបានបរិបូណ៌ហូរហៀរ ដើម្បីធ្វើជាសេដ្ឋីគហបតីក្តី ឬប្រាថ្នាវិជ្ជាជ្រៅជ្រះ ដើម្បីបានធ្វើជាមន្ត្រីធំដុំទីទីគេក្តី, យើងមិនត្រូវដេកចាំព្រេងវាសនា ឬ បន់ស្រន់បួងសួងព្រះអាទិទេពឲ្យមកជួយយើងនោះទេ, យើងត្រូវខំខ្នះខ្នែងប្រើកម្លាំងកាយ ចិត្ត-បញ្ញាព្យាយាមរៀនសូត្រ, ធ្វើការងារសព្វសារពើទាំងអស់ ដើម្បីថ្កក់យកផលដែលយើងប្រាថ្នានោះ ៗ បើពុំដូច្នោះទេ ផលនោះមិនអាចផ្តល់ ហុចផលប្រយោជន៍ឲ្យយើងបានឡើយ ៗ សេចក្តីនេះសមដូចសុភាសិតសំស្ក្រឹតមួយបទថា:

ការងារតែងសម្រេចដោយព្យាយាម
ពុំមែនបានតាមបំណងថា
ម្រឹគពុំដែលចូលក្នុងមាត់សីហា
កាំពុងនិទ្រាលង់លក់នោះឡើយ ៗ

សេចក្តីថា ចំណេះវិជ្ជា ការងារសព្វសារពើទាំងអស់សម្រេចបានដោយសេចក្តីព្យាយាមធ្វើ, ព្យាយាមរក, ព្យាយាមសិក្សារៀនសូត្រតែប៉ុណ្ណោះ, មិនមែនយើងដេកចាំ ឲ្យទ្រព្យសម្បត្តិចំណេះវិជ្ជាហូរចូល ដោយឥតបានព្យាយាមរក, ព្យាយាមសន្សំសន្សៃ ព្យាយាមរៀនសូត្រនោះនោះឡើយ ៗ បើប្រាសចាកសេចក្តីព្យាយាមអស់ហើយ គេចំណេះវិជ្ជា

ទ្រព្យសម្បត្តិ ខឹងសម្រេចឲ្យយើងប្រើប្រាស់ដូចម្តេចបាន ? ព្រោះហេតុហ្នឹង បានជាបុរាណចារ្យ លោកបានចងក្រងជាពាក្យប្រៀនប្រដៅមានច្រើនបែបច្រើនយ៉ាង ទុកដាស់តឿនក្រើនរំលឹកកូនចៅក្រោយ ៗ ជាកុំឲ្យខ្ជិលច្រអូស ឲ្យខំរកស៊ី ឲ្យខំរៀនសូត្រទើបកែខ្លួនរួចអំពីក្រ ទៅជាមាន, អំពីល្ងង់ខ្លៅ ទៅជាអ្នកចេះដឹងជ្រៅជ្រះ, អំពីពាល ទៅជាបណ្ឌិត, អំពីហីនភាព ទៅជាឧត្តមភាព; អំពីទាសភាព ទៅជាកុដិស្សភាពបាន ៗ

ឧទាហរណ៍:

មានសេចក្តីដំណាលថា: មានត្រកូលមួយមានកូនប្រុសម្នាក់ ជាត្រកូលទីទ័លក្រយ៉ាងក្រៃលែង ៗ ក្នុងកាលកុមារជាបុត្ត មានវ័យវឌ្ឍនាការចំរើនឡើង មាតាបិតាក៏បានទៅស្តីដណ្តឹងនាងកុមារិកាម្នាក់ឲ្យជាភរិយា ៗ ត្រកូលទាំងពីរនេះ បានរៀបអាពាហ៍ពិពាហ៍មង្គលការបុត្តធីតារួចស្រេចហើយ ក៏គ្មានបានចែកកេរ្តិ៍មត៌កអ្វីជាសំខាន់ ដើម្បីឲ្យបុត្តធីតាប្រកបអាជីវកម្ម តាមសភាពជាអ្នកស្រុកសោះឡើយ ៗ មាតាបិតាខាងស្វាមីបានចែកឲ្យតែ ១ ឆ្កែ១, មាតាបិតាខាងភរិយាចែកឲ្យស្វា ១ ប៉ុណ្ណោះ ៗ គូស្វាមីភរិយា លំបាកវេទនា ក្នុងចិត្តកើតទុក្ខព្រៀមក្រំយ៉ាងក្រៃលែង មិនដឹងគិតរកឋេរអ្វីចិញ្ចឹមជីវិតបាន ៗ

ថ្ងៃមួយ បានប្រឹក្សាគ្នាថា: បើយើងនៅក្នុងទីនេះតទៅទៀត ឃើញ

ជារឹតតែលំបាកឡើង ព្រោះយើងគ្មានគ្រឿងមតិកអ្វីនឹងប្រកបរបរចិញ្ចឹមជីវិតសោះ ៗ ដូច្នេះ, យើងគិតចេញទៅរកទីកន្លែងណាមួយ ដើម្បីប្រកបរបររកស៊ីតាមសម្មាអាជីព ៗ គិតស្រេចហើយ ក៏ស្រុះស្រួលមូលមតិគ្នារៀបចំអីវ៉ាន់វេចជាសម្ពាយរៀបចេញទៅ ៗ មុននឹងចេញទៅ បុរសប្តីបាននឹកដល់គុណព្រះទេពព្រៃ និយាយនឹងពពៃថា: "បើទីកន្លែងណាដែលត្រជាក់ត្រជុំ រកស៊ីទៅមានបានកើតកាលវាលគុម្ព, បានសេចក្តីសុខ-ចំរើននោះ សូមឲ្យពពៃដែលជានិមិត្តនេះ ឈប់នៅត្រង់ទីនោះ" ហើយលែងពពៃនោះទៅ ៗ បុរសប្តីបណ្ដើរឆ្កែ នាងភរិយាបីស្វាដើរតាមទាន់ក្រោយពពៃដែលលែងទៅមុខ ៗ ពពៃចេះតែបោលទៅៗ កាត់វាលចូលព្រៃ លេចព្រៃចូលវាល សែនឆ្ងាយដាច់ស្រយាល លុះទៅដល់កន្លែងមួយ នាមាត់ស្ទឹង ដែលមានទឹកមានស្មៅគ្រប់គ្រាន់ ជាទីមានព្រៃឈើដុះស្រោងស្រឹងស្ងាត់ជ្រងំ កណ្ដាលអារណ្យប្រទេស ពពៃក៏ឈប់ផឹកទឹក ស៊ីស្មៅតាមស្រួល ៗ បុរសប្តីប្រពន្ធក៏សន្និដ្ឋានថា "ទីព្រៃនេះហើយ ជាទីមានសុភមង្គលល្អ" ព្រោះពពៃបានឈប់នៅទីនេះ ៗ

បណ្ដាប្តីប្រពន្ធទាំងពីរនាក់នេះ, ប្តីស្រឡាញ់ពពៃនឹងឆ្កែ, ប្រពន្ធស្រឡាញ់ស្វាណាស់ ព្រោះសត្វទាំងនេះសុទ្ធតែគ្រឿងមតិករបស់ខ្លួន ៗ ៗ ទាំងពីរនាក់ ក៏ដាក់សម្ពាយចងស្វាស្រួលបួលហើយ, ប្តីក៏ទៅកាប់ឈើ

ឆ្កាព្រៃពនដី ដើម្បីទីដាំស្រូវយកផល ៗ ឈើណាដែលល្អ ៗ គ្រាន់បើ ក៏រើសជញ្ជូនយកមកធ្វើខ្ទមបង្ហា ជាជម្រកនៅសំណាក់ក័កអាស្រ័យរបស់ខ្លួនកណ្ដាលព្រៃនោះ ៗ ប្រពន្ធនៅចាំខ្ទមដាំបាយ បោសច្រាសសំអាតទីលំនៅឲ្យបានស្អាតល្អ ៗ រៀងរាល់ថ្ងៃ, គ្រួសារថ្មីនេះឥតមានទុកកាយរបស់ខ្លួន ដែលនៅកំពុងពេញកម្លាំងពលំឲ្យនៅទំនេរឥតប្រយោជន៍សោះឡើយ ៗ ប្ដីទៅស្រែ បាចទឹកដាក់ស្រូវ, ប្រពន្ធនៅផ្ទះរៀបចំទីលំនៅឲ្យបានប្រសើរ ៗ ទោះបីខ្ទមតូចមួយរបស់នាង ដែលសង់ឡើងអំពីកូនឈើប្រក់ស្លឹកគ្នាត នៅកណ្ដាលព្រៃដូច្នោះក៏ដោយ ក៏នាងចេះកែច្នៃលលករៀបចំឲ្យទាល់តែខ្ទមនោះ ក្លាយទៅជាគ្រឹះស្ថានមួយយ៉ាងប្រសើរ គួរជាទីពិតពិលរមិលមើលនៃអ្នកផងទាំងពួង ៗ អ្នកទាំងពីរស្រឡាញ់គ្នាណាស់, ថ្វីបើម្នាក់ ៗ ខំធ្វើការពេញ ៗ មួយថ្ងៃ, មានការនឿយហត់យ៉ាងណាក៏ដោយ ក៏នៅតែមានសេចក្ដីស្រស់ស្រាយរួសរាយញញឹមញញែមរកគ្នាជានិច្ច ឥតចេះប្រកែកប្រច័ណ្ឌនិយាយគំរោះគំរើយ ទាស់ទែងខ្វែងគំនិតគ្នាសោះឡើយ ៗ

មានរាត្រីមួយ ជារាត្រីអពមង្គលអស្ចារ្យ; ក្រោយដែលគាត់ធ្វើការនឿយហត់អស់កម្លាំងពីពេលថ្ងៃ គាត់ក៏និទ្រាលង់លក់ស្កប់ស្កល់ឥតភម្រើក ៗ យប់នោះមានសត្វខ្លាចង្រៃមកចាប់យកពៃរបស់គាត់ដែល

វាដេកនៅក្បែរខ្ទម យកទៅស៊ីជាអាហាររបស់វាបាត់ទៅ ។ គាត់ភ្ញាក់ឡើង រកពពែមិនឃើញ មានសេចក្ដីតក្កមាតន់ពេក ។ គាត់ខំដើររកសព្វទី កន្លែងដែលពពែធ្លាប់រកស៊ីរាល់ថ្ងៃ ដើររហូតទៅដល់មាត់ស្ទឹងដែលពពែ ធ្លាប់ផឹកទឹកក៏មិនឃើញ ស្រាប់តែឃើញស្នាមជើងខ្លាយ៉ាងធំៗ នៅត្រង់ កន្លែងពពែដេក ។ គាត់ដឹងច្បាស់ថា ពិតជាខ្លាចាប់យកទៅស៊ីហើយ ។ ដូច្នេះ, គាត់ក៏មកនិយាយប្រាប់ប្រពន្ធថា "ពពែយើងពិតជាខ្លាចាប់យក ទៅស៊ី, ព្រោះខ្ញុំឃើញស្នាមជើងវាធំៗ នៅត្រង់កន្លែងពពែដេក បើប្រ សិនណាជាយើងមិនរកឧបាយកលព្យាយាមចាប់សម្លាប់វាឲ្យបានទេ, ថ្ងៃ ក្រោយវាចាប់ឆ្កែនិងស្វារបស់យើង រហូតដល់ចាប់យើងទាំងពីរនាក់យក ទៅស៊ីជាអាហាររបស់វាទៀតមិនខាន" ។ មួយរំពេចនោះ, គាត់ក៏ទៅ កាប់ឈើយកមកធ្វើអង្គប់ ដើម្បីដាក់ខ្លាប្រហារជីវិតវាឲ្យបាន ។ លុះ ធ្វើរួចស្រេចក៏គិតថា« បានអ៊ីហ្នឹ៎ ! នឹងយកធ្វើនុយឲ្យខ្លាវាចូល, បើយក ឆ្កែទៅឃើញថាអាណិតវាខ្លាំងពេក ព្រោះឆ្កែនេះជាទីស្រឡាញ់ ហើយ ជាកេរ្ដិ៍មត៌កនៅសល់តែមួយនេះផង ។ គាត់ក៏ទៅនិយាយអង្វរល្បួងលោម ករិយាថា«អូនជាទីស្រឡាញ់ ! ឥឡូវបងធ្វើអង្គប់រួចស្រេចហើយ, នៅ ខ្វះតែនុយទៀតប៉ុណ្ណោះ, ដូច្នេះ សូមអូនឲ្យស្វាមកបង ១ នឹងយកទៅ ធ្វើនុយឲ្យខ្លាវាចូល, បើអូនទុកស្វានេះទៅក៏ពុំសូវបានផលអ្វីដែរ" ។ ទោះបើ

ប្តីគង្វាលលួងលោមដោយពាក្យផ្អែមល្ហែមយ៉ាងណា ក៏ប្រពន្ធមិនព្រមឲ្យសោះ ៗ គាត់ក៏កាត់សេចក្តីអាណិតចំពោះឆ្កែ, ចាប់ឆ្កែយកមកឱបថើប ហើយនិយាយទាំងអាក់អួលថា "ឱ! ឆ្កែជាទីស្រឡាញ់របស់អញ, អញស្រឡាញ់ឯងណាស់, អញគ្មានចង់ឲ្យឯងឃ្លាតចេញអំពីបេះដូងរបស់អញទេ, តែពេលនេះ បើឯងមិនអាណិតជីវិតអញផង អញត្រូវតែស្លាប់, ព្រោះសត្វខ្លាវាចេះតែមកយាយីជីវិតអញរាល់ទិវារាត្រី, ដូច្នេះអញសុំយកឯងទៅចងនៅក្នុងអង្គប់ ធ្វើជានុយ ឲ្យខ្លាវាចូលមក អង្គប់នឹងថ្ងស់ជាប់វាមិនខាន ៗ ហេតុនេះ, ជីវិតឯងត្រូវតែស្លាប់ជំនួសជីវិតអញ ៗ ឱ! ទេវតាអើយ សូមលោកមេត្តាជួយជីវិតឆ្កែរបស់ខ្ញុំយ៉ាងណា កុំឲ្យខ្លាចូលមក ហើយអង្គប់ថ្ងស់មានគ្រោះថ្នាក់ដល់ជីវិតឆ្កែរបស់ខ្ញុំឡើយ" ៗ លុះនិយាយរួចស្រេច ក៏ថើបឆ្កែនោះ ហើយដឹកទៅចងនៅក្នុងអង្គប់; ប្រមាណជាពាក់កណ្តាលអធ្រាត្រ, ខ្លាដែលធ្លាប់តែរកស៊ីបាននៅកន្លែងនោះក៏មកដល់, ដើរក្រឡឹងអង្គប់បីជុំហើយចូលទៅចាប់ឆ្កែនៅក្នុងអង្គប់ ៗ ក៏ថ្ងស់សង្កត់ខ្លាជាប់ ៗ ចំណែកខាងឆ្កែ, ដោយគុណានុភាពនៃមេត្តាចិត្តរបស់ម្ចាស់ ក៏បានរួចរបូតពីគ្រោះថ្នាក់ បោលតម្រង់មករកខ្ទមម្ចាស់វិញ, ម្ចាស់ឃើញឆ្កែរួចមក មានសេចក្តីត្រេកអរណាស់ ស្ទុះទៅថើបឆ្កែដោយសេចក្តីស្រឡាញ់ទាំងសេចក្តីនឹកអាល័យ ៗ ទាំងពីរនាក់

ប្តីប្រពន្ធ ក៏យកលំពែងស្ទុះរត់ទៅចាក់ខ្លា នៅក្នុងអង្គប់ស្លាប់ទៅ ។ មួយរំពេចនោះ យកខ្មោចខ្លាមកពន្លះយកស្បែកទុកលក់ ។

ពីរបីថ្ងៃក្រោយមក បុរសប្តីក៏លាប្រពន្ធយកស្បែកខ្លាទៅលក់ឯផ្សារដែលតាំងនៅឆ្ងាយ ដាច់សង្វែងពីដីរបស់ខ្លួន ។ មុននឹងចេញទៅបាននិយាយផ្តែផ្តាំប្រពន្ធឲ្យមើលថែទាំផ្ទះសម្បែង, មើលបាបកុំឲ្យស៊ីស្រូវក្នុងស្រែ ដែលកំពុងតែទុំស្រគាល, ហើយជាពិសេស ឲ្យមើលឆ្កែទីងស្លាផង ។ ប្រពន្ធទទួលបណ្តាំហើយ រៀបចំបាយសំណុំទឹកបំពង់ឲ្យប្តីរួចស្រេចផ្តាំថា «បើបងលក់ស្បែកខ្លានេះដាច់ សូមទិញ "សា គាត" ឲ្យខ្ញុំមួយផង» ។ ប្តីក៏យកស្បែកខ្លាពុនរែកដាក់លើស្មា ដើរតម្រង់ទៅរកទីផ្សារដែលខ្លួនមិនធ្លាប់ស្គាល់សោះ គ្រមង់គ្រមោចលទ្ធងលទ្ទោចតែម្នាក់ឯងគាត់វាលចូលព្រៃ កាត់ព្រៃចូលវាលត្រាតែដល់ផ្សារ ជាទីប្រជុំជនមានមនុស្សម្នាច្រើន ។ ដល់ហើយ ដាក់លក់ក្បែរគេឯង នៅក្នុងផ្សារ ។ មានជនជាតិស្បែកសម្នាក់បានមកទិញយកស្បែកខ្លានោះទៅ ដោយឲ្យថ្លៃ ៤៥ រៀល ។ បុរសនេះមានសេចក្តីត្រេកអរណាស់ប្រញាប់ប្រញាល់វិលមកផ្ទះវិញ យកប្រាក់នោះមកបង្ហាញប្រពន្ធ ។ ក៏មានសេចក្តីត្រេកអរយ៉ាំងមហិមា ព្រោះខ្លួនមិនធ្លាប់មានប្រាក់ច្រើនដល់ម្លេះ ។ ដោយសារតែគាត់ជាមនុស្សទើទ័លក្រក្រៃពេក បានប្រាក់មកហើយគេកន្ទង់

ទុកដាក់មិនបាន ទើបយកប្រាក់នោះទៅដាក់ក្នុងកូនស្បោងតូចមួយព្យួរទៅលើជើងក្រានបាយ ៗ រាត្រីមួយ, ដេកទៅយល់សប្តិឃើញសក្កទេវរាជមកប្រាប់ថា "អ្នកឯងត្រូវខំរកស៊ី កាន់ធម៌សាមគ្គីឲ្យខ្ជាប់ខ្ជួនចំពោះគ្នានឹងគ្នា កុំចាស់ទែងខ្វែងគំនិតគ្នា, យូរទៅ នឹងបានឡើងជាអ្នកមានស្តុកស្តម្ភមាំមួនមិនខាន" ៗ

ក្រោយមក គាត់ក៏ខំរកស៊ីធ្វើការទ្វេឡើងទៀតឥតមានទំនេរសោះឡើយ ៗ កាលបើស្រូវនោះទុំអស់ហើយក៏ច្រូតកាត់បែនបោក ប្រកជង្រុក ប្រកស្បោងទុកដាក់តាមធម្មតា ៗ

រដូវក្រោយមក គាត់ខំទៅកាប់គាស់កកាយឆ្កាព្រៃ ពនដីថែមទៀត ដើម្បីឲ្យស្រែនោះបានរីកធំឡើងលើសមុន, រួចធ្វើភ្លឺឲ្យមាំ, បាក់ជីរ, បាចទឹកដាក់ស្រែ ឥតមានឈប់ឈរ ៗ គាត់កាប់ឈើយកមកធ្វើនង្គ័លរនាស់, បានគ្រឿងឧបករណ៍សព្វគ្រប់ នៅខ្វះតែក្របីគោប៉ុណ្ណោះ ៗ គួរអនិច្ចាបុរសកំសត់ពីរនាក់ប្តីប្រពន្ធនេះពេក, បុរសប្តីអ្នកអូសនង្គ័លធ្វើភ្នែកក្លុះ ៗ ឃើញតែទឹកភ្នែកទឹកសម្បោរហូរហៀរ,ប្រពន្ធកាន់កន្ទុយយាមជាអ្នកបរនង្គ័ល តាំងពីព្រឹកដល់ថ្ងៃត្រង់, មុខមាត់ខ្លួនប្រាណរបស់គាត់ ប្រឡាក់ពាសដាសដោយភក់ល្បាប់ មានសេចក្តីទុក្ខលំបាកវេទនាយ៉ាងក្រៃលែង ៗ គាត់ខំបង្ហូរញើសឈាមយ៉ាងពេញទំហឹង

ដើម្បីប្តូរយកជីវភាពថ្មីថ្មី ចំរើនរុងរឿងក្នុងអនាគតកាល ។

ដោយហេតុតែគាត់ទាំងពីរនាក់ ទៅធ្វើការបាត់ ៗ ពីផ្ទះពេលថ្ងៃ, ស្វានៅផ្ទះបានដៃ ឡើងរុករើពេញទាំងផ្ទះ, លុះឃើញស្បោងក្អូរនៅលើជើងក្រាន ទឹកស្មានថាជាអាហារក៏លោតទៅកន្ត្រាក់របូតស្បោងប្រាក់នោះធ្លាក់ចូលក្នុងជើងក្រាន, ត្រូវព្រះអគ្គីឆេះអស់ប្រាក់គ្មានសេសសល់តិចតួចឡើយ ។ លុះគាត់ត្រឡប់មកពីធ្វើការ មិនឃើញស្បោងប្រាក់ក៏ទឹកធ្លុលមើលទៅក្នុងជើងក្រាន ឃើញតែកំទេចក្រដាសប្រាក់ដែលភ្លើងឆេះអស់ ៗ មានសេចក្តីខឹងចំពោះស្វាខ្លាំងណាស់ ក៏វាយស្វាមួយព្រនង់ហើយបោះទៅក្នុងព្រៃ, ស្វាក៏បោលបាត់ទៅ ។ ប្រពន្ធកើតទុក្ខទោម្នេញ ដោយសារតែស្វាមីវាយស្វារបស់ខ្លួនបោះចោល ។ លុះស្វាមីកំហឹងអស់ហើយ ប្តីនិយាយលួងលោមប្រពន្ធថា "សក្កទេវរាជបានមកពន្យល់យើងថា កុំឲ្យឈ្លោះទាស់ទែងខ្វែងគំនិតគ្នា យើងនឹងរកស៊ីមានបានទ្រព្យសម្បត្តិស្តុកស្តម្ភ ដូច្នេះនាងកុំកើតទុក្ខអ្វីចំពោះស្វានេះ ចាំយើងរកស៊ីមានបងនឹងរកស្វានេះឲ្យអូនវិញ" ប្រពន្ធឮប្តីនិយាយដូច្នោះ មានសេចក្តីត្រេកអរណាស់ ក៏ពួតដៃគ្នារកស៊ីតទៅទៀត ។

ក្នុងរសៀលថ្ងៃមួយនោះ, ព្រះពិរុណមិនបង្អុរដើម្បីឲ្យកសិករធ្វើស្រែបានដោយស្រួលសោះ, ពំនឹះ ស្ងួតហួតហែង, ទាំងត្រពាំងបឹង

ឬក៏រីងស្ងួតអស់គ្មានសល់, កសិករទាំងប្រទេសស៊ើរតែដាច់ពោះស្លាប់ដោយការអត់បាយគ្មានទឹកធ្វើស្រែ ។

បុរសប្តីប្រពន្ធប្រឹក្សាគ្នាថា: បើយើងនៅទំនេរទាំងអស់គ្នាដូចសព្វថ្ងៃនេះ ឃើញថាគ្មានបានផលអ្វីសោះ ។ ដូច្នេះ, បងសុំលាអូនទៅរកស៊ីឈ្នួលគេ គ្រាន់បានប្រាក់កាសនឹងទិញគ្រប់ទឹម ។ ប្រពន្ធក៏ទទួលព្រមហើយជូនពរសព្វសាធុការចំពោះប្តីថា: សូមឲ្យបងអញ្ជើញទៅបានប្រកបដោយសេចក្តីសុខ ចំរើន, រកការងារក៏ឲ្យបានប្រទះតែសម្បូរសជនកុំបីឃ្លាត" ហើយរៀបចំបាយសំណុំទឹកបំពង់ជូនដំណើរប្តីឥតមានខ្វះ ។ ប្តីក៏ចេញអំពីផ្ទះចោលប្រពន្ធ ជាទីស្រឡាញ់ ទាំងសេចក្តីអាល័យយ៉ាងក្រៃលែង ។ លុះដើរឆ្ងាយទៅ ៗ បានទៅដល់ផ្សារមួយជាទីប្រជុំជនយ៉ាងធំមានគេហដ្ឋានកុះករច្រើនមហិមា ។

នៅក្នុងផ្សារនោះមានដន្លោះឈើម្នាក់ ដែលប្រើសុទ្ធតែដំរីឲ្យអូសឈើទម្លាក់ពីលើខ្នងដឹក ។ បណ្តាដំរីទាំងនោះមានដំរីមួយកាចសាហាវបានសម្លាប់ទ្រមាក់ម្នាក់ស្លាប់ថ្មី ៗ ។ ដន្លោះឈើខំស្វះស្វែងរកទ្រមាក់ថ្មីទៀត តែមិនបានដូចបំណង ។

បុរសកំសត់ព្រាត់ពីប្រពន្ធជាទីស្រឡាញ់ បានទៅដល់ទីផ្សារនោះ ហើយ បានដឹងថា: ដន្លោះឈើកំពុងខ្វះទ្រមាក់ដំរីដូច្នោះ មានសេចក្តីត្រេក

អណ្ដាស់, ប៉ុន្តែមានសេចក្ដីព្រួយបន្តិចមកវិញ ដោយគេប្រាប់ថាដំរីនោះកាច ហោកសម្លាប់ទ្រមាក់អស់ច្រើនណាស់ហើយ. វាទើបនឹងហោកទ្រមាក់ម្នាក់ស្លាប់ក្នុងពេលថ្មីៗ នេះ ។ គាត់ក៏ប្រញាប់ប្រញាល់ដើរសំដៅទៅផ្ទះដម្បៀឈើ ។ បានទៅសំពះដំរាបសួរតាមសេចក្ដីគួរសម ថៅកែបានទទួលសំពះតបដោយចិត្តរីករាយ ហើយសួរថា:

– អ្នកមកពីណា? មានការអ្វី?

– បាទព្រោស, ខ្ញុំបាទជាអ្នកទីទ័លក្រ មកពីស្រុកឆ្ងាយ ដើម្បីនឹងមកសុំស៊ីឈ្នួលនៅក្នុងសំណាក់លោក ។

– អ្នកអាចកាន់កាប់ដំរីនោះបានដែរ ? (ចង្អុលទៅដំរី)

– បាទព្រោស, ឲ្យតែព្រះតេជព្រះគុណឲ្យការធ្វើ, ទោះបីឲ្យខ្ញុំបាទធ្វើការអ្វី ខ្ញុំបាទនឹងធ្វើតាមបង្គាប់ទាំងអស់ ។

ថៅកែ បានចុះឈ្មោះបុរសនេះ នៅក្នុងបញ្ជីសម្រាប់កម្មករស្រួលបួលហើយ ក៏នាំកម្មករថ្មីនេះទៅប្រគល់ដំរីឲ្យ ។

កម្មករផងទាំងពួង មានសេចក្ដីអាណិតអាសូរទ្រមាក់ថ្មីនេះណាស់ព្រោះទ្រមាក់មុនៗ មាឌធាត់ធំមាំមួនក្រអាញ ម្ដេចដំរីនេះសម្លាប់អស់ជាច្រើន, ចំណង់បើបុរសនេះមាឌតូចស្គមកំព្រឹង មានតែស្បែកដណ្ដប់ឆ្អឹងយ៉ាងនេះ មុខតែដំរីនេះសម្លាប់ទៀតមិនខាន ។ បុរសក៏សត, កាលបើ

ថៅកែប្រគល់ដំរីដ៏សាហាវមកឲ្យខ្លួនដូច្នោះ ក៏តាំងអធិដ្ឋានដោយមេត្តាចិត្តថា: " ឱ! ដំរីដ៏កាចសាហាវ, ខ្ញុំនេះជាមនុស្សទ័លក្រ, មករកស៊ីឈ្នួលគេ យកលុយកាក់ គ្រាន់នឹងបានចិញ្ចឹមជីវិតខ្លួននឹងប្រពន្ធកូនតែប៉ុណ្ណោះ ខ្ញុំមិនមែនមកប្រាថ្នាដើម្បីធ្វើទុក្ខបុកម្នេញដល់អ្នកឡើយ" ។ គ្រាន់តែទឹកអធិដ្ឋានក្នុងចិត្តដូច្នេះ, ដំរីដែលធ្លាប់តែមានចិត្តកន្ទ្រឹសឫស្យារឹងរូស កាចសាហាវមហិមា ក៏មានចិត្តប្រែក្លាយទៅជាទោរទន់អាណិតអាសូរករុណា ចំពោះទ្រមាក់ថ្មីនេះ បែរមុខមករកទ្រមាក់ថ្មីនោះហើយឈរសម្រុកទឹកភ្នែករហាម ហាក់បីដូចជាគិតឃើញថាទ្រមាក់ថ្មីនេះមានមេត្តាចំពោះខ្លួនយ៉ាងក្រៃលែង ។ នេះដោយអំណាចមេត្តាធម៌របស់បុរសនោះ ។ ទ្រមាក់ថ្មីក៏ចូលទៅស្រាយច្រវ៉ាក់ ដែលគេចងវាអស់ ២-៣ ថ្ងៃមកហើយនោះ ឲ្យបានរបូតរួចស្រេច ទើបឡើងជិះតាមស្រួលឥតមានគ្រោះថ្នាក់អ្វីឡើយ ។

តាំងពីថ្ងៃនោះមក កម្មករថ្មីនេះ ត្រូវបានសេចក្តីកោតសរសើរយ៉ាងច្រើនអំពីសំណាក់ថៅកែ-អំពីកម្មករផងគ្នា ទាំងអំពីអ្នកស្រុកផងទាំងពួង ។ គាត់ខំធ្វើការដោយយកចិត្តទុកដាក់ ចំពោះថៅហ្វាយនាយឥតមានធ្វេស, ខំថែរក្សាដំរីដែលខ្លួនកាន់កាប់ ដោយឲ្យស្មៅស៊ី-ទឹកផឹកបានឆ្អែតគ្រប់គ្រាន់ឥតខ្វះកន្ទះ ។ ដំរី ដែលកាលពីដើមជាសត្វស្គមកំព្រឹង ឥឡូវប្រែក្លាយ

ទៅជាសត្វឆាត់ធំ មានកម្លាំងពលំមាំមួន អាចប្រើការអូសឈើបានដូច បំណង ។ កន្លះ ១ ថ្ងៃ។ គាត់បរដំរីឲ្យអូសឈើទម្លាក់ពីលើខ្នងភ្នំ ជាមួយនឹង កម្មករឯទៀតជាច្រើន ។ ឈើណាដែលកម្មករឯទៀតឲ្យដំរីអូសមិនរួច, គាត់អាចប្រើដំរីរបស់គាត់ឲ្យអូសទាល់តែបាន ។ ដូច្នេះហើយ បានជាគាត់ បានសេចក្ដីកោតសរសើរជាច្រើនអំពីចៅហ្វាយនាយ ។

ចំណែកកតិយានៅផ្ទះវិញ ខំប្រព្រឹត្តតាមដំបូន្មានប្ដីឥតខ្ចេះ ។ នាងអង្គុយនៅមាត់ទ្វារផ្ទះ ដេរប៉ាក់ ស្រែះចាក់ទូរសំលៀកបំពាក់ណា ដែលរហែកធ្លុះធ្លាយ ឲ្យបានជិតឡើងវិញផង, មើលចាបមិនឲ្យស៊ីស្រូវក្នុង ស្រែផង ។ទោះបីដៃរបស់នាងខំធ្វើការឲ្យរវើកយ៉ាងណាក៏ដោយ ចិត្តរបស់ នាងតែងនឹកមមៃដល់ស្វាមីជានិច្ច ។ ដូនកាលនាងសម័យឃើញហាក់ បីដូចជាឮសំឡេងប្ដីនាងស្រែកហៅ , តែនាងរកមើលមិនឃើញសោះ គឺគ្រាន់តែជានិមិត្តរូប មកលង់វិញ្ញាណរបស់នាងប៉ុណ្ណោះ ។ នាងនឹក ថា មិនដឹងជាថ្ងៃ-ខែ-ណាប្ដីនាងនឹងវិលមកវិញ, ណាមួយនាងនៅតែ ម្នាក់ឯង ខ្លាចក្រែងឈឺក្បាលវិលមុខ ឬ ក៏មានសត្វព្រៃកាចសាហាវយង់ ឃ្នងណាមួយមកយាយីដល់នាង ។

ថ្ងៃងពីប្ដីនាងវិញ, ក៏មានសេចក្ដីទុកអាល័យមកកតិយាណាស់ដែរ ។ កម្មករផងគ្នា គេសប្បាយរីករាយយ៉ាងក្រៃលែង ផ្ទុយទៅវិញគាត់តែងតែ មានមុខស្រពាប់ស្រពោនជានិច្ច ។ គាត់បរដំរីទៅធ្វើការពេលថ្ងៃ

វិញ្ញាណរបស់គាត់ តែងតែសាត់អណ្តែតតាមព្រះពាយមកកាន់គេហដ្ឋាន របស់គាត់ ជាពិសេស មកកាន់ភរិយា ។

ថ្ងៃមួយកំពុងបរដំរីទៅអូសឈើ, គាត់សំឡឹងមើលទៅចំការរបស់គាត់ ឃើញដើមត្នោតខៀវខ្ចីងងឹត, គាត់នឹកថាត្នោតនេះធ្លាក់ចំផ្ទះអញពិតហើយ ។ ដូច្នេះ, អញនឹងសុំលាថៅកែទៅផ្ទះវិញ ។ មួយរំពេចនោះ គាត់បរដំរីវិលមកចងនៅកន្លែង ហើយទៅលាថៅកែថា :

ខ្ញុំបាទសូមលាលោកទៅផ្ទះវិញ ។ ទោះបីថៅកែអង្វរយ៉ាងណា ក៏បុរសនោះមិនព្រមនៅ ដោយនិយាយថា "សូមលោកមេត្តាចុះ, ខ្ញុំបាទមិនទាន់ចង់ទៅប៉ុន្មានទេ តែខ្ញុំបាទមើលឃើញដើមត្នោតធ្លាក់ចុះច្រើននៅឯស្រុកខ្ញុំ, ហេតុនោះ ខ្ញុំប្រញាប់វិលទៅដើម្បីកែ ក្របី គោ នង្គ័ល រនាស់ធ្វើស្រែ ។ ថៅកែក៏ទទួលព្រម ហើយឲ្យប្រាក់ខែតាមកំណត់ពេលដែលគាត់បានធ្វើការ, មិនតែប៉ុណ្ណោះ, ថៅកែបានឲ្យប្រាក់បន្ថែមលើប្រាក់ខែនោះទ្វេឡើងទៀតផង ព្រោះគាត់ធ្វើការល្អហើយយកចិត្តទុកដាក់ ។ បុរសទុគ៌តបានប្រាក់ហើយ មានចិត្តត្រេកអរណាស់សំពះលាថៅកែ, ហើយមកលាកម្មករជាមិត្តភក្តិទាំងអស់ ដោយសេចក្តីរីករាយ ។ ពេលនោះគាត់ចេញអំពីសំណាក់ថៅកែ អំពីកម្មករទាំងអស់ ទាំងទីកន្លែង និងសេចក្តីទុក្ខក្រៀមក្រំយ៉ាងក្រៃលែង ។ គាត់ធ្វើដំណើរទៅតាមផ្លូវ ទិញបានក្របីមួយយ៉ាងស្គម ដើម្បីយកទៅ

ទឹមធ្វើស្រែ ៗ លុះទៅដល់ផ្ទះ បានជួបជុំប្រពន្ធប្តីហើយ បានសំណេះសំណាលពីនេះពីនោះ, ហើយជាពិសេស, បានរៀបរាប់អំពីដំណើរដែលខ្លួនបានទៅរកស៊ីនោះ ឲ្យប្រពន្ធបានដឹងសព្វគ្រប់តាមដំណើរ ៗ

តអំពីនោះមក, បុរសប្តីប្រពន្ធ បានខំរកស៊ីដោយទឹមនៃគោមួយ ដើម្បីភ្ជួរនង្គ័ល ៗ ក្នុងមួយឆ្នាំ ៗ គាត់បានផលស្រូវលើសលប់ រកប្រៀបពុំបាន ៗ ប៉ុន្មានឆ្នាំក្រោយមក, ទាំងពីរនាក់ បានឡើងឋានៈទៅជាអ្នកមានសម្បត្តិយ៉ាងស្តុកស្តម្ភ, មានកេរ្តិ៍ឈ្មោះពីរោះខ្ចរខ្ចាយពាសពេញទាំងប្រទេស ក្នុងស្រុកនិងក្រៅស្រុក ៗ

— ដោយសារតែគាត់យកចិត្តទុកដាក់ទៅលើផ្លូវគោលគឺ: ការខំប្រឹងប្រែងខ្នះខ្នែង ឥតទំនេរក្នុងការកសាងជីវភាពឲ្យថ្លៃថ្នូរ ៗ

— ដោយសារតែគាត់ចេះចងសាមគ្គីភាពរវាងគ្នានិងគ្នា មិនទាស់ទែងខ្វែងគំនិតគ្នា ៗ

— ដោយសារតែគាត់ ប្រៀបបាននឹងសត្វកណ្ដៀរដែលខំព្យាយាមយកកាចម៍ដីបន្តិចម្តង ៗ មកពូនកកើតជាដំបូកយ៉ាងធំទៅបាន ៗ

— ដោយសារតែគាត់ មានគំនិតអធ្យាស្រ័យប្រកបដោយមេត្តាជានិច្ច ៗ

ទីបំផុតគាត់បានឡើងទៅជាគហបតីមួយរូបយ៉ាងល្បីល្បាញ នៅក្នុងក្រុង ៗ

## រឿងព្រេងប្រទេសហ្វីលីពីន

បែនអំពី

# អណ្ដើក នឹងស្វាបែកឈើគ្នា

ភិក្ខុ ម៉ែន-រៀម
សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែពីភាសាអង់គ្លេស

---

ថ្ងៃមួយ អណ្ដើកកំពុងតែអង្គុយកាំងថ្ងៃនៅមាត់ទឹក ស្រាប់តែបានឃើញវត្ថុមួយអណ្ដែតតាមទន្លេ នៅចំពីមុខវា ។ កាលវត្ថុនោះអណ្ដែតមកជិត អណ្ដើកបានស្គាល់ថាជាដើមចេក វាលោតចុះទៅក្នុងទឹក, ហែលសំដៅទៅដើមចេកនោះ ហើយទាញយកមកឯច្រាំង ប៉ុន្តែ វាជាសត្វគ្មានកំឡាំងល្មមនឹងលើដើមចេកនោះ យកមកដាក់នៅលើដីរឹងបានឡើយ ។ ម្ល៉ោះហើយ វាចេញដើរទៅ, បានឃើញស្វា រួចនាំស្វានោះត្រឡប់មកមើលលទ្ធផលនោះវិញ; វានិយាយប្រាប់ស្វាថា ៖

—នេះហើយជាដើមចេក ដែលអញស្រង់យកពីក្នុងទឹកមក, ចូរឯងជួយសែងដើមចេកនេះ ទៅចំការរបស់អញ, អញនឹងដាំវា ។

ដោយស្វាជាសត្វថែតាំខ្លួនវា, វានិយាយតបថា :

-បើប្រសិនជាអញត្រូវធ្វើដូច្នោះ អញត្រូវតែបានចំណែកដើមឈើនេះដែរ ។

-ឲ្យតែឯងជួយអញចុះ អញនឹងចែកឲ្យឯង ។

ពេលនោះ ស្វានឹងអណ្ដើកទាំងពីរនាក់ ក៏ទំទាញអូសដើមចេកនោះ នាំទៅចំការរបស់អណ្ដើក ។ ដល់ចំការ, អណ្ដើកនិយាយថា:

-ឥឡូវនេះ យើងត្រូវដីករណ្ដៅដាំវា ។

-ទេ, យើងបាននិយាយថា យើងត្រូវចែកគ្នា! (ស្វានិយាយ) ។

-ពិតហើយ, យើងត្រូវដាំវាសិន ហើយដល់កាលណាវាផ្លែ សឹមយើងចែកគ្នាពាក់កណ្ដាលម្នាក់ ។

-ទេ! ទេ! យ៉ាងហ្នឹង មិនមែនជារបៀបចែកទេ, យើងត្រូវតែចែកគ្នាឥឡូវនេះ ឲ្យហើយទៅ, ឯងយកដើមចេកនេះពាក់កណ្ដាល អញយកពាក់កណ្ដាល ។

-ចែករបៀបឯងហ្នឹង មិនល្អទេ!

-យ៉ាងណាក៏ដោយ អញត្រូវតែយកចំណែករបស់អញឥឡូវនេះឯង ។

ដូច្នេះហើយ អណ្ដើកក៏កាប់ដើមចេក ជាពីរកំណាត់ស្មើគ្នាដោយទើសទាល់ក្នុងចិត្ត ។

ស្វាក្រឡេកមើលចំណែកខាងចុង ប្រកបដោយស្លឹកខៀវខ្ចីដែលវាយល់ថា ជាចំណែកល្អបំផុតនោះ ក៏បន្ទឹសិដ៏ថា :

-អាតាក់កណ្ដាលខាងចុង ត្រូវបានអញ ! ។ រួចហើយ វានាំយកចំណែកដែលមានស្លឹកខៀវខ្ចី ទៅក្នុងចំការរបស់វា ។

ឯអណ្ដើកក៏ដាំចំណែកដើមចេកដែលសល់ គឺខាងគល់, លុបដីជាន់បង្ហាប់យ៉ាងខ្ជាប់ខ្ជួនជុំវិញដើមនោះ ។ ចំណែកដើមដ៏ខៀវរបស់ស្វា មិនយូរប៉ុន្មានក៏ស្វិតស្រពោនងាប់ទៅ ។ ប៉ុន្តែ ចំណែករបស់អណ្ដើកដែលមានឫសនោះ, បានលូតលាស់នូវស្លឹកថ្មី ហើយក្រោយមក មិនយូរប៉ុន្មានក៏ចេញរូបរាងប្រាកដជាដើមចេក មានផ្លែកើតឡើង ។

កាលដែលផ្លែចេកនោះទុំ អណ្ដើកចង់បេះស៊ី ប៉ុន្តែវាមិនអាចឡើងបេះបានឡើយ ។ ដូច្នេះហើយ វាក៏ទៅនាំស្វាមកម្ដងទៀត ហើយសុំឲ្យស្វា ឡើងទៅបេះទំលាក់មកឲ្យវា, វានិយាយថា ៖

-ដោយសេចក្ដីខ្នះខ្នែងរបស់ឯង, អញនឹងឲ្យផ្លែចេកទៅឯងខ្លះ ។

ស្វាបានឡើងទៅអង្គុយលើចុងដើមចេក រួចតាំងភ្លក្សផ្លែចេកមើល ឯអណ្ដើកបានអង្គុយចាំខាងក្រោម ប៉ុន្តែស្វាឥតទំលាក់មកឲ្យអណ្ដើកមួយឡើយ វាអង្គុយស៊ីធ្វើព្រងើយ លើចុងចេកនោះ; អណ្ដើកនិយាយថា ៖

-ទំលាក់ឲ្យអញខ្លះមក អញនឹងចាប់ !

- កុំអី! (ស្វាឆ្លើយតប), ពីមុនឯងបានបោកបញ្ឆោតអញ ដោយឲ្យចំណែកខាងអាក្រក់មកអញ, ឥឡូវនេះ អញត្រូវតែស៊ី !

- ចោះឲ្យអញពីរ.បី មក ! ។

- ហ៎ ! នេះសំបក! ស៊ីទៅ! ។ ថាហើយស្វាក៏បោះសំបកចេកទំលាក់មកលើដី ។

ដល់មកថ្នាក់នេះ អណ្តើកត្រឡប់ជាខឹង ហើយក៏បានទៅប្រមូលកណ្តកវត្ត (វត្តដែលមានសណ្ឋានជាបន្លា) នឹងបន្លាឈើផ្សេង ៗ អំពីព្រៃស៊ុំទ្រុំ យកមកកាយជុំវិញគល់ចេក រួចក៏ទៅពួនបាត់ ។

កាលដែលស្វាស៊ីផ្លែចេកអស់ហើយ ក៏លោតចុះមក ហើយបានជាន់ទៅលើបន្លាទាំងនោះ ក៏ស្រាប់តែលោតកញ្ឆក់ក៏យកញ្ឆេង ស្រែកដោយការឈឺចាប់ ចំពោះបន្លាមុតជើងយ៉ាងវេទនា ។ ជាន់ត្រង់ណាក៏ដោយ ស្វាចេះតែប៉ះលើបន្លាជាដរាប ។

ទីបំផុត អណ្តើកឃើញទិដ្ឋភាពដូច្នោះ ក៏អត់សើចមិនបាន ។ ឮសំណើច, ស្វាស្ទុះទៅក្រញាំអណ្តើក ចាប់ក្បាលទាញបត់ទៅលើស្លឹក ធ្វើឲ្យអណ្តើកកេតពំនាក់គ្នា ។

- ពេលនោះស្វាប្រកាសឡើងថា ៖

- ឥឡូវនេះ អាឯងត្រូវទទួលទណ្ឌកម្ម ចំពោះបទឧក្រិដ្ឋរបស់

អាឯង ! ,  គេឲ្យអញសំពងអាឯងនឹងដំបង  ឬឲ្យអញដាក់អាឯងទៅក្នុងត្បាល់ថ្ម រួចកិនអាឯងឲ្យទៅជាម្សៅតែម្ដងទៅ ? ឬមួយក៏ចង់ឲ្យអញ គ្រវែងអាឯងចុះពីលើកំពូលភ្នំវិញ ? ។

ស្វាបាននិយាយណែនាំអណ្ដើក តាមរបៀបនេះ ច្រើនបែបច្រើនយ៉ាងទៀត ។

ទីបំផុត អណ្ដើកឆ្លើយថា ៖

—បាទ ! ធ្វើបែបនេះ ជាការប្រពៃណាស់, អញ្ជើញធ្វើតាមចិត្តចុះ, បោះខ្ញុំពីកំពូលភ្នំក៏បាន, កិនខ្ញុំក៏ទំបកក្នុងត្បាល់ថ្មក៏បាន, សំពងនឹងដំបងក៏បាន, ការធ្វើទាំងអស់នេះ នឹងនាំឲ្យខ្ញុំរឹងរឹតតែសប្បាយឡើងទៀត, ប៉ុន្តែ សូមមេត្តាអាណិត កុំតែបោះខ្ញុំទៅក្នុងទឹកឲ្យសោះ ! ។

—អូ , ទឹក ? ម៉េចបានជាអញគិតមិនដល់ហ្ន៎ ?
បើអ៊ីចឹង អញនឹងបង្ហើយអាឯងឲ្យស្រេចទៅក្នុងទឹកតែម្ដង ! ។

ជាហើយ ស្វាចាប់លើកអណ្ដើកយួរ សំដៅទៅមាត់ទន្លេ ហើយបានគ្រវែងអណ្ដើក ទៅត្រង់ទឹកដ៏ជ្រៅបំផុតក្នុងស្បូវប្រូង លិចបាត់ពីទិដ្ឋភាព ។ ស្វាសប្បាយចិត្តណាស់ ។ ក្រោយនោះអណ្ដើកបានងើបក្បាលផុតពីផ្ទៃទឹកមកវិញ រួចនិយាយទៅកាន់ស្វាថា ៖

—អរគុណសំឡាញ់, អរគុណ ! អ្នកឯងមិនដឹងថា ទឹកជាគេហដ្ឋានរបស់ខ្ញុំទេឬ ? ។

# រឿងសាមកុក

## កណ្ឌទី ៤១

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាតបើបានអាន
> នឹងរេះឲ្យបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ។

ជៀវហៀនិងជៀវឡាំ ដែលជាទាហានអ៊ួនសៀវឆ្លើយជំរាបប៉ូឆូថា ខ្ញុំបាទជាពួកអ្នកលើកមែន តែបំណានការខាងទូកគ្រាន់បើដែរ ខ្ញុំបាទនឹងសុំទូកចម្បាំង ២០ ផ្ទុកទាហានឲ្យព្រម លើកទៅវាយកងទ័ពជីវយី វេលានេះ យកជ័យជោគជាជំនូនឲ្យប្រាកដកើតឈ្មោះថាជាមនុស្សអ្នកលើបំណានក្នុងការទូកក្ដារ ។

ប៉ូឆូតបថា ដែលអ្នកទាំង ២ នឹងបំណានការទូកមែន តែបានខាង ឯក្នុងស្ទឹងនឹងព្រែក ឯពួកស្រុកកាំងតាំងខ្លាំងពូកែខាងទូកនោះ

រួសរហ័សណាស់ បើដូចត្រីហែលប្រណ្តាស់គ្នាក្នុងទឹក អ្នកទាំង ២ កុំបី មើលងាយ ដែលទឹងអាសាទៅនោះក៏គាប់ចិត្តខ្ញុំណាស់ហើយ តែយើងទឹងឲ្យទៅនោះ បើដូចក្លែងធ្វើឲ្យអ្នកទាំង ២ ស្លាប់អសារឥតការ ៗ

ដៀវហៀ, ដៀវឡាំបេះតែអង្វរ បើខ្ញុំបាទអាសាទៅដល់សេចក្តីស្លាប់ក្នុងកងទ័ព សូមលោកយកបុត្រភរិយាបងប្អូនខ្ញុំបាទទាំង ២ នាក់ មកចំហោកទឹកចេញឲ្យអស់ទៅចុះ ៗ ប៊ូឆូគបថា ទូកចម្បាំងធំ ៗ ក៏ចងភ្ជាប់គ្នាអស់ទៅហើយ នៅតែទូកតូចរហ័សសម្រាប់ប្រើប្រាស់យាមល្បាត ហើយក៏ចុះទាហានតែ ២៥ នាក់ ដែលទឹងទៅនោះឃើញជាមិនបាន ៗ

ដៀវហៀ, ដៀវឡាំថា តែត្រឹមទូកតូចក៏បានដែរ ទឹងបានធ្វើការរហ័សបើទឹងប្រោសហើយ ថែងទូកឲ្យដៀវឡាំពាក់កណ្តាល លើកធ្វើទៅវាយខ្ទប់យកកងទ័ពទូកដីវយី កាត់យកក្បាលដីវយីឲ្យបាន ៗ ប៊ូឆូថា បើទឹងអាសាទៅក៏ទៅចុះ យើងទឹងឲ្យទាហាន ៥០០ ហើយទឹងឲ្យប៊ុនផេងនាំទូកចម្បាំង ៣០ លើកជូនទៅក្រោយ តែអ្នកទាំង ២ ធ្វើតែល្មមឲ្យឃើញថ្វីដៃ កុំរំលោកបំពានចូលទៅឲ្យថូសការ; ដៀវហៀ ដៀវឡាំ មានសេចក្តីត្រេកអរក៏គំនាប់លាប៊ូឆូចេញមក ហើយចាត់ចែងទាហានទឹងគ្រឿងសាស្ត្រាវុធឲ្យចុះទូក ២៥ លើកដង្រែងទៅកងទ័ពដីវយី ៗ

ឯទាហានដីវយី កាលថ្ងៃដែលប៊ូឆូឲ្យបណ្តោតផែទូកចម្បាំងនោះ

ដឹងដំណឹងហើយ ក៏ចូលទៅប្រាប់ដីវយ៉ា ។ ក៏នាំទាហានឡើងទៅមើល លើកំពូលភ្នំខ្ពស់ ឃើញទាហានក្នុងកងទ័ពចូចូ បណ្តែតផែទូកចម្បាំង វាយស្គរស្រែកហោកញ្ជ្រៀវអឺងកង ទើបដីវយ៉ាត្រឡប់មកបន្ទាយវិញ

កាលជៀវហៀ, ជៀវឡាំលើកទ័ពទូកទៅនោះ ទាហានយាមល្បាត ក៏ចូលទៅប្រាប់ដីវយ៉ា ។ ក៏ប្រើក្បួនទាហានទាំងពួនថា ទាហានចូចូ លើកកន្ទួងចូលមកដល់មុខកងទ័ពទូកយើងហើយ នរណានឹងអាចទទួល អាសាចេញទៅតទឹងសឹកសត្រូវបាន ហ៊ានតុងទីងជីវថាយ ក៏លាដីវយ៉ា ចេញទៅចុះទូក ព្រមទាំងទាហានគ្រប់ទូកទាំង ៥ ។

ឯជៀវហៀ, ជៀវឡាំ ឃើញទាហានដីវយ៉ាចេញមកក៏ស្រែកថា អញទាំង ២ មានថ្វីដៃខ្លាំងពូកែណាស់ នរណាអាចហ៊ានមកតស៊ូនឹងអញ ក៏ឲ្យចេញមុខមកចុះ; ឯជៀវហៀកាន់លំពែងឡើងទៅឈរខាងក្បាលទូក ឲ្យទាហានស្រូតថែវហើយឲ្យបាញ់ធ្នូចម្រុះទៅជាច្រើន ឯហ៊ានតុងក៏យក ខែលនេព្រួញ លុះទូកចម្បាំងចូលទៅជិតគ្នា ហ៊ានតុងក៏យកលំពែង ចាក់ត្រូវជៀវហៀស្លាប់ ហើយលោតឡើងលើទូកកាប់សម្លាប់ទាហាន ក្នុងទូកនោះស្លាប់អស់លើង ជៀវឡាំឃើញដូច្នោះ ក៏ឲ្យទាហានស្រូត ថែវទូកជំនួយចូលទៅតយុទ្ធទៀត ជីវថាយក៏ជេញទូកទាហានចូលទៅជិត គ្នា ហើយលោតឡើងទៅលើទូក យកក្រប៊ីកាប់ជៀវឡាំស្លាប់ ហើយ

កាប់ចាក់ទាហានក្នុងទូកនោះ ស្លាប់អស់គ្មានសល់ ឯទូកទាហានដៀវហៀ, ដៀវឡាំដែលសល់នោះ ក៏ស្រូតថែវថយរត់ទៅក្រោយវិញ ហ័នតុងក៏លើកទូកដេញតាម ទទួលប្រទះនឹងទ័ពទូកប៉ុនផេងលើកជាជំនួយមកតាមពីក្រោយ ក៏ចូលច្បាំងប្រយុទ្ធគ្នាជាកោលាហល ។

ក្នុងខណៈជីវយីទៀងទៅលើកពលកំ ក្រឡេកទៅខាងជើង ឃើញទូកកងទ័ពចូលជោតទង់ប្រូងប្រុះជាច្រើន ហើយក្រឡេកមកត្រង់មុខបន្ទាយរបស់ខ្លួន ឃើញទង់ទូកចម្បាំងហ័នតុង, ជីវថាយ កំពុងច្បាំងគ្នានឹងប៉ុនផេង ជាសន្ធឹកណាស់ ឃើញទូកទ័ពប៉ុនផេងទប់ទល់ពុំឈ្នះ ក៏ថយរត់ទៅ ឃើញទូកទ័ពហ័នតុង, ជីវថាយនៅថែវដេញតាម ជីវយីបារម្ភខ្លាចក្រែងទ័ពចូលទៅនឹងបង្គាប់ចាំធ្វើអន្តរាយ ហ័នតុងនឹងជីវថាយឲ្យខូចការ ជីវយីក៏ប្រឹក្សានឹងនាយទ័ពនាយកងទាំងពួងថា ទូកចម្បាំងចូលច្រើនលើសលុបហួសវិស័យដែលនឹងគណនារាប់ ឧបមាដូចស្លឹកឈើដែលនៅលើដើម យើងនឹងរិះគិតតតាំងច្បាំងប្រការម្ដេច ទើបនឹងបានជ័យជំនះ ។

ទីប្រឹក្សានឹងសេនាទាហានទាំងពួង នៅមិនទាន់ឆ្លើយថាប្រការម្ដេច ទទួលកើតខ្យល់ព្យុះបក់បោកមកខ្លាំងណាស់ ជីវយីក្រឡេកទៅឃើញទង់លឿងក្នុងទ័ពចូលបាក់ដងរលំចុះ ជីវយីក៏សើចហើយថា

ដែលទង់ជ័យចូចូបាក់ដងនោះ ជាការអពមង្គលដល់ចូចូ ល្មមផុតពាក្យនិយាយ ចុងខ្យល់ក៏បក់បោកមកទៀត ត្រូវទង់ជ័យក្នុងកងទ័ពជីវយីរបូតចេញពីដង អណ្តែតឡើងទៅធ្លាក់លើក្ឋំ ចំពោះមុខជីវយី ។

ជីវយីឃើញដូច្នោះ ក៏ភ័យស្លុតចិត្តគិតថា ឥឡូវនេះកងទ័ពចូចូជាដើមខ្យល់ ឯខាងទ័ពយើងនៅជាចុងខ្យល់ ការដែលគិតទុកថានឹងដុតទ័ពចូចូនោះ ឃើញជាមិនបានសម្រេច ព្រោះខ្យល់មិនបានបក់ត្រឡប់ទៅខាងទ័ពចូចូ តើនឹងរិះគិតប្រការម្តេចអេះ មិនឃើញច្រកល្ហកសោះដូច្នេះ មិនដឹងជាយ៉ាងណា ។ ជីវយីក៏មានសេចក្តីក្តៅក្រហាយព្រួយទុក្ខទោមនស្សមិនសប្បាយ ចេះតែក្រហល់ក្រហាយញ័រអស់សព្វសាច់តែគិតទៅគិតមកមិនដាច់ស្រេច រឹតតែទុក្ខខ្លាំងឡើង ទាល់តែក្អួតធ្លាក់មកសុទ្ធតែឈាម ហើយដួលសន្លប់នៅទីនោះ ទាហានទាំងអស់ក៏ភ័យស្លុតស្មារតី ជួយគ្នាគ្រាហ៍នាំខ្លួនជីវយីត្រឡប់ចុះទៅបន្ទាយ លុះគេត្រូវប្រថាប់ដឹងខ្លួនហើយ ទាហានទាំងពួងក៏ប្រឹក្សាគ្នាថា គ្រានេះជីវយីជាមេកងធំកងទ័ពត្រឡប់ជាឈឺដូច្នេះ បើសិនណាជាចូចូដឹងក៏នឹងលើកទ័ពមកច្បាំងគ្រប់សង្កត់ យើងក៏នឹងបានសេចក្តីភ្ញាំងភ្ញាក់បរាជ័យ, ហេតុនេះត្រូវយើងនាំសេចក្តីទៅជំរាបស៊ុនគ្វីន សូមខ្លួនហ្មពេទ្យដែលឯក នាំមកព្យាបាលរក្សារោគជីវយីឲ្យស្រះជា ទើបនឹងបានធ្វើការជាប់តទៅ ។

ខណៈនោះ ឡោសុកឃើញជីវ័យឈឺក្រោកមិនរួចដូច្នោះ ក៏មិនមានសេចក្តីសប្បាយទើបនាំរឿងរ៉ាវទៅប្រមាណប្រាប់ខុនបេនថា ជីវ័យក្អួតឈាម ឥឡូវនៅដេកឈឺមិនទាន់ជា ខុនបេនក៏តែងសួរថា កាលបើជីវ័យឈឺអ្នកនៅដូច្នេះ តើអ្នកបានឃើញការតាំងពួននោះនឹងជាប្រការម្តេច ឡោសុកថា ដែលជីវ័យជាមេកងធំក្នុងទ័ពបង្គាប់បញ្ជាការតាំងពួន ឥឡូវមកឈឺដូច្នេះ ក៏ជាបុណ្យរបស់ប៉ូច ជាកម្មរបស់ពួកស្រុកតាំងតាំង ខុនបេនឮដូច្នោះក៏អស់សំណើចហើយថា ឯកេតជីវ័យនេះខ្ញុំក៏ល្មមនឹងរក្សាព្យាបាលឲ្យស្រះជាបាន ។

ឡោសុកថា បើលោករក្សាកេតជីវ័យឲ្យស្រះជាបាន ក៏ជាបុណ្យរបស់អ្នកស្រុកតាំងតាំង ហើយឡោសុកក៏នាំខុនបេនចូលទៅក្នុងបន្ទាយឲ្យខុនបេននៅខាងក្រៅ ខុនឡោសុកឯងក៏ចូលទៅខាងក្នុង ឃើញជីវ័យកំពុងដេកឈឺ ឡោសុកសួរថា ដែលលោកឈឺនេះ បណ្តាលមកពីហេតុអ្វី ? ជីវ័យថា ហេតុក្នុងខ្លួនខ្ញុំ មិនដឹងប្រាប់ថាឈឺនោះយ៉ាងម្តេចទេ តែក្នុងដើមទ្រូងត្រង់ថ្ងៃប្រមាត់នោះញាប់ញ័រ ចាប់ដូចជាត្រូវអាវុធផ្សេងៗ ឡោសុកសួរថា លោកបានពិសាថ្នាំអ្វីខ្លះដែរឬទេ ? ជីវ័យប្រាប់ថា ថ្នាំមានគ្រប់មុខ តែដឹកមិនបាន ព្រោះហេតុថាខ្យល់មកស្ទះប៉ះដពច ឡោសុកថា ហេតុលោកដែលឈឺនេះ ខុនបេនថានឹងមើលឲ្យជា ឥឡូវខុនបេន

មកដែរនៅខាងក្រៅ ជីវ័យក៏ឲ្យអញ្ជើញខុនបេងចូលទៅ ហើយឲ្យមនុស្សដែលថែពេគលើកគ្រាហ៍ឲ្យអង្គុយ ខុនបេងថា ខ្ញុំមិនបានមកសួរលោក ២-៣ ថ្ងៃនេះ លោកក៏បង្កើតបច្ចុប្បន្នពេគមកក្ខាម ខ្ញុំមិនដឹងសោះ; ជីវ័យថា ធម្មតាកើតមកជាមនុស្សនេះ កម្រនឹងដឹងការក្នុងអាកាស ។

ជីវ័យឮខុនបេងថាដូច្នោះក៏ទឹកខឹងណាស់ តែមិនចេញស្តីថាប្រការម្តេច ធ្វើជាស្រួល តែពេគនោះក៏រឹតតែកំរើកខ្លាំងឡើងទៀត ខុនបេងថា ក្នុងដើមទ្រូងលោកក៏សឹងប្រកបដោយសេចក្តីវិតក្កៈបេះតែប្រមូលគ្នាជាច្រើនឡើង បានជាបណ្តាលទៅជាពេគដូច្នេះ ត្រូវតែប្រកបថ្នាំត្រជាក់ទើបសះជា ជីវ័យថា ថ្នាំត្រជាក់ក៏បានផឹកលេបច្រើនមុខមកហើយ ពេគមិនអន់ស្រន់ចុះ ហើយសួរខុនបេងថា ថ្នាំត្រជាក់របស់អ្នកឈ្មោះអ្វី ? ក្រែងផឹកទៅប្រកបនឹងពេគខ្ញុំ ។

ខុនបេងក៏បណ្តេញមនុស្សបំរើទាំងអស់ចេញទៅ ហើយក៏យកពិធមកសរសេរអក្សរ ១៦ តួជាសេចក្តីថា ដែលនឹងគិតកំចាត់ចូច្ចនោះបានចាត់របៀបរៀបទុកជាស្រេចអស់ហើយ គឺប្រាថ្នានឹងយកក្បួនដុតទ័ពចូច្ចនៅខ្វះតែខ្យល់សលាត៍ខមួយមុខ ដែលមិនបានបក់មកដូចបំណងប្រាថ្នាលោក លុះសរសេរហើយក៏ហុចទៅឲ្យជីវ័យហើយថា ឯពេគដែលឈឺនេះឧបមាដូចធាតុទាំង ៤ ក្នុងរូបកាយរបស់លោក ឯធាតុដីធាតុទឹកក៏មាន

(នៅមានត)

## ផ្នែកកំណត់និងប្រវត្តិការណ៍

### ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

### ព្រះរាជក្រឹត្យ

### តែងតាំងព្រះថេរានុត្ថេរៈជាទីរាជាគណៈ
### និងរាជានុក្រម

---

តាមព្រះរាជក្រឹត្យលេខ ២៣ រ.វ. នៃសម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ តែងតាំងព្រះថេរានុត្ថេរៈឲ្យឡើងឋានន្តរស័ក្តិ មានដូចតទៅនេះ៖

ក– ព្រះឧបាលិវង្ស សូរ-ហាយ ជន្មាយុ ៥៦ ឆ្នាំ វស្សា ៣៤ រាជាគណៈសម្រាប់ត្រី នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ទោ មានគោរម្យងារជា "ព្រះមុនីកោសល" ជាជំនួសព្រះមុនីកោសល សោម-ឈុន ដែលអនិច្ចធម្ម ។

ខ– ព្រះឥន្ទមុនី កែវ-វណ្ណ ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣២ រាជាគណៈសម្រាប់ចត្វា នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ត្រី មានគោរម្យងារជា „ព្រះឧបាលិវង្ស,, ជាជំនួសព្រះឧបាលិ-

វង្ស សួរ-ហាយ ដែលឡើងកាន់ឋានៈជាទីរាជាគណៈសម្រាប់ទោ ។

គ- ព្រះវិន័យសំវរ ពជ-គីង ជន្មាយុ ៥០ ឆ្នាំ វស្សា ៣០ រាជាគណៈសម្រាប់ចត្វា នៅវត្តសាពវ័ន ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ត្រី មានគោរម្យងារជា "ព្រះសិរីសម្មតិវង្ស" ជាជំនួសព្រះសិរីសម្មតិវង្ស ប៉ិន-ម៉ា ដែលអនិច្ចធម្ម ។

ឃ- ព្រះគ្រូមុនីកោស័ណ សេខ-នាង ជន្មាយុ ៤៩ ឆ្នាំ វស្សា ២៥ ឋានានុក្រម នៅវត្តឧណ្ណលោម ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ចត្វា មានគោរម្យងារជា "ព្រះឥន្ទមុនី" ជាជំនួសព្រះឥន្ទមុនី កែវ-វណ្ណ ដែលឡើងកាន់ឋានៈ ជាទីរាជាគណៈសម្រាប់ត្រី ។

ង- ព្រះគ្រូសំវរបញ្ញា ចក់-សេង ជន្មាយុ ៤៥ ឆ្នាំវស្សា ២៩ ឋានានុក្រម នៅវត្តសាពវ័ន ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ចត្វា មានគោរម្យងារជា "ព្រះគម្ពីរត្នោ" ជាជំនួសព្រះគម្ពីរត្នោ ទន់ ហង្ស ដែលអនិច្ចធម្ម ។

ច- ព្រះគ្រូពុទ្ធបណ្ឌិត អ៊ុង-ភួង ជន្មាយុ ៥១ ឆ្នាំវស្សា ៣០ ឋានានុក្រម នៅវត្តព្រះពុទ្ធមានបុណ្យ ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ចត្វា មានគោរម្យងារជា "ព្រះវិន័យសំវរ" ជាជំនួសព្រះវិន័យ-សំវរ ពជ-គីង ដែលឡើងកាន់ឋានៈជាទីរាជាគណៈសម្រាប់ត្រី ។

ឆ- ព្រះគ្រូសង្ឃសុមេធ ធន់-រ៉ាន់ ជន្មាយុ ៤៥ ឆ្នាំ វស្សា ២៥ ឋានានុក្រម នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាទីពជាគណៈសម្រាប់បត្តា មានគោរម្យងារជា "ព្រះសិរីវិសុទ្ធិ" ជាជំនួសព្រះសិរីវិសុទ្ធិ អ៊ិន-ជួន ដែលអនិច្ចធម្ម ។

ជ- ព្រះវិន័យធរ ជុំ-ម៉ក ជន្មាយុ ៥៣ ឆ្នាំ វស្សា ៣២ ឋានានុក្រម នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាទីពជាគណៈសម្រាប់បត្តា មានគោរម្យងារជា "ព្រះញាណសំវរ" ជាជំនួសព្រះញាណសំវរ ទុំ-ឯក ដែលអនិច្ចធម្ម ។

ឈ- ព្រះវិន័យធម្ម ម៉ៃ-ខាន់ ជន្មាយុ ៥០ ឆ្នាំ វស្សា ៣០ ឋានានុក្រម នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាទីពជាគណៈសម្រាប់បត្តា មានគោរម្យងារជា "ព្រះបិដកធម្ម" ជាជំនួសព្រះបិដកធម្ម អ៊ុង-យឿន ដែលអនិច្ចធម្ម ។

ញ- ព្រះវិន័យធរ អ៊ុំ-ទិត ជន្មាយុ ៥៣ ឆ្នាំ វស្សា ៣៣ ឋានានុក្រម នៅវត្តមហាមន្ត្រី ក្រុងភ្នំពេញ ជាទីពជាគណៈសម្រាប់បត្តា មានគោរម្យងារជា "ព្រះវិកូញាណ" ជាជំនួសព្រះវិកូញាណ ឡុង-បានដែលអនិច្ចធម្ម ។

ប្រការ ២- អ្នកឧកញ៉ាវាំងអគ្គនាយកក្រសួងនានាក្នុងព្រះបរមរាជ

ភាំង នឹងទុកញ្ញាពិភក្ដិសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ ត្រូវទទួលភារៈ ចាត់ការរៀងខ្លួន ឲ្យបានសម្រេចការតាមព្រះរាជក្រឹត្យនេះ ។

ព្រះរាជក្រឹត្យធ្វើនៅក្នុងព្រះបរមរាជវាំងចតុមុខ ក្រុងភ្នំពេញ

នៅថ្ងៃ ៦ ១២ ៧ ១០ ឆ្នាំជូតទោស័ក ព.ស. ២៥០៣

ត្រូវនឹងថ្ងៃទី ២ ខែកញ្ញា គ.ស. ១៩៦០

សម្ដេចទ្រង់ឡាយព្រះហស្ដលេខា :

ន. សីហនុ

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ សូមព្រះរាជ

ទានឡាយព្រះហស្ដលេខា នៃព្រះប្រមុខរដ្ឋ

រដ្ឋមន្ត្រីក្រសួងធម្មការ

ហត្ថលេខា: ផូ-ទ្រឿង

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិទូរ គុ. ដែលឆ្ងាយក្រៃលែង; នបុ. ចំងាយក្រៃលែង ។ — *ត្វ* នបុ. ភាពនៃ... ឆ្ងាយក្រៃលែង ។

អតិទ្ឫប្ត គុ. ដែលឆ្មើងឆ្មៃក្រៃលែង ។

អតិទេវិន៑ ៣. ន. អ្នកលេងក្រៃលែង ។

អតិទេឝ បុ. *អតិទេឝ*, ការរីកទូលាយ; ការប្រហែលគ្នា ។

អតិទ្រុត គុ. ដែលចត់ក្រៃលែង ។

អតិទ្វយ–យី គុ. ដែលក្រៃលែងដោយពីរ, ដែលមានតែមួយ ។

អតិធនិន៑ គុ. ដែលមានទ្រព្យក្រៃលែង ។

អតិធន្វិន៑ បុ. ឈ្មោះគ្រូម្នាក់ ។

អតិធវល គុ. ដែលសក្រៃលែង, ដែលសស្គុស ។

អតិធីរតា ស្ត្រី. ភាពនៃបុគ្គលនឹងធឹងក្រៃលែង; — *ធៃយ៌*, នបុ. ភាពនៃបុគ្គលនឹងធឹងក្រៃលែង, ភាពនៃបុគ្គលម៉ឺងម៉ាត់ក្រៃលែង ។

អតិនម្រតា ស្រី. ភាពនៃ ... ទន់ក្រៃលែង ។

អតិនម៌ន៑ បុ. កិរិយារីករាយក្រៃលែង ។

(នៅមានត)